អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
United Nations in Cambodia

# កិច្ចប្រជុំវាយតម្លៃរួមគ្នាលើកទី៧នៃ ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ២០១១-២០១៥

# របាយការណ៍តាមដានប្រចាំឆ្នាំ២០១៤

ថ្ងៃអង្គារ ទី១០ ខែមិនា ឆ្នាំ២០១៥

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

# លទ្ធផល ១ – កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាព

**រហូតដល់ឆ្នាំ ២០១៥ ប្រជាពលរដ្ឋកាន់តែច្រើនឡើងដែលរស់នៅកម្ពុជា ទទួលផលពីកំណើនសេដ្ឋកិច្ច និងចូលរួមក្នុងកំណើនសេដ្ឋកិច្ចនេះ ដែលមានភាពចម្រុះជាងមុន ដែលនាំមកនូវសមធម៌និងបៃតងជាងមុន ។**

## *សេចក្តីផ្តើម*

តាមរយៈUNDAF លទ្ធផល ១ ប្រព័ន្ធអ.ស/ប សម្របសម្រួលកិច្ចប្រឹងប្រែងដើម្បីអភិវឌ្ឍវិស័យកសិកម្ម និងលើកកំពស់ការទទួលបានដោយសមធម៌នូវស្បៀង និងកសិផល គាំទ្រដល់ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ ដើម្បីលើកកំពស់ពិពិធកម្មសេដ្ឋកិច្ច ការបង្កើតការងារ និងការអភិវឌ្ឍជំនាញ និងដោះស្រាយការប្រឈមខាងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។

អ.ស.ប គ្រោងបន្តការគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ចជាមូលដ្ឋានរបស់កម្ពុជា តាមរយៈយន្តការនានា ដែលមានស្រាប់ដែលបានបង្កើតឡើង ដើម្បីសម្របសម្រួលជំនួយពីខាងក្រៅ និងពង្រឹងប្រសិទ្ធភាពជំនួយនៅក្នុងវិស័យអាទិភាពចំនួនបួន ដែលរួមចំណែកក្នុងលទ្ធផលនេះ ពោលគឺ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ វិស័យឯកជន និងការងារ និងការអភិវឌ្ឍធនធានមនុស្ស។

អ.ស.ប បានបង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីបង្កើតលក្ខខណ្ឌអំណោយផល បង្កើនសេវាកម្មអភិវឌ្ឍន៍អាជីវកម្មសម្រាប់មីក្រូសហគ្រាស សហគ្រាសខ្នាតតូចនិងមធ្យម និងដើម្បីបង្កើនវត្តមានការងារ និងឱកាសការងារសមរម្យជាពិសេស សម្រាប់យុវជន និងស្ត្រី តាមរយៈពិពិធកម្មការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានក្នុងទីក្រុង និងទីជនបទនានា។

## *លទ្ធផលឆ្នាំ 2014*

នៅឆ្នាំ2014 អ .ស.ប បានបន្តចូលរួមក្នុងការអភិវឌ្ឍកសិកម្មក្នុងប្រទេសនេះ។ អ.ស.ប បានគាំទ្រដល់ជម្រឿនកសិកម្មដំបូងបង្អស់នៅកម្ពុជា ដែលបង្កើតទិន្នន័យគោលអំពីស្ថានភាពនៃការកាន់កាប់ដីកសិកម្ម និងគ្រួសារនានាក្នុងប្រទេសនេះ។ លទ្ធផលសម្រេចត្រូវបានរំពឹងថានឹងបានចែកផ្សាយនៅក្នុងឆមាសទីមួយឆ្នាំ 2015។

កម្រងទិន្នន័យ CensusInfo 2.0 ដែលរួមមានសូចនាករសេដ្ឋកិច្ច-សង្គម ត្រូវបានកែលម្អ និងអាចជួយឲ្យវិទ្យាស្ថានជាតិស្ថិតិផ្សព្វផ្សាយទិន្នន័យនានាពីគ្រប់ការអង្កេតតាមវិធីដែលងាយស្រួលប្រើប្រាស់។ អ.ស.ប បានផ្តល់ការគាំទ្រក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS 2014) ជុំទីបួន ដោយមានការបញ្ចូលទិន្នន័យពេញលេញអំពីអំពើហឹង្សាក្នុងគ្រួសារ។ សមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិក្នុងការតាមដានសន្តិសុខស្បៀង និងការវិភាគ ត្រូវបានពង្រឹងនៅពេលដែលមានការបញ្ចូលទិន្នន័យសន្តិសុខស្បៀងនិងភាពងាយរងគ្រោះ ទៅក្នុងការអង្កេតសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា (CSES) ឆ្នាំ 2014 ដែលអាចឲ្យមានការគណនាសូចនាករសំខាន់ៗអំពីសន្តិសុខស្បៀង ដូចជា របបអាហារប្រចាំគ្រួសារ ឬពិន្ទុភាពចម្រុះនៃរបបអាហារ សន្ទស្សន៍យុទ្ធសាស្ត្រទប់ទល់ និងភាគចំណែកនៃការចំណាយលើស្បៀងអាហារ។ ការគាំទ្របច្ចេកទេសបានបន្តផ្តល់សម្រាប់ការបោះពុម្ពផ្សាយប្រចាំខែនូវព្រឹត្តិបត្រព័ត៌មានរួមគ្នារបស់កម្ពុជាស្តីពីថ្លៃស្បៀងអាហារនិងប្រាក់ឈ្នួល ព្រមទាំងព្រឹត្តិបត្រព័ត៌មានរួមគ្នាប្រចាំត្រីមាសស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ រួមជាមួយរបាយការណ៍ប្រចាំឆ្នាំស្តីពីសន្តិសុខស្បៀង។ អ.ស.ប ក៏បានគាំទ្ររដ្ឋាភិបាលដើម្បីពង្រឹងសន្តិសុខស្បៀង និងប្រព័ន្ធព័ត៌មានអាហារូបត្ថម្ភ (FSNIS)ផងដែរ។

កម្មវិធីវិធានការចម្រុះការពារដំណាំ(IPM) ដែលបានបង្កើតមូលដ្ឋានគ្រឹះសម្រាប់កម្មវិធីសាលាស្រែកសិករ(FFS) នៅទូទាំងប្រទេស ត្រូវបានបន្តនៅឆ្នាំ 2014។ សមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាល ខាងសេវាកម្មផ្សព្វផ្សាយ និងសេវាកម្មការពារដំណាំ ក៏ដូចជា សមត្ថភាពរបស់ដៃគូអភិវឌ្ឍន៍មិនមែនរដ្ឋាភិបាល ក៏ត្រូវបានពង្រឹងផងដែរ ក្នុងការអនុវត្តកម្មវិធី IPM នៅតាមមូលដ្ឋាន។ កសិករសរុបចំនួន 5.112 នាក់ ដែលរួមទាំង ស្ត្រីចំនួន 1710 នាក់ បានទទួលផលពី

កម្មវិធីនានានៅឆ្នាំ 2014។

អ.ស.ប បានផ្តល់វគ្គបណ្តុះបណ្តាលដល់កសិករខ្នាតតូច តាមរយៈសាលាស្រែកសិករ និងសាលាអាជីវកម្មស្រូវ ដំឡូងមី បន្លែ និងការចិញ្ចឹមមាន់ នៅក្នុងអំឡុងពេលដែលត្រូវគ្នានឹងវដ្តនៃផលិតកម្ម រួមជាមួយការផ្តល់ឥណទានសម្រាប់ទិញសម្ភារៈកសិកម្មនិងការអប់រំអំពីអាហារូបត្ថម្ភ ដើម្បីលើកកំពស់សហគ្រាសកសិកម្ម និងបង្កើនលទ្ធភាពរបស់កសិករខ្នាតតូច ក្នុងការទទួលបានស្បៀងអាហារនៅក្នុងរយៈពេលវែង។ នៅឆ្នាំ 2014 កសិករចំនួន 3.700 គ្រួសារ បានទទួលការបណ្តុះបណ្តាលតាមរយៈសាលាស្រែកសិករ និងសាលាអាជីវកម្មកសិកម្ម និងបានទទួលជំនួយ តាមរយៈសម្ភារៈកសិកម្មនៅខេត្តឧត្តរមានជ័យ និងព្រះវិហារ។

អ.ស.ប បានសហការជាមួយអាជ្ញាធរនានាលើកកម្ពស់ការយល់ដឹងអំពីជម្ងឺផ្តាសាយបក្សី (AI) នៅក្នុងការចាត់ចែងវេទិកាសាលារៀនប្រាស្រ័យទាក់ទងអំពីហានិភ័យនៃជម្ងឺ ផ្តាសាយបក្សីចំនួន 23 លើក ដោយមានសិស្សចូលរួមចំនួន 7.000 នាក់ ដែលបានទទួលព័ត៌មានទាក់ទងនឹងជម្ងឺ ផ្តាសាយបក្សី (H5N1) និងបានរៀនសូត្រអំពីវិធីជៀសវាងការចម្លងវីរុសនេះ។ ជំនួយបច្ចេកទេសបន្ថែមត្រូវបានផ្តល់ ដើម្បីទប់ស្កាត់ និងជៀសវាងការសាយភាយជម្ងឺធ្ងន់ធ្ងរផ្សេងទៀត ដូចជា ជម្ងឺអុតក្តាម។ ជាលទ្ធផល នីតិវិធីសម្រាប់រាយការណ៍ត្រូវបានបង្កើតឡើង ហើយក្រុមពេទ្យសត្វសម្រាប់ការឆ្លើយតបរហ័សត្រូវបានដាក់ឲ្យប្រតិបត្តិការ និងសមត្ថភាពជាតិ ដើម្បីវិភាគសំណាកក៏បានបង្កើនយ៉ាងច្រើនផងដែរ។

អ.ស.ប បានបន្តលើកកំពស់ និងគាំទ្រដល់ការកសាងសមត្ថភាពខាងហិរញ្ញវត្ថុក្នុងចំណោមគ្រួសារក្រីក្របំផុត ដែលជាញឹកញាប់ត្រូវបានទុកចោលនៅក្រៅកិច្ចផ្តួចផ្តើមផ្តល់ប្រាក់កម្ចីតូចៗ។ អ្នកទទួលផលចំនួន 49.200 នាក់ បានទទួលការជួយឧបត្ថម្ភក្នុងការបង្កើត និងការបណ្តុះបណ្តាលក្រុមទុនបង្វិល ការផ្តល់សេវាកម្មបណ្តុះបណ្តាលអំពីការរក្សាទុកកំណត់ត្រា និងការបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីតាមដានប្រតិបត្តិការហិរញ្ញវត្ថុចូល និងចេញពីក្រុមទុនបង្វិលនេះ។

អ.ស.ប បានគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភឆ្នាំ 2014-2018 និងផែនទីបង្ហាញផ្លូវសម្រាប់ ធ្វើឱ្យប្រសើរឡើងយ៉ាងឆាប់រហ័សនូវអាហារូបត្ថម្ភឆ្នាំ 2014-2020 ដែលបានអនុមត័ជាផ្លូវការដោយរដ្ឋាភិបាល។ អ.ស.ប ក៏បានគាំទ្រដល់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពស្បៀងផងដែរ ដែលនឹងជួយកែលម្អសុវត្ថិភាពនៃស្បៀងដែលផលិតសម្រាប់ការនាំចេញ ការនាំចូល និងការបរិភោគក្នុងប្រទេស។ អ.ស.ប បានផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលជលផល ដើម្បីរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិឆ្នាំ 2015-2020 ស្តីពីការបញ្ច្រាបយេនឌ័រ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅក្នុងវិស័យជលផល។ ផែនការសកម្មភាពជាតិស្តីពីការថែទាំ និងការអភិវឌ្ឍកុមារតូចឆ្នាំ 2014-2018 ក៏ត្រូវបានរៀបចំ និងប្រកាសឲ្យប្រើប្រាស់ជាផ្លូវការផងដែរ។

លំហាត់របរចិញ្ចឹមជីវិតចម្រុះសម្រាប់ការវិភាគភាពធន់នៅទូទាំងប្រទេស (CLEAR)បានធ្វើឡើង ដើម្បីស្វែងយល់បានកាន់តែច្បាស់អំពីការគ្រប់គ្រងធនធានធម្មជាតិ ក៏ដូចជា ផលប៉ះពាល់ពីការប្រែប្រួលធាតុ អាកាស និងពីការប្រែប្រួលអាកាសធាតុ មកលើរបរចិញ្ចឹមជីវិត និងភាពធន់ជាក់លាក់។ របាយការណ៍ CLEAR នឹងរៀបចំរួចរាល់នៅឆ្នាំ 2015។

អ.ស.ប បានធ្វើការដើម្បីកែលម្អភាពធន់នៃប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុតដោយសារការប៉ះទង្គិចដែលទាក់ទងនឹងការប្រែប្រួលធាតុអាកាស/ការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតទ្រព្យសម្បត្តិ និងការបន្សាំរបរចិញ្ចឹមជីវិត និងទម្លាប់អនុវត្តនានារបស់សហគមន៍។ នៅឆ្នាំ 2014 អ.ស.ប បានផ្តល់ជំនួយស្បៀងដល់ប្រជាជនប្រមាណជាង 55.440 នាក់ (ក្នុងនោះ ច្រើនជាង 40% ជាស្ត្រី) និងបានផ្តល់ប្រាក់ តាមរយៈការបង់ថ្លៃពលកម្ម និងការបង់ថ្លៃសម្រាប់សកម្មភាពក្នុងសហគមន៍ដល់ប្រជាជនចំនួន 1.781 គ្រួសារ (សរុប 167.804 ដុល្លាអាមេរិក) ក្នុងនោះ 56% គឺជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។ ផែនការសកម្មភាពសាកល្បងមួយត្រូវបានរៀបចំឡើងសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (DRR)នៅក្នុងខេត្តកំពង់ស្ពឺ ដើម្បីណែនាំការអនុវត្តសកម្មភាពជាក់លាក់ និងកាត់បន្ថយការខូចខាត និងការបាត់បង់កសិផល។ យុទ្ធសាស្ត្រជាតិមួយសម្រាប់វិស័យដំណាំត្រូវបានគាំទ្រ និងត្រូវពង្រីកសម្រាប់អនុវិស័យដទៃទៀតក្នុងកសិកម្មផងដែរ។

អ.ស.ប បានជម្រុញ និងអនុវត្តបង្ហាញអំពីការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការប្រើប្រាស់ធនធានឲ្យមានប្រសិទ្ធភាព និងបានជួយរដ្ឋាភិបាលក្នុងការត្រៀមខ្លួនសម្រាប់ REDD+ និងការរៀបចំរបាយការណ៍ស្តីពីការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ សម្រាប់ដាក់ជូនអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ លើសពីនេះ អ.ស.ប បានគាំទ្រដល់ការរៀបចំផែនទីបង្ហាញផ្លូវរបស់ជាតិស្តីពីជីវថាមពលនិងសន្តិសុខស្បៀង (BEFS) ដើម្បីអនុវត្តបង្ហាញអំពីតួនាទី និងការប្រើប្រាស់ថាមពលកកើតឡើងវិញ។

អ.ស.ប បានគាំទ្រដល់ការរៀបចំគោលនយោបាយជាតិស្តីពីការងារនិងមុខរបរ និងបានធ្វើបច្ចុប្បន្នភាពគោលនយោបាយស្តីពីចំណាកស្រុកដើម្បីការងារ និងប្រកាសដែលពាក់ព័ន្ធដទៃទៀត។ អ.ស.ប បានផ្តល់ជំនួយដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយសម្រាប់ចំណាកស្រុក ដើម្បីកែលម្អកិច្ចការពារពលករចំណាកស្រុក តាមរយៈការរៀបចំលិខិតូបករណ៍សម្រាប់សម្រាប់ចំណាកស្រុកដើម្បីការងារ ដោយផ្អែកលើគោលការណ៍ដែលស្រង់ចេញពីស្តង់ដារពលកម្មអន្តរជាតិ។ បទប្បញ្ញត្តិថ្មីមួយត្រូវបានប្រកាសឲ្យប្រើប្រាស់ ដើម្បីការពារបុគ្គលិកក្នុងវិស័យបម្រើការកំសាន្ត និងដើម្បីកាត់បន្ថយការសោយភាយនៃការមាក់ងាយ និងរើសអើងនៅក្នុងវិស័យនេះ។

អ.ស.ប បានផ្តល់ជំនួយនៅក្នុងការជួយឲ្យកម្ពុជារក្សាបានឋានៈជាប្រទេសទទួលផលចំណូលបានច្រើនបំផុតពីការនាំចេញ និងវិស័យរៀបរយដែលស្រូបយកកម្លាំងពលករច្រើនជាងគេ ពោលគឺ ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ដែលរក្សានិរន្តរភាព និងភាពប្រកួតប្រជែង តាមរយៈការពង្រឹងសមត្ថភាពផលិតនិងការនាំចេញ កំណែលម្អលក្ខខណ្ឌការងារ ដែលរួមទាំង អនុលោមភាពជាមួយស្តង់ដារពលកម្មអន្តរជាតិ និងជាតិ និងកំណែសម្រួលកម្រិតប្រាក់ឈ្នួលអប្បបរមាដែលមានតុល្យភាព។ នៅឆ្នាំ 2014 រោងចក្រចំនួន 356 បានទទួលផលពីកម្មវិធីរោងចក្រកាត់ដេរប្រសើរជាងមុននៅកម្ពុជា ហើយឧស្សាហកម្មនេះបានរកចំណូលបានច្រើនជាង ៥ពាន់លានដុល្លាអាមេរិក ជាផលចំណូលពីការនាំចេញ ទន្ទឹមនឹងស្រូបយកកម្លាំងពលកម្មច្រើនជាង 500.000 នាក់ ដែលត្រូវបានប៉ាន់ស្មានថាជាការផ្តល់ការគាំទ្រដល់ប្រជាជនកម្ពុជារហូតដល់ពីរលាននាក់។ លើសពីនេះ យុវជនសរុបចំនួន 4.663 នាក់បានទទួលការងារធ្វើនៅក្នុងឆ្នាំ 2014 តាមរយៈសេវាប្រឹក្សាមុខរបរ និងការងារ នៃទីភ្នាក់ងារជាតិការងារនិងមុខរបរ (NEA)។

អ.ស.ប បានបន្តផ្តល់ការគាំទ្រដល់ពលករចំណាកស្រុកកម្ពុជា តាមរយៈព័ត៌មាន សេវាកម្មមុខរបរ និងជំនួយមនុស្សធម៌ ក៏ដូចជា បានគាំទ្រដល់ក្របខ័ណ្ឌស្ថាប័នសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាត្រឹម 128 ដុល្លាអាមេរិក ជាថ្លៃឈ្នួលអប្បបរមាថ្មីសម្រាប់ពលករនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើង នៅឆ្នាំ 2015។ តាមរយៈការជួយរបស់អ.ស.ប ការយល់ដឹងនិងការទប់ស្កាត់មេរោគអេដស៍ ត្រូវបានរួមបញ្ចូលនៅក្នុងផែនការការងាររបស់សហគ្រាសចំនួន90 ដែលសហគ្រាសនីមួយៗបានបង្កើតគណៈកម្មការប្រឆាំងជម្ងឺអេដស៍ ស្របតាមគោលនយោបាយជាតិ។

## *ការប្រឈម*

- ផលិតភាពកសិកម្មនៅតែមានកម្រិតទាប ដោយសារតែកម្រិតទាបខាងបច្ចេកវិទ្យា ជំនាញដាំដំណាំមានកម្រិតទាប ដីខ្សត់ជីជាតិ និងការគ្រប់គ្រងទឹកមិនបានល្អ ការប្រើប្រាស់ និងការទទួលបានពូជកែលម្អមិនបានគ្រប់គ្រាន់ ការទទួលបានសេវាផ្សព្វផ្សាយក្នុងកម្រិតកំណត់ និងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។ សមត្ថភាពរបស់កសិករដើម្បីទទួលយកបច្ចេកវិទ្យាថ្មីនៅមានកម្រិតទាប ហើយការណែនាំឲ្យប្រើប្រាស់វិធីសាស្ត្រកែលម្អក្នុងផលិតកម្មគឺជាដំណើរការយ៉ាងវែងមួយ។ កំណើនចំណាកស្រុករវាងជនបទនិងទីក្រុង សង្កត់ធ្ងន់ពីគម្លាតខាងសមត្ថភាពនៅតាមទីជនបទ។
- ទោះបីផលិតភាពនៃសហគ្រាសមូលដ្ឋានបានកើនឡើងហើយក៏ដោយ សហគ្រាសកម្ពុជាបន្តប្រកួតប្រជែងជាមួយការហូរចូលនៃផលិតផលនាំចូលដែលមានថ្លៃទាបជាង ចំណែកថ្លៃផលិតផលក្នុងស្រុក ដូចជា សាច់ជ្រូក ឬដំណាំសម្រាប់លក់ ដូចជា ដំឡូងមី និងពោត គ្មានស្ថិរភាព។
- កម្លាំងពលកម្មដែលមានជំនាញកម្រិតទាប តំណាងឲ្យការប្រឈមធ្ងន់ធ្ងរចំពោះភាពប្រកួតប្រជែង ផលិតភាព និងកំណើនតម្លៃបន្ថែមនៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ។ ភាពទន់ខ្សោយនៃប្រព័ន្ធទិន្នន័យនិងព័ត៌មានអំពីទីផ្សារ គឺជា

ឧបសគ្គបន្ថែមទៀតដែលរារាំងកម្លាំងពលកម្មនាពេលបច្ចុប្បន្ន និងទៅអនាគត ក៏ដូចជា គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលផងដែរ ពីការធ្វើសេចក្តីសម្រេចដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់ អំពីប្រភេទជំនាញ និងសមត្ថភាពដែលត្រូវស្វែងរកឲ្យបាន។

- ការចូលរួមយ៉ាងសកម្មនៃវិស័យឯកជននៅក្នុងការលើកកំពស់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការត្រួតពិនិត្យការបំពុល នៅតែត្រូវការឲ្យមានការពង្រឹងបន្ថែមទៀត។
- ការកាប់ឈើល្មើសច្បាប់ ភាពទន់ខ្សោយនៃការគ្រប់គ្រងដី ការរានធ្លារ/ការទន្ទ្រានយកដី និងភាពមិនច្បាស់លាស់នៃកម្មសិទ្ធិដីបន្តដាក់សម្ពាធមកលើព្រៃឈើ ជីវៈចម្រុះ និងរបរចិញ្ចឹមជីវិតដែលពឹងអាស្រ័យលើធនធានព្រៃឈើ។

## *អាទិភាពសម្រាប់ឆ្នាំ 2015*

- បន្តរួមចំណែកកែលម្អលទ្ធភាពរបស់គ្រួសារក្រីក្រជាងគេនៅជនបទ ដើម្បីទទួលបានសេវាមីក្រូហិរញ្ញប្បទាន។
- អ.ស.ប នឹងបន្តគាំទ្រដល់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពស្បៀង។ បន្តគាំទ្រដល់ក្រសួងផែនការដើម្បីបង្កើយការវិភាគ CDHS និងផ្សព្វផ្សាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ និងកសាងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាល (NIS/MoP) ដើម្បីត្រៀមខ្លួនសម្រាប់ជុំទី ៣ នៃ ជម្រឿនប្រជាជន និងលំនៅស្ថាន ដែលត្រូវធ្វើឡើងនៅឆ្នាំ 2018។ ផ្តល់ការបណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រសម្រាប់ការរៀបចំផែនការ និងការវិភាគស្ថិតិ ដល់ជនបង្គោលយេនឌ័រ នៅក្នុងមន្ទីរផែនការនៅថ្នាក់ក្រោមជាតិ។
- ការបន្តផលិត និងចេញផ្សាយរួមគ្នានូវព្រឹត្តិបត្រព័ត៌មានប្រចាំខែស្តីពីថ្លៃចំណីអាហារ និងប្រាក់ឈ្នួល ការពង្រឹងសមត្ថភាពបច្ចេកទេសនៅថ្នាក់ជាតិ។ រៀបចំ និងបោះពុម្ពផ្សាយរួមគ្នាជាមួយវិទ្យាស្ថានជាតិស្ថិតិជាបន្ថែមទៀតនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីសន្តិសុខស្បៀង។ បន្តរៀបចំបង្កើយ និងបោះពុម្ពផ្សាររបាយការណ៍ CLEAR រួមគ្នាជាមួយក្រសួងបរិស្ថាននៅឆ្នាំ 2015។
- អ.ស.ប នឹងគាំទ្រដល់ការគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលដោយនិរន្តរភាព តាមរយៈការពង្រឹងគណៈកម្មការសហគមន៍ស្រះជម្រកត្រី។ អ.ស.ប នឹងសម្រួលឲ្យមានការបន្សីុគ្នានៃកម្មវិធីសិក្សាសម្រាប់វេជ្ជសាស្ត្របសុសត្វ នៃមហាវិទ្យាល័យវិជ្ជសាស្ត្របសុសត្វ នៅសកលវិទ្យាល័យភូមិន្ទកសិកម្ម ជាមួយស្តង់ដារអន្តរជាតិ និងកសាងសមត្ថភាពបង្រៀនរបស់បុគ្គលិកមហាវិទ្យាល័យ។
- បន្តពង្រឹងសមត្ថភាពសម្រាប់នវានុវត្តន៍ និងពង្រីកវិធានការចម្រុះការពារដំណាំ(IPM) និងការបណ្តុះបណ្តាលអំពីការកាត់បន្ថយហានិភ័យនៃថ្នាំគីមីកសិកម្ម និងការអប់រំកសិករសម្រាប់បង្កើនប្រពលវប្បកម្មដំណាំដោយនិរន្តរភាព។
- បន្តកសាងភាពធន់របស់សហគមន៍ ចំពោះការប៉ះទង្គិចដែលទាក់ទងនឹងការប្រែប្រួលធាតុអាកាស និងការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតទ្រព្យសម្បត្តិសហគមន៍និងការបន្ស៊ាំរបរចិញ្ចឹមជីវិតរបស់គ្រួសារដែលងាយរងគ្រោះ។ គាំទ្រក្រសួង MAFF ក្នុងការពង្រីកផែនការសកម្មភាពជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងកសិកម្មទៅដល់វិស័យនានាដទៃទៀត ដែលរួមទាំង នៅថ្នាក់ខេត្តផងដែរ។
- ពង្រឹងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងការ គម្រាមកំហែង តាមរយៈការបន្ស៊ាំ និងការកាត់បន្ថយដោយបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ, ការតាមដាននិងវាយតម្លៃ( M&E), យុទ្ធសាស្ត្រ REDD+ និងក្របខ័ណ្ឌអនុវត្ត ព្រមទាំងប្រព័ន្ធប្រកាសផ្តល់ដំណឹងជាមុន។ បន្តកែបង្កើនលទ្ធភាពទទួលបានថាមពលស្អាត និងប្រសិទ្ធភាពថាមពល។ បន្តគាំទ្រក្រុមបច្ចេកទេសជាតិទទួលបន្ទុកវាស់ រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)/ កម្រិតបំភាយយោង (REL) និងក្រុមអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការបង្កើតប្រព័ន្ធតាមដានព្រៃឈើជាតិ (NFMS) និងគាំទ្រការរៀបចំកម្រិតបំភាយយោងសម្រាប់ព្រៃឈើ (FREL)។ កសាងសមត្ថភាពវិស័យព្រៃឈើសម្រាប់រៀបចំរបាយការណ៍ស្តីពីការបំភាយឧស្ម័នផ្ទះកញ្ចក់។
- បន្តពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើការឃ្លាំមើល អង្កេត និងត្រួតពិនិត្យជម្ងឺឆ្លងកាត់ព្រំដែនមកលើសត្វ ដែលរួមទាំង ជម្ងឺផ្តាសាយបក្សី និងដើម្បីពង្រឹងសមត្ថភាពជាតិខាងមន្ទីរពិសោធន៍ផងដែរ។

- រៀបចំបង្កើយគោលនយោបាយជាតិមុខរបរ រួមជាមួយផែនការសកម្មភាពដែលផ្តោតលើសកម្មភាពគោលនយោបាយដែលអាចអនុវត្តបានមួយចំនួនតូច និងការពង្រីកសេវាកម្មមុខរបរនិងការងារដល់ទីជនបទ។
- បន្តពង្រឹងគោលនយោបាយជាតិ តាមរយៈការបណ្តុះបណ្តាល និងបង្កើនការយល់ដឹង ដើម្បី៖ (1) សម្របសម្រួល និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានា សម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង (2) រៀបចំគោលនយោបាយ/យុទ្ធសាស្ត្រការងារនិងមុខរបរដែលគិតគូរអំពីយេនឌ័រ ដោយផ្តោតការយកចិត្តទុកដាក់លើយុវជន បុគ្គលិកវិស័យបម្រើការកំសាន្ត និងពលករចំណាកស្រុក។
- បន្តគាំទ្រដល់ការបង្កើនផលិតភាព និងការកែលម្អលក្ខខណ្ឌការងារ និងសុវត្ថិភាពក្នុងការងារ និងសុខភាពនៃសហគ្រាសខ្នាតតូច និងមធ្យម តាមរយៈកម្មវិធីកសាងសមត្ថភាព និងសេវាផ្តល់យោបល់ដោយចំណាយទាប ដែលពង្រឹងបណ្តាញសហគ្រាស ភាពប្រកួតប្រជែង និងសមត្ថភាពស្នូលខាងអាជីវកម្ម។
- បន្តគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីការពារពលករចំណាកស្រុកកម្ពុជា តាមរយៈសកម្មភាពមួយចំនួនដែលនឹងជួយដល់ការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានាកាន់តែមានប្រសិទ្ធភាព ដែលរួមទាំង ការបណ្តុះបណ្តាលគ្រូបង្គោលអំពីកម្មវិធីសិក្សាសម្រាប់ការណែនាំនៅមុនពេលចេញដំណើរ ការវិភាគយន្តការបណ្តឹង និងការកសាងសមត្ថភាពលើការដោះស្រាយទំនាស់ ការបង្កើតតារាងត្រួតពិនិត្យសម្រាប់អធិការកិច្ចពលករសម្រាប់ក្រុមហ៊ុនឯកជនជ្រើសរើសពលករ ក៏ដូចជា ការគាំទ្របច្ចេកទេសក្នុងការរៀបចំបង្កើយសេចក្តីព្រាងប្រកាសស្តីពីការប្រើប្រាស់ប្រាក់តំកល់សម្រាប់ការធានាផងដែរ។
- បន្តគាំទ្រដល់ក្រសួងផែនការ នៅក្នុងការអង្កេតជាបន្តលើគម្រោងចំណាកស្រុករវាងជនបទ-ទីក្រុងនៅកម្ពុជា (CRUMP) ដើម្បីបានយល់ដឹងកាន់តែច្បាស់អំពីកស្តុតាងនៃទម្រង់ចំណាកស្រុកថ្មីៗរបស់ប្រជាជននៅកម្ពុជា។

### *វិស័យលទ្ធផល 1 ការចំណាយសម្រាប់ឆ្នាំ 2014 – 2015:*

- តួលេខចំណាយប៉ាន់ស្មានសម្រាប់ឆ្នាំ **2014: 28.096.145** ដុល្លាអាមេរិក
- តួលេខគ្រោងចំណាយសម្រាប់ឆ្នាំ **2015: 27.226.831** ដុល្លាអាមេរិក

# ការវិភាគបរិមាណ - សូចនាករសម្រាប់តាមដានក្នុងឆ្នាំ 2014

| ល.រ | សូចនាករ | ស្ថានភាព | តួលេខគោល | ឆ្នាំ 2014 | យោបល់ | គ្រោងសម្រាប់ឆ្នាំ 2015 |
|---|---|---|---|---|---|---|
| 1.1 | អត្រាកំណើនផ.ស.ស ប្រចាំឆ្នាំ (ភាគរយ) | គ្រោង | | | | 8 |
| | | ជាក់ស្តែង | 6,8 | 7,2 | | |
| 1.2 | អត្រាកំណើនការនាំចេញ (ភាគរយ) | គ្រោង | | | | 18 |
| | | ជាក់ស្តែង | 16,3 | 11,4 | | |
| 1.5 | ពិន្ទុរបបអាហារតាមគ្រួសារ (ភាគរយ) | គ្រោង | | | | 11 |
| | | ជាក់ស្តែង | 6 | N/A | ពុំទាន់មាននៅ NIS ទេ ទើបបង្កើយការប្រមូលទិន្នន័យសម្រាប់ CSES 2014 ហើយការបញ្ចូលទិន្នន័យនឹងបន្តដល់ខែកុម្ភៈ-មីនា | |
| 1.6 | អត្រាកំណើននៃវិស័យកសិកម្ម (ភាគរយ) | គ្រោង | | | | 5,5 |
| | | ជាក់ស្តែង | 5,4 | N/A | មានតែ 4% ដែលបង្ហាញក្នុងNSDP 2014-2018 | |
| 1.7 | អត្រាកំណើនវិស័យកសិកម្មក្រៅពី ស្រូវ (ភាគរយ) | គ្រោង | | | | 5 |
| | | ជាក់ស្តែង | 2,67 | N/A | | |
| 1.8 | ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនប្រពលវប្បកម្មផលិតកម្មដំណាំដោយនិរន្តរភាពនិងពិពិធកម្ម ដែលរៀបចំឡើងជាមួយផែនការការងារប្រចាំឆ្នាំដោយគណនាថ្លៃចំណាយ | គ្រោង | | ផែនការកំណត់ថ្លៃប្រចាំឆ្នាំ | | |
| | | ជាក់ស្តែង | 0 | N/A | យោងតាមសេចក្តីព្រាងASDP 2014-2018, ផែនការឆ្នាំ 2014 គឺ 7,8លានដុល្លា ចំណែកឆ្នាំ 2015 គឺ 11,4 លានដុល្លា | |
| 1.9 | ចំនួនប្រជាជនដែលប្រើប្រាស់សេវាកម្មផ្សព្វផ្សាយ ដែលរួមទាំង សាលាស្រែកសិករ ការបណ្តុះបណ្តាល និងសេវាកម្មសម្រាប់សហគមន៍ដែលពឹងផ្អែកលើកសិកម្ម ជលផល និងព្រៃឈើ ដែលរួមទាំង ការប្រើប្រាស់ថ្នាំគីមីកសិកម្មប្រកបដោយការទទួលខុសត្រូវ (ចំនួន, ស្ត្រី) | គ្រោង | | | | 13500 |
| | | ជាក់ស្តែង | 7487 | 18949 | | |

| | | | | | | |
|---|---|---|---|---|---|---|
| 1.9 | ចំនួនប្រជាជនដែលប្រើប្រាស់សេវាកម្មផ្សព្វផ្សាយ ដែលរួមទាំង សាលាស្រែកសិករ ការបណ្តុះបណ្តាល និងសេវាកម្ម សម្រាប់សហគមន៍ដែលពឹងផ្អែកលើកសិកម្ម ជលផល និងព្រៃឈើ ដែលរួមទាំង ការប្រើប្រាស់ថ្នាំគីមីកសិកម្មប្រកបដោយការទទួលខុសត្រូវ (ចំនួន, បុរស) | គ្រោង | | | | 16500 |
| | | ជាក់ស្តែង | 11231 | 51438 | | |
| 1.9 | ចំនួនប្រជាជនដែលប្រើប្រាស់សេវាកម្មផ្សព្វផ្សាយ ដែលរួមទាំង សាលាស្រែកសិករ ការបណ្តុះបណ្តាល និងសេវាកម្មសម្រាប់សហគមន៍ដែលពឹងផ្អែកលើកសិកម្ម ជលផល និងព្រៃឈើ ដែលរួមទាំង ការប្រើប្រាស់ថ្នាំគីមីកសិកម្មប្រកបដោយការទទួលខុសត្រូវ (ចំនួន) | គ្រោង | | | | 30000 |
| | | ជាក់ស្តែង | 18718 | 70087 | | |
| 1.15 | ភាគរយនៃបុរស និងស្ត្រីដែលងាយរងគ្រោះបំផុតពីអសន្តិសុខស្បៀង ដែលបានទទួលការគាំទ្រតាមរយៈការផ្តល់ពូជ ជី ឧបករណ៍ និងសេវាកម្មផ្សព្វផ្សាយ (ភាគរយ, បុរស) | គ្រោង | | | | 35 |
| | | ជាក់ស្តែង | | 9271 | តួលេខឆ្លុះបញ្ចាំងអំពីគ្រួសារ ឬអ្នកចូលរួម ប៉ុន្តែលំបាកបម្លែងតួលេខនេះទៅជាភាគរយ | |
| 1.15 | ភាគរយនៃបុរស និងស្ត្រីដែលងាយរងគ្រោះបំផុតពីអសន្តិសុខស្បៀង ដែលបានទទួលការគាំទ្រតាមរយៈការផ្តល់ពូជ ជី ឧបករណ៍ និងសេវាកម្មផ្សព្វផ្សាយ (ភាគរយ, ស្ត្រី) | គ្រោង | | | | 35 |
| | | ជាក់ស្តែង | | 2229 | តួលេខឆ្លុះបញ្ចាំងអំពីគ្រួសារ ឬអ្នកចូលរួម ប៉ុន្តែលំបាកបម្លែងតួលេខនេះទៅជាភាគរយ | |
| 1.15 | ភាគរយនៃបុរស និងស្ត្រីដែលងាយរងគ្រោះបំផុតពីអសន្តិសុខស្បៀង ដែលបានទទួលការគាំទ្រតាមរយៈការផ្តល់ពូជ ជី ឧបករណ៍ និងសេវាកម្មផ្សព្វផ្សាយ (ភាគរយ) | គ្រោង | | | | 35 |
| | | ជាក់ស្តែង | | 11500 | តួលេខឆ្លុះបញ្ចាំងអំពីគ្រួសារ ឬអ្នកចូលរួម ប៉ុន្តែលំបាកបម្លែងតួលេខនេះទៅជាភាគរយ | |
| 1.18 | ភាគរយនៃខេត្ត ដែលរាយការណ៍ជាប្រចាំនូវទិន្នន័យកសិកម្ម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មកថ្នាក់ជាតិទាន់ពេលវេលា (ភាគរយ) | គ្រោង | | 70 | | 80 |
| | | ជាក់ស្តែង | | 90% | របាយការណ៍រដ្ឋបាលទៀងទាត់ពី ថ្នាក់ខេត្ត មកថ្នាក់ជាតិ | |
| 1.17 | ប្រព័ន្ធព័ត៌មានប្រតិបត្តិការ (ដែលផ្សារភ្ជាប់ថ្នាក់ខេត្ត មកថ្នាក់ជាតិ) ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរួមទាំង ប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុន | គ្រោង | | ប្រតិបត្តិការ | | បានបង្កើតប្រព័ន្ធប្រកាសផ្តល់ព័ត៌មានជាមុន |

| | | | | | | |
|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ពុំទាន់មានប្រព័ន្ធនៅឡើយទេ | 4 | បានផលិតនិងផ្សព្វផ្សាយ 3 លេខរួចមកហើយ។ លេខចុងក្រោយ (តុលា-ធ្នូ) កំពុងរៀបចំ និងគ្រោងបង្ហើយនៅចុងខែមករា | |
| 1.20 | ភាពខុសគ្នានៃការបំភាយ CO2 នៅកម្រិតជាតិ ដោយសារការប្រើប្រាស់ចង្ក្រានចំអិនអាហារប្រសិទ្ធភាពថាមពល | គ្រោង | | | | 400000 |
| | | ជាក់ស្តែង | ប្រហែល50,000tCO2e ក្នុងមួយឆ្នាំ | | | |
| 1.22 | គោលការណ៍ណែនាំត្រូវបានរៀបចំសម្រាប់ទីតាំងសហគមន៍ឥណទានកាបូនដែលទាក់ទងនឹងព្រៃឈើ ដែលផ្អែកលើអន្តរាគមន៍គំរូ | គ្រោង | | 1 | គោលការណ៍ណែនាំត្រូវបានរៀបចំនៅឆ្នាំ 2014 | 1 |
| | | ជាក់ស្តែង | 0 | | | |
| 1.24 | ចំនួនសហគមន៍ព្រៃឈើទូទាំងប្រទេសដែលមានផែនការគ្រប់គ្រង (ចំនួន) | គ្រោង | | 50 | | 50 |
| | | ជាក់ស្តែង | 4 | 50 | | |
| 1.24 | ចំនួនសហគមន៍ព្រៃឈើទូទាំងប្រទេសដែលមានផែនការគ្រប់គ្រង | គ្រោង | | | | |
| | | ជាក់ស្តែង | | 30 | | |
| 1.29 | ចំនួនផែនការនិងយុទ្ធសាស្រ្តជាតិនិងតាមវិស័យដែលយោងជាក់លាក់ទៅការប្រែប្រួលអាកាសធាតុ (ចំនួន) | គ្រោង | | 19 | ជាមួយបណ្តាឆ្នាំកន្លងទៅ | 19 |
| | | ជាក់ស្តែង | | 9 | | |
| 1.29 | ចំនួនផែនការនិងយុទ្ធសាស្រ្តជាតិនិងតាមវិស័យដែលយោងជាក់លាក់ទៅការប្រែប្រួលអាកាសធាតុ (ចំនួន) | គ្រោង | | | | 19 |
| | | ជាក់ស្តែង | 0 | 9 | | |
| 1.28 | ផែនការយុទ្ធសាស្រ្តជាតិប្រែប្រួលអាកាសធាតុ ដែលមានផែនការការងារប្រចាំឆ្នាំដែលកំណត់ថ្លៃចំណាយ | គ្រោង | | ផែនការការងារកំណត់ថ្លៃចំណាយ | | 1 |
| | | ជាក់ស្តែង | 0 | | | |
| 1.30 | ផែនការយុទ្ធសាស្រ្តត្រៀមលក្ខណៈសម្រាប់ REDD ត្រូវបានរៀបចំជាមួយផែនការការងារប្រចាំឆ្នាំដែលកំណត់ថ្លៃចំណាយ | គ្រោង | | ផែនការការងារកំណត់ថ្លៃចំណាយ | | 1 |
| | | ជាក់ស្តែង | 0 | សេចក្តីព្រាងដំបូងនៃយុទ្ធសាស្រ្ត REDD+ជាតិកម្ពុជាត្រូវបានរៀបចំ | | |
| 1.34 | ផែនការយុទ្ធសាស្រ្តត្រៀមលក្ខណៈសម្រាប់ REDD ត្រូវបានរៀបចំជាមួយ | គ្រោង | | 1 | ផែនការប្រចាំឆ្នាំ មានកំណត់ថ្លៃចំណាយ | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| | ផែនការការងារប្រចាំឆ្នាំដែលកំណត់ថ្លៃចំណាយ | ជាក់ស្តែង | 0 | សេចក្តីព្រាងដំបូងនៃយុទ្ធសាស្ត្រ REDD+ជាតិកម្ពុជាត្រូវបានរៀបចំ | | |
| 1.36 | មានយុទ្ធសាស្ត្រជាតិកាត់បន្ថយអាកាសធាតុនិងផែនការសកម្មភាព ជាមួយការអនុវត្តផែនការការងារប្រចាំឆ្នាំ | គ្រោង | | 1 | ផែនការប្រចាំឆ្នាំមានថ្លៃចំណាយ | 1 |
| | | ជាក់ស្តែង | 0 | បានអនុម័តក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ | | |
| 1.37 | ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចក្នុងបណ្តាខេត្តជាក់លាក់ | គ្រោង | | | | |
| | | ជាក់ស្តែង | | | | |
| 1.38 | ចំនួនការអង្កេតគុណភាពនិងបរិមាណដែលបានអនុវត្តដើម្បីកំណត់អត្តសញ្ញាណ សក្តានុពលសម្រាប់ពិពិធកម្មការអភិវឌ្ឍនៅមូលដ្ឋាននិងសេដ្ឋកិច្ចទាំងនៅតាមជនបទនិងទីក្រុង (ចំនួន) | គ្រោង | | 5 | ការអង្កេតឆ្នាំ 2014 - 5 ត្រូវបានអនុវត្ត | 5 |
| | | ជាក់ស្តែង | 0 | | | |
| 1.44 | ភាគរយនៃចំណុចដៅផែនការការងារប្រចាំឆ្នាំអភិក្រមទូទាំងវិស័យពាណិជ្ជកម្ម (Trade SWAPs) ដែលបានអនុវត្តតាមពេលកំណត់ (ភាគរយ) | គ្រោង | | 80 | 80% លទ្ធផលសម្រេចបានក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ 2011 | 80 |
| | | ជាក់ស្តែង | N/A | | UNDP រៀបចំផែនការដើម្បីគាំទ្រMOC ដើម្បីបម្លែងផែនទីបង្ហាញផ្លូវ Trade SWAPs ឲ្យទៅជាផែនការអនុវត្តជាក់ស្តែងសម្រាប់ក្រសួងពាក់ព័ន្ធនីមួយៗ។ ផែនការពាក់កណ្តាលអាណត្តិជាមួយការរំពឹងក្នុងការផលិតនៅឆ្នាំ 2015 | |
| 1.45 | ចំនួនលើកក្នុងមួយឆ្នាំដែលអនុគណៈកម្មាធិការអភិវឌ្ឍពាណិជ្ជកម្ម និងការវិនិយោគ ដែលទាក់ទងនឹងពាណិជ្ជកម្មបានកោះប្រជុំ (ចំនួន) | គ្រោង | | 2 | យ៉ាងហោចណាស់ 2 ដងក្នុងមួយឆ្នាំចាប់ពីឆ្នាំ2011 | 2 |
| | | ជាក់ស្តែង | 2 | 2 | | |
| 1.56 | កម្រងទិន្នន័យត្រូវបានរៀបចំ និងធ្វើបច្ចុ | គ្រោង | | 3 | ធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ | 4 |

| | | | | | | |
|---|---|---|---|---|---|---|
| | ប្បន្នភាពរៀងរាល់ពីរឆ្នាំម្តង ជាមួយសារពើភ័ណ្ឌ និងសំណុំលក្ខណៈនៃសេវាកម្មអភិវឌ្ឍន៍អាជីវកម្ម (ចំនួន) | ជាក់ស្តែង | 0 | 2 | | |
| 1.59 | ភាគរយនៃអ្នកទទួលផលដែលបានប្រើប្រាស់ប្រព័ន្ធណាមួយ ដែលបានទទួលការងារ (ការងារផ្តល់កម្រៃ ឬ ការងារផ្ទាល់ខ្លួន) ក្នុងរយៈពេល 6 ខែក្រោយបញ្ចប់ (ភាគរយ) | គ្រោង | | 70 | | 70 |
| | | ជាក់ស្តែង | | 23 | ភាគរយនៃអ្នកទទួលផលដែលបានទទួលការងារក្នុងរយៈពេល6 ខែក្រោយប្រើប្រាស់សេវា NEA | |
| 1.60 | ភាគរយនៃចំនួនសហគ្រាសខ្នាតមធ្យមនិងធំ(SMEs) អង្គភាពរដ្ឋាភិបាលនិងCSOs ដែលបានឯកភាពផ្តល់តំណែងការងារជាមួយលក្ខខណ្ឌការងារសមរម្យ (ភាគរយ) | គ្រោង | | 30 | 30% នៃ SMEs បានចុះហត្ថលេខា ជាមួយ NEA | 30 |
| | | ជាក់ស្តែង | 0 | 14&53 | 14 ភាគរយ(ឬ7.430សហគ្រាស) នៃSMEsទាំងអស់ (53.417 សហគ្រាស) ដែលមានកម្មកររវាង 5 និង1.000 នាក់ ឬ 53% នៃសហគ្រាសដែលមានកម្មកររវាង 10 និង 1.000 នាក់។ | |
| 1.61 | ចំនួនវិធានការដែលត្រូវផ្តល់សិទ្ធិ និងការទទួលស្គាល់សម្រាប់បង្រៀនកូនជាង កម្មសិក្សាការី និងអ្នកស្ម័គ្រចិត្ត (ចំនួន) | គ្រោង | | | | 3 |
| | | ជាក់ស្តែង | 0 | 2 | ឧស្សាហកម្មចំនួន 2 ដូចជា ទេសចរណ៍ ជាមួយការទទួលស្គាល់នៅទូទាំងឧស្សាហកម្មក្នុងអាស៊ាន& សំណង់ដែលមានកិច្ចការចំនួន(ជាងកំបោរ & រាយខ្សែភ្លើង)ជាមួយថៃ។ | |

ក្នុងករណីខ្លះ លក្ខខណ្ឌគោល និងចំណុចដៅ ពុំទាន់បានកំណត់នៅឡើយទេ ។

# លទ្ធផលទី ២ – សុខភាព និងការអប់រំ

ត្រឹមឆ្នាំ ២០១៥ បុរស ស្ត្រី កុមារ និងពលរដ្ឋវ័យក្មេងកាន់តែច្រើនឡើង នឹងទទួលបានសេវាសុខភាពនិងការអប់រំប្រកបដោយសមធម៌។

## *សេចក្តីផ្តើម*

ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាផ្នែកសុខភាពនិងការអប់រំ អង្គការសហប្រជាជាតិ (អ.ស.ប) បាននិងកំពុងធ្វើការងារដើម្បីលើកកម្ពស់ការទទួលបានប្រកបដោយសមធម៌មនូវសេវានានាដោយផ្តោតលើៈ គុណភាពសុខភាពបន្តពូជ សុខភាពមាតា-ទារកនិងកុមារ រួមទាំង សេវាផែនការគ្រួសារនិងអាហារូបត្ថម្ភ ការឆ្លើយតបទៅនឹងជម្ងឺអេដស៍ កំណើនការទទួលបានទឹកស្អាតនិងអនាម័យនិងការរស់នៅស្អាត ការពង្រីកការគ្របដណ្តប់និងនិរន្តរភាពនៃការសិក្សារបស់កុមារតូច និងគុណភាពនៃការអប់រំមូលដ្ឋាន និង ការពង្រីកលទ្ធភាពរបស់យុវវ័យក្នុងការទទួលបានបំណិនជីវិត ដែលរួមទាំងការយល់ដឹងអំពីជម្ងឺអេដស៍ និងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។

## *លទ្ធផលឆ្នាំ 2014*

### សុខភាពមាតា និងកុមារ ៖

កម្ពុជាទទួលបានវឌ្ឍនភាពគួរឲ្យកត់សំគាល់ នឹងឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (CMDGs) 4, 5 និង 6។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ 2014 អត្រាមរណភាពមាតា(MMR)នៅតែខ្ពស់ក្នុងកម្រិត 170នាក់ ស្លាប់ក្នុងកំណើតរស់ 100.000នាក់[1] ប៉ុន្តែអត្រាស្លាប់នៃទារកទើបកើតមិនបានផ្លាស់ប្តូរឡើយ 27 នាក់ស្លាប់ក្នុងកំណើតរស់ 1.000នាក់ ដែលត្រូវជាពាក់កណ្តាលនៃមរណភាពកុមារអាយុក្រោមប្រាំឆ្នាំ[2]។ លើសពីនេះ កុមារក្នុងចំណោមក្រុមគ្រួសារក្រីក្រជាងគេ មានភាវនីយភាពនៃការបាត់បង់ជីវិតខ្ពស់ជាងបីដងនៃកុមារក្នុងក្រុមគ្រួសារដែលមានជីវភាពប្រសើរ។ បញ្ហាទាំងនេះពាក់ព័ន្ធជាមួយការគ្របដណ្តប់សេវាថែទាំសុខភាពសំខាន់ៗនៅមានកម្រិតទាបសម្រាប់មាតា ទារក និងកុមារ ជាពិសេស ក្នុងបណ្តាខេត្តដាច់ស្រយាល និងមានប្រជាជនរស់នៅដាច់ពីគ្នា ដូចជា ក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី។

នៅឆ្នាំ 2014 អ.ស.ប បានផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ដែលនាំឲ្យមានការរៀបចំ និងការអនុវត្តគោលការណ៍ណែនាំថ្មីៗរបស់ជាតិស្តីពីការផ្សព្វផ្សាយពេញលេញដើម្បីលុបបំបាត់តេតាណូសលើមាតានិងទារក ការថែទាំចម្រុះសម្រាប់មាតាក្រោយសម្រាលកូន - ការថែទាំមាតា និងទារកនៅតាមសហគមន៍ ការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរឥរិយាបថ និងការគ្រប់គ្រងសមាហរណកម្មជម្ងឺនានាលើកុមារ។ លទ្ធផលនេះបានបំពេញបន្ថែមដោយការអនុវត្តវិធីសាស្ត្រសមធម៌ដែលផ្តោតលើស្រុកប្រតិបត្តិចំនួនដប់ដែលមានប្រាក់ចំណូលទាប ដែលនាំឲ្យមាតា និងទារកចំនួនប្រមាណ 88.648 នាក់ ក្នុងចំណោមក្រុមដែលខ្វះខាតបំផុតបានទទួលសេវាទាំងនេះ ដូចជា ភាគរយនៃស្ត្រីដែលបានមកពិនិត្យផ្ទៃពោះចំនួនបួនលើក ឬ ច្រើនជាងនេះ បានកើនឡើងពី 23% នៅឆ្នាំ 2013 ដល់ 39% នៅក្នុងអំឡុងត្រីមាសទីបី នៃឆ្នាំ 2014។

តាមរយៈការបណ្តុះបណ្តាលឆ្មប រួមជាមួយអន្តរាគមន៍របស់ពួកគេ ក្នុងការអនុវត្តផែនការធ្វើឱ្យប្រសើរឡើងសេ

[1] ប៉ាន់ស្មានដោយ WHO, UNICEF, UNFPA, ធនាគារពិភពលោក, និងផ្នែកប្រជាជននៃអ.ស.បៈ និន្នាការនៃមរណភាពមាតាៈ ឆ្នាំ 1990 to 2013

[2] DHS 2010

វាសង្គ្រោះបន្ទាន់និងថែទាំទារក (EmONC) និងសកម្មភាពផ្សព្វផ្សាយដទៃទៀត ដែលគាំទ្រដោយអ.ស.ប នៅឆ្នាំ 2014 មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកទាំងអស់ (HCsនិងRHs) បានផ្តល់កញ្ចប់សេវាសុខភាពសម្រាប់មាតា ទារក និងកុមារ។

សមាមាត្រនៃការផ្តល់សេវា ដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ ក៏បានកើនឡើងផងដែរ និងត្រូវបានប៉ាន់ស្មានថានឹងឈានដល់ចំណុចដៅ (85%) នៅឆ្នាំ 2015។ ទោះជាយ៉ាងណាក៏ដោយ អត្រាទាបនៃសេវាគ្របដណ្តប់ដោយ បុគ្គលិកជំនាញនៅក្នុងពេលសម្រាលកូន ត្រូវបានរាយការណ៍ថាមាននៅក្នុងខេត្តក្រចេះ (19%) បានលុង (39%) និង សែនមនោរម្យ (48%) ដោយសារតែសេវាកម្មផ្សព្វផ្សាយ ផ្តោតភាគច្រើនតែលើសេវាថែទាំស្ត្រីមានផ្ទៃពោះ (ANC) និងក្រោយពេលសម្រាលកូន (PNC) ដោយមិនបានរួមបញ្ចូលសេវានៃការសម្រាលកូន ដោយសារកង្វះឆ្មបដែលបានទទួលការហ្វឹកហាត់។

បន្ទាប់ពីការតស៊ូមតិដោយជោគជ័យពីសំណាក់អ.ស.ប ក្រសួងសុខាភិបាលបានរៀបចំសន្និសីទជាតិលើកទីមួយស្តីពីការកសាងផែនការគ្រួសារ កាលពីខែវិច្ឆិកា ឆ្នាំ 2014 ដោយមានការចូលរួមពីសិក្ខាកាមចំនួន 250 នាក់។ សន្និសីទនេះ រៀបចំឡើងដោយមានការគាំទ្ររួមគ្នាពីដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ជាលទ្ធផល នាំអោយមានការប្តេជ្ញាចិត្តរួមគ្នាអំពីការគាំទ្ររបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ចំពោះការកសាងផែនការគ្រួសារដែលឆ្លើយតបនឹងតម្រូវការខាងយេនឌ័រលើសិទ្ធិជាមូលដ្ឋាននៅកម្ពុជា។ អ.ស.ប បានគាំទ្រក្រសួងសុខាភិបាល ដើម្បីធានាឲ្យមានវត្តមានវិធីពន្យាកំណើតទំនើបនៅក្នុងគ្រប់មណ្ឌលសុខភាព ក្នុងខេត្តនីមួយៗទូទាំងប្រទេសកម្ពុជា ដែលរួមទាំង ការដាក់ឲ្យអនុវត្ត និងការពង្រីកវិធីពន្យាកំណើតសម្រាប់ករណីបន្ទាន់នៅក្នុងប្រព័ន្ធសុខាភិបាល និងបុគ្គលិកក្នុងស្ទើរតែគ្រប់មណ្ឌលសុខភាព។ ស្ទើរតែគ្រប់បុគ្គលិកHCsនិងRHs ទទួលការបណ្តុះបណ្តាល និងការផ្តល់សេវាពន្យាកំណើតសម្រាប់ករណីបន្ទាន់។ នៅឆ្នាំ 2014 មណ្ឌលសុខភាពទាំងអស់ចំនួន 1.094 និងមន្ទីរពេទ្យបង្អែកចំនួន 43 ផ្តល់យ៉ាងហោចណាស់វិធីទំនើបចំនួនបី ដែលរួមទាំង សេវាកម្មដាក់កងក្នុងស្បូន (IUD) (962) និងសេវាដាក់កងនៅដើមដៃ (527)។ ខ្ទង់ថវិកាជាតិសម្រាប់វិភាគទានដំបូងដល់ប្រព័ន្ធលទ្ធកម្មឧបករណ៍ពន្យាកំណើត ត្រូវបានរៀបចំឡើង ហើយរដ្ឋាភិបាលបានសន្យាបង្កើនវិភាគទានលើខ្ទង់ថវិកានេះទ្វេដងផងដែរនៅក្នុងឆ្នាំ 2015។

មជ្ឈមណ្ឌលសល្យសាស្ត្រកុមារ (CSC) បានទទួលការគាំទ្រជាលើកដំបូង ដើម្បីអនុវត្តយុទ្ធនាការព័ត៌មាន និងការផ្សព្វផ្សាយដល់សហគមន៍ ដើម្បីកំណត់រកករណីបញ្ហាដាច់សន្ទះរវាងទ្វារធំនិងយោនី (obstetric fistula) ក្នុងតំបន់ដាច់ស្រយាលនិងក្រីក្រទូទាំងប្រទេស។

វឌ្ឍនភាពត្រូវបានកត់ត្រា អំពីវិសាលភាពគ្របដណ្តប់នៃការផ្តល់ថ្នាំបង្ការ (៨៣%នៃថ្នាក់បង្ការរោគប្រាំមុខ-3, ៨៤%សម្រាប់ការផ្តល់ថ្នាំតំណាក់បង្ការរោគស្វិតអវៈយវៈ, ៧៧%សម្រាប់ថ្នាំបង្ការរោគកញ្ជ្រិល) ប៉ុន្តែសេវាកម្មទាំងនេះនៅតែជាឧបសគ្គនៅឡើយសម្រាប់សហគមន៍ដាច់ស្រយាល ដែលកុមារប្រមាណ២០% មិនបានទទួលថ្នាំបង្ការជាមូលដ្ឋានទាំងអស់នេះឡើយ។ ការគាំទ្រត្រូវបានផ្តល់ដើម្បីសម្រួលឲ្យមានយុទ្ធនាការផ្តល់ថ្នាំបង្ការបន្ថែមចំនួនបីលើកនៅតាមភូមិនានាដែលបានរកឃើញថាមានហានិភ័យខ្ពស់នៅទូទាំងប្រទេស ក្នុងឆ្នាំ២០១៤ ក៏ដូចជា ដើម្បីពង្រឹងប្រព័ន្ធឃ្លាំមើលជម្ងឺដែលអាចទប់ស្កាត់បានតាមរយៈការផ្តល់ថ្នាំបង្ការ។

ផ្នែកបរិយាកាសអំណោយផល សមិទ្ធផលសម្រេចបានគួរឲ្យកត់សំគាល់ មានជាអាទិ៍ ការបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ទារក នីតិវិធីសម្រាលកូនដោយសុវត្ថិភាពសម្រាប់មន្ទីរពេទ្យបង្អែកនៅចុងឆ្នាំ២០១៣ និងនីតិវិធីសវនកម្មមរណភាពមាតា នៅដើមឆ្នាំ២០១៤។ ក្របខ័ណ្ឌសមត្ថភាពស្នូលសម្រាប់ឆ្មប ត្រូវបានប្រកាសរួមគ្នាដោយក្រុមប្រឹក្សាឆ្មបកម្ពុជា (CMC) និងក្រសួងសុខាភិបាល នៅឆ្នាំ 2014 និងត្រូវបានប្រើប្រាស់ ដើម្បីរៀបចំជាបឋមនូវលិខិ

តួបករណ៍វាយតម្លៃសមត្ថភាពអំពីកម្មវិធីបណ្តុះបណ្តាលឆ្មប សម្រាប់ទាំងគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ និងឯកជន។ ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុត្រូវបានផ្តល់ឲ្យក្រសួងសុខាភិបាល ដើម្បីរៀបចំគោលការណ៍ណែនាំដំបូងបង្អស់របស់ជាតិសម្រាប់ការគ្រប់គ្រងអំពើហឹង្សាមកលើស្ត្រី និងកុមារ (VAW/C) ដែលបច្ចុប្បន្នកំពុងរង់ចាំការអនុម័តគាំទ្រពីក្រសួងសុខាភិបាល។

**អាហារូបត្ថម្ភ ៖**

ការគាំទ្ររបស់អ.ស.ប ផ្តោតជាសំខាន់លើការថែទាំនៅតាមសម្បទាសុខភាពនានា ដល់អ្នកដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ និងស្រួចស្រាល់ (SAM) ការផ្តល់មីក្រូសារជាតុបន្ថែម (ចំណុចដៅ៖20ភាគរយ) និងបង្កើនការយល់ដឹងអំពីទម្លាប់ល្អក្នុងការផ្តល់ចំណីអាហារ។ ជាលទ្ធផលកុមារដែលមានបញ្ហា SAM ទទួលបានការព្យាបាលកាន់តែច្រើន ព្រមទាំងអត្រាខ្ពស់នៃការព្យាបាលបានជោគជ័យ តាមរយៈប្រព័ន្ធត្រួតពិនិត្យតាមដានជាប់លាប់ (អត្រាព្យាបាលកម្រិត ៦០%, ៧៥% និង ៨៥% តាមរយៈការព្យាបាលលើកទី១ដល់លើកទីបីបន្តគ្នា)។

នៅក្នុងកិច្ចប្រឹងប្រែងដើម្បីទប់ស្កាត់ជម្ងឺក្រិន និងកង្វះមីក្រូសារជាតិ អ.ស.ប ក្រោមភាពជាដៃគូជាមួយ NGOs បានផ្តល់ប្រចាំខែនូវអាហារដែលមានសារជាតិពិសេស ដល់កុមារប្រមាណ 15.000 នាក់នៅក្រោមអាយុពីរឆ្នាំ និងស្ត្រីមានផ្ទៃពោះ និងបំបៅដោះកូន នៅក្នុងខេត្តចំនួនពីរ រួមជាមួយការបំពេញបន្ថែមដោយការអប់រំអំពីសុខភាព និងអាហារូបត្ថម្ភ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈ។ ដើម្បីផ្តល់ឱកាសសម្រាប់ការបង្កើតគំរូប្រកបដោយនិរន្តរភាពដែលប្រើប្រាស់ផលិតផលអាហារផ្សំស្រេចដែលផលិតក្នុងស្រុកសម្រាប់ផ្តល់សារជាតិបន្ថែម ការផ្តល់អាហារដែលមានសារជាតិពិសេសត្រូវបានផ្អាកនៅខែមិថុនាឆ្នាំ 2014។

កម្មវិធីផ្តល់អាហារដល់សិស្សសាលាដែលគាំទ្រដោយអ.ស.ប បានបន្តកែលម្អភាពចម្រុះនៃរបបអាហារតាមរយៈការផ្តល់ផលិតផលអាហារព្យាបាល(ប្រេងរុក្ខជាតិ និងអំបិលអ៊ីយ៉ូដ) និងការកៀគរសហគមន៍ដើម្បីផ្តល់អាហារបំពេញបន្ថែមពីច្បារដំណាំតាមផ្ទះ។ លើសពីនេះ អ.ស.បបានបន្តរិះរកជម្រើសនានាដើម្បីបន្ថែមអាហារព្យាបាលទៅក្នុងរបបអាហារ ដើម្បីធានាឲ្យមានការផ្តល់ម្សៅមីក្រូសារជាតិសំខាន់ៗកាន់តែច្រើនថែមទៀត ហើយកិច្ចការនេះនឹងត្រូវបន្តនៅក្នុងឆ្នាំ 2015។

តាមរយៈការគាំទ្រក្នុងការបង្កើតក្រុមប្រឹក្សាត្រួតពិនិត្យ ក្រុមការងារ និងការបង្កើតលក្ខខណ្ឌប្រតិបត្តិ និងគោលការណ៍ណែនាំ សមត្ថភាពរបស់ក្រសួងសុខាភិបាលត្រូវបានពង្រឹង សម្រាប់ការអនុវត្តអនុក្រឹត្យលេខ 133 និងបានពង្រឹងការអនុវត្តប្រកាសរួមលេខ 061 ស្តីពីការលក់ផលិតផលសម្រាប់កុមារ និងការផ្តល់អាហារដល់កុមារតូច។ ការរៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ 2014-2018 និងផែនទីបង្ហាញផ្លូវថ្នាក់ជាតិសម្រាប់ការបង្កើនប្រសិទ្ធភាពឆាប់រហ័សដើម្បីបង្កើនអាហារូបត្ថម្ភឆ្នាំ 2014-2020 ក៏បានទទួលការគាំទ្រផងដែរ។

**មេរោគអេដស៍ និងជម្ងឺអេដស៍ ៖**

ផែនការយុទ្ធសាស្ត្រជាតិវិស័យសុខភាពសម្រាប់ត្រួតពិនិត្យមេរោគអេដស៍ និងជម្ងឺកាមរោគ (2015-2020) យុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់(2015-2020) និងគោលការណ៍ណែនាំស្តីពីការទប់ស្កាត់ ការផ្តល់សេវានិងការគ្រប់គ្រង ត្រូវបានរៀបចំរួចស្រេច ដោយផ្អែកលើការពិនិត្យឡើងវិញនៅឆ្នាំ 2013 ។ អំពីការឆ្លើយតបនៃវិស័យសុខភាពរបស់កម្ពុជា ហើយការងារបង្កើតម៉ូដែលអំពីការឆ្លងជម្ងឺអេដស៍ ត្រូវបានធ្វើបច្ចុប្បន្នភាព ដោយប្រើប្រាស់ទិន្នន័យនិងព័ត៌មានដែលមានថ្មីៗបំផុត ស្តីពីថ្លៃកញ្ចប់អន្តរាគមន៍ក្នុងមួយឯកត្តា និងប្រសិទ្ធភាពនៃកម្មវិធី។ កិច្ចការនេះផ្តល់ជាការយល់ដឹងស៊ីជម្រៅ និងទូទៅ អំពីការវិវត្តនៃករណីឆ្លងមេរោគអេដស៍នៅក្នុងប្រទេស តាមរយៈស្ថានភាពដោយឡែក

របស់ខ្លួន ដូចជា បច្ចុប្បន្នភាពនៃការប៉ាន់ស្មាន ប្រសិទ្ធភាពនៃកម្មវិធី ការបង្កើតសេណារីយ៉ូ និងការវិភាគផលប៉ះពាល់។ ផែនការយុទ្ធសាស្ត្រថ្មីៗទាំងនេះ ផ្តល់ជាក្របខ័ណ្ឌអនុវត្តសម្រាប់ចក្ខុវិស័យរបស់កម្ពុជា 3.0 ដើម្បីលុបបំបាត់ការឆ្លងថ្មីៗនៃមេរោគអេដស៍រហូតដល់ឆ្នាំ 2020។

នៅរវាងខែមករា-កញ្ញា ឆ្នាំ 2014 សមាមាត្រស្ត្រីមានផ្ទៃពោះដែលបានធ្វើតេស្តរកមេរោគអេដស៍ និងបានទទួលលទ្ធផលរបស់ខ្លួន ក៏ដូចជាសមាមាត្រនៃការវិភាគពេគសញ្ញានៅក្នុងដំណាក់កាលដំបូងៗ ក្នុងចំណោមកុមារប្រឈមមេរោគអេដស៍ បានកើនឡើងយ៉ាងច្រើន (ស្ត្រីមានផ្ទៃពោះ៩% និងកុមារ ៨%)។ អ.ស.ប បានបន្តគាំទ្រក្រសួងសុខាភិបាលក្នុងការអនុវត្តវិធីធ្វើតេស្តដោយជួសឈាមនៅចុងម្រាមដៃ ដែលអាចទទួលបានលទ្ធផលឆាប់រហ័ស។ ក្រោមកិច្ចសហការជាមួយក្រសួងសុខាភិបាល ស្តង់ដារនីតិវិធីប្រតិបត្តិការ (SOPs) ត្រូវបានរៀបចំសម្រាប់អនុវត្តនៅកម្ពុជា 3.0។ ជំនួយបច្ចេកទេសត្រូវបានផ្តល់ឲ្យ NCHADS តាមរយៈហិរញ្ញវត្ថុដែលផ្តល់ដោយមូលនិធិសកល សម្រាប់ការរៀបចំផែនការផ្គត់ផ្គង់ ការព្យាករណ៍ លទ្ធកម្ម ARV ប្រតិករសម្រាប់ធ្វើតេស្តរកមេរោគអេដស៍ និងសម្ភារៈប្រើប្រាស់ដទៃទៀត។

អ.ស.ប បានបន្តគាំទ្រដល់កម្មវិធីនារីឆ្លាត (SMARTgirl) នៅក្នុងខេត្តចំនួនប្រាំពីរ តាមរយៈ NGOមួយ (CWPD) ដែលបានគ្របដណ្តប់បុគ្គលិកក្នុងវិស័យបម្រើការកំសាន្តចំនួន ៣៤% អ្នករកស៊ីផ្លូវភេទគ្មានមូលដ្ឋានច្បាស់លាស់ និងដោយខ្លួនឯង( សរុបចំនួន13.000នាក់ )។ ដោយផ្តោតលើការរួមបញ្ចូលវិធីកសាងផែនការគ្រួសារនៅក្នុងសមាសភាគមេរោគអេដស៍ នៃកម្មវិធីនារីឆ្លាត លទ្ធផលបានបង្ហាញថា ៦៩% នៃអ្នកដែលអាចជាអតិថិជន បានរាយការណ៍ថាបានប្រើប្រាស់វិធីកសាងផែនការគ្រួសារ។ ការប្រើប្រាស់ស្រោមអនាម័យជាប់ជាប្រចាំ ជាមួយអតិថិជន នៅតែមានអត្រាថេរត្រឹម ៨0% ប៉ុន្តែការប្រើប្រាស់វិធីបង្ការ និងស្រោមអនាម័យក្នុងចំណោមដៃគូទៀងទាត់ នៅតែមានកម្រិតទាបត្រឹម ៣៦%។

ក្រោមភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ សេវាកម្មទទួលទូរស័ព្ទបន្ទាន់ ត្រូវបានផ្តួចផ្តើមសម្រាប់ផ្តល់ព័ត៌មានអំពីសុខភាពផ្លូវភេទនិងបន្តពូជ ដើម្បីអោយពលរដ្ឋវ័យក្មេងអាចធ្វើសេចក្តីសម្រេចដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់។ អ្នកទូរស័ព្ទចូលវ័យក្មេងប្រមាណ 8.727នាក់ (នៅអាយុក្រោម 25ឆ្នាំ) បានទួលការអប់រំ និងការប្រឹក្សាយោបល់តាមទូរស័ព្ទ ដោយផ្តោតលើសុខភាពផ្លូវភេទនិងបន្តពូជ (៥៦%), បញ្ហាមេរោគអេដស៍ (១៩%) និងកាមរោគ (៦%)។

បន្ថែមលើការវិភាជន៍ថវិកាជាតិសម្រាប់លទ្ធកម្មផលិតផល RH ដោយប្រើប្រាស់ប្រព័ន្ធលទ្ធកម្មដែលមានការទទួលស្គាល់ជាអន្តរជាតិ រដ្ឋាភិបាលកម្ពុជាបានអះអាងអំពីការផ្តល់វិភាគទានថ្មីពីថវិកាជាតិចំនួន 3,7 លានដុល្លាអាមេរិកសម្រាប់ថ្នាំប្រឆាំងវីរុស សម្រាប់អំឡុងពេលបីឆ្នាំ (2015 ដល់ 2017) ជាលទ្ធផលនៃការតស៊ូមតិនៅកម្រិតគោលនយោបាយដោយផ្អែកលើភស្តុតាង បានបង្ហាញថារដ្ឋាភិបាលបង្កើនភាពម្ចាស់ការកាន់តែខ្ពស់ ដើម្បីការទទួលបាននូវការព្យាបាលដោយនិរន្តរភាពសម្រាប់រយៈពេលវែង។ ការគាំទ្រក៏បានផ្តល់ផងដែរដល់រដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបជាសកលទៅនឹងមេរោគអេដស៍ (GARPR) សម្រាប់ឆ្នាំ 2014។

ទាក់ទងនឹងការកាត់បន្ថយគ្រោះថ្នាក់ គោលនយោបាយម្ជុលនិងសឺរ៉ាំង ដែលរៀបចំឡើងជាមួយការគាំទ្រពី អ.ស.ប ត្រូវបានអនុម័ត ហើយមជ្ឈមណ្ឌលព្យាបាលតាមសហគមន៍សម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន កំពុងត្រូវបានពង្រីកនៅក្នុងរាជធានីភ្នំពេញ។

ក្រសួងសុខាភិបាល បានអនុម័ត និងបានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងច្បាប់ស្តីពីការចេញអាជ្ញាប័ណ្ណជាចាំបាច់សម្រាប់សុខភាពសាធារណៈ ដែលមានគោលដៅជានាថា កម្ពុជានៅតែអាចបន្តទទួលបាន

ឱសថសម្រាប់ការពារអ្នកជម្ងឺក្រោយផុតកំណត់រយៈពេលលើកលែង TRIPS សម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច។ ការគាំទ្របច្ចេកទេសកំពុងតែបានផ្តល់ឲ្យក្រសួងសុខាភិបាល សម្រាប់ការពារច្បាប់នេះ ចំពោះមុខក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រីនិង ECOSOC។

នៅក្នុងការអនុវត្តយុទ្ធសាស្ត្រកម្ពុជា 3.0 មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍ រោគសើរស្បែក និងជម្ងឺកាមរោគ (NCHADS) និងដៃគូនានា បានផ្តោតលើការបង្កើតវិធានការចម្រុះគ្រប់គ្រងករណីសកម្ម (IACM)។ អ្នកសម្របសម្រួល/អ្នកជំនួយការ គ្រប់គ្រងករណីត្រូវបានដាក់ពង្រាយនៅកម្រិតស្រុកប្រតិបត្តិ ដើម្បីបង្កើនជាអតិបរមានូវអត្រាអ្នកជម្ងឺនៅបន្តទទួលការព្យាបាល។ ក្រុមតាមដាននិងវិភាគសកម្មភាពឆាប់រហ័ស (RMAA) ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិ និងបានជួបប្រជុំប្រចាំពីរសប្តាហ៍ម្តង ដើម្បីតាមដានវឌ្ឍនភាពនៃ IACM និងដើម្បីពិភាក្សាករណីនៃបញ្ហាបុគ្គលម្នាក់ៗ ដែលរួមទាំងករណីរបស់អ្នកដែលស្ថិតក្នុងក្រុមប្រជាពលរដ្ឋជាគោលដៅផងដែរ ដូចជាបុគ្គលិកក្នុងវិស័យបម្រើការកំសាន្ត បុរសស្រឡាញ់បុរស(MSM) ក្រុមស្រីស្រស់ និងអ្នកចាក់គ្រឿងញៀន (PWID)។

នៅក្នុងក្របខ័ណ្ឌនៃការអប់រំអំពីមេរោគអេដស៍/ជម្ងឺអេដស៍ និងបញ្ហាផ្លូវភេទ សម្រាប់ពលរដ្ឋវ័យក្មេង ដែលរួមទាំងក្រុមពលរដ្ឋវ័យក្មេងជាគោលដៅ អ.ស.ប បានគាំទ្រក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ដើម្បីអនុវត្តកម្មវិធីសិក្សាពិស្តារអំពីសុខភាពផ្លូវភេទ ក្នុងខេត្តចំនួន ៩ នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ក៏ដូចជាកម្មវិធីសិក្សាមិនផ្លូវការផងដែរ។ ជាផ្នែកមួយនៃក្រុមស្នូលថ្នាក់ជាតិស្តីពីអាហារូបត្ថម្ភសម្រាប់អ្នកផ្ទុកមេរោគអេដស៍ អ.ស.ប បានដើរតួសំខាន់នៅក្នុងការកែសម្រួលឡើងវិញឧបករណ៍អាហារល្អ ដែលជាកញ្ចប់សម្ភារៈមួយសម្រាប់ប្រឹក្សាអ្នកផ្ទុកមេរោគអេដស៍អំពីអាហារូបត្ថម្ភ។ ឧបករណ៍ចំនួនប្រាំរយ ត្រូវបានធ្វើលទ្ធកម្ម និងចែកផ្សាយដល់គ្រូបង្ហាត់ និង អង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តកម្មវិធីថែទាំសុខភាពតាមគ្រួសារ។

**ទឹកស្អាតនិងអនាម័យ ៖**

វឌ្ឍនភាពតាមវិស័យត្រូវបានតាមដាន តាមរយៈកម្មវិធីតាមដានរួមគ្នាមួយរវាង UNICEF/WHO និងការវិភាគនិងវាយតម្លៃជាសកលអំពីអនាម័យនិងទឹកស្អាតសម្រាប់ផឹក (GLAAS)។ នៅឆ្នាំ ២០១៤ ប្រជាជនច្រើនជាង ៧០% ប្រើប្រាស់ទឹកពីប្រភពស្អាត (៩៤% នៅទីក្រុង/ ៦៦% នៅជនបទ)[3]។ ពាក់ព័ន្ធនឹងទឹកស្អាតនិងអនាម័យតាមជនបទកម្ពុជាស្ថិតក្នុងលំដាប់ទាបជាងគេបំផុតក្នុងតំបន់នេះ។ គម្លាតយ៉ាងធំខាងវិសាលភាពគ្របដណ្តប់នៃកម្មវិធី WASH នៅតែមានកម្រិតនៅឡើយ ជាពិសេស បញ្ហាអនាម័យ ដែលវិសាលភាពគ្របដណ្តប់សរុបគឺ 37% (82% នៅទីក្រុង/25% នៅជនបទ)។

បន្ទាប់ពីមានការតស៊ូមតិរួមគ្នាជាច្រើនឆ្នាំដោយអ.ស.ប និង NGOs ក្នុងឆ្នាំ 2014 ទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជាបានអនុម័តផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជនបទ និងអនាម័យ ។ បន្ទាប់ពីនោះ ផែនការសម្មភាពជាតិសម្រាប់ប្រតិបត្តិការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំ។ យោងតាមការវាយតម្លៃថ្មីៗនេះដោយអង្គការសុខភាពពិភពលោកអំពីគុណភាពទឹកផឹកនៅឆ្នាំ 2014 មានគ្រួសារត្រឹម 23% ដែលមានទឹកផឹកប្រកបដោយសុវត្ថិភាពនៅជិតបំផុត។ ទោះជាមានកំណើនយាងច្រើននៃការវិនិយោគពីវិស័យឯកជនក៏ដោយ ដើម្បីសាងសង់ប្រព័ន្ធចែកចាយទឹក ការធ្វើនិយ័តកម្ម និងពង្រឹងការអនុវត្តកម្មវិធីទឹកស្អាតសម្រាប់ផឹក ស្តង់ដារគុណភាពទឹកនៅតែជាបញ្ហាប្រឈមនៅឡើយ។

ការគាំទ្រត្រូវបានផ្តល់ដល់ប្រជាជនក្នុង 383ភូមិ ក្នុង11ខេត្ត ដែលផ្តល់ឱកាសអោយសហគមន៍ដឹកនាំ

[3] JMP 2014

អនាម័យទាំងស្រុង ដើម្បីបង្ហាញជាយុទ្ធសាស្ត្រនិម្មិត្តរូបមួយសម្រាប់ការផ្លាស់ប្តូរនិយាមសង្គម។ អ្នកទស្សនា និងអ្នកស្តាប់ប្រមាណបីលាននាក់បានទទួលព័ត៌មានតាមរយៈចម្រៀង សារទូរស័ព្ទ ការទូរស័ព្ទចូលក្នុងកម្មវិធីតាមវិទ្យុ និងកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍។ ជាផ្នែកមួយនៃសកម្មភាពថ្នាក់ជាតិស្តីពីការលាងសំអាតដៃជាមួយសាប៊ូ នៅតាមសាលារៀន សិស្សសាលាចំនួន 200.000 នាក់ បានទទួលខ្លឹមសារនេះ តាមរយៈយុទ្ធនាការព័ត៌មានក្នុងរយៈពេលពីរខែ[4]។

តាមរយៈភាពជាដៃគូជាមួយ NGOs សាលារៀនចំនួនប្រាំមួយ បានទទួលផលពីកែលម្អ និងពង្រឹងកម្មវិធីសេវាកម្មអនាម័យដល់សិស្សចំនួន 1.740នាក់[5] នៅក្នុងរដូវវស្សាឆ្នាំ 2014។ ជាផ្នែកមួយនៃកម្មវិធីផ្តល់អាហារបន្ថែមតាមសាលារៀន ដែលគាំទ្រដោយអ.ស.ប អណ្តូងទឹកចំនួន 40 និងបង្គន់អនាម័យចំនួន 78 ត្រូវបានសង់ ឬ ជួសជុលឡើងវិញ ហើយកញ្ចប់សម្រាប់អនាម័យនិងការរស់នៅស្អាតចំនួន 856 ត្រូវបានផ្តល់នៅឆ្នាំ 2014។ លើសពីនេះ ប្រជាជនចំនួន 46.459 គ្រួសារ (213.711 នាក់) បានទទួលសេវាទឹកផឹកដែលមានសុវត្ថិភាព ជាពិសេស ទឹកពីប្រភពជំនួសដែលគ្មានជាតិអាសេនិក។ អណ្តូងទឹកចំនួន 4.586 ត្រូវបានវិភាគគុណភាពទឹកឡើងវិញ ហើយសកម្មភាពបង្កើនការយល់ដឹងត្រូវបានអនុវត្តក្នុងភូមិចំនួន 273 ក្នុងឃុំចំនួន 60 ក្នុងខេត្តដែលមានហានិភ័យខ្ពស់ជាងគេគឺ កណ្តាល ព្រៃវែង និងកំពង់ចាម។ ភូមិចំនួន 23 ក្នុងឃុំចំនួន 5 បានផ្តួចផ្តើមប្រព្រឹត្តកម្មទឹក និងសកម្មភាពដែលមានសុវត្ថិភាពតាមគ្រួសារ ដើម្បីលើកកំពស់ការទទួលបានទឹកផឹកដែលមានសុវត្ថិភាព។

តាមរយៈការគាំទ្រហិរញ្ញវត្ថុពីគណៈកម្មការអឺរ៉ុប គ្រួសារចំនួន 10.000 ទទួលបានសម្ភារៈផ្គត់ផ្គង់ទឹកក្នុងស្រុកចំនួន 18 ក្នុងប្រាំខេត្ត ដែលរងការប៉ះពាល់ពីទឹកជំនន់នៅគ្រប់រដូវ។ សកម្មភាពនេះបានបំពេញបន្ថែមតាមរយៈការកសាងសមត្ថភាពមន្ត្រីចំនួន 98 នាក់ អំពីការដាក់ក្លរ និងការគ្រប់គ្រងអណ្តូងនៅក្នុងពេល និង ក្រោយពេលមានទឹកជំនន់។ ការវាយតម្លៃអណ្តូងទឹក ដោយប្រើប្រាស់បច្ចេកវិទ្យាចល័ត ត្រូវបានប្រកាសឲ្យប្រើប្រាស់ ក្រោមភាពជាដៃគូជាមួយ NGOs ដោយបានបង្កើនប្រសិទ្ធភាព និងភាពសុក្រឹត្យនៃការប្រមូល និងប្រើប្រាស់ព័ត៌មានសម្រាប់រៀបចំផែនការ និងការធ្វើសេចក្តីសម្រេច។

**ការអប់រំ ៖**

កម្ពុជាទទួលជោគជ័យក្នុងការធ្វើឲ្យប្រសើរឡើងក្នុងវិស័យអប់រំនិងសម្រេច CMDG អំពីការអប់រំ។ វិសាលភាពគ្របដណ្តប់នៃការអប់រំថ្នាក់បឋមសិក្សា នៅតែមានកម្រិតខ្ពស់ ដែលបានកើនដល់ 98,2% នៅឆ្នាំសិក្សា 2013/2014 (98,5% សម្រាប់កុមារី)។ កុមារអាយុចូលរៀនថ្នាក់បឋមសិក្សា ដែលបានចុះឈ្មោះក្នុងសាលាឯកជន មានដល់ 2,6%។ លទ្ធភាពទទួលបានការអប់រំកុមារតូច(ECE) បានកើនឡើងបន្តិច ចាប់ពី 32,7% នៅឆ្នាំ 2012/2013 ដល់ 33,3% នៅឆ្នាំ 2013/2014 ក្នុងចំណោមកុមារអាយុ 3 ដល់ 5ឆ្នាំ។ អ.ស.បបានគាំទ្រក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ដើម្បីបង្កើនវត្តមានការអប់រំបានពេញលេញអំពីសុខភាពផ្លូវភេទ (CSE) នៅតាមសាលារៀន។ សកម្មភាពនេះបានផ្តល់ឲ្យពលរដ្ឋវ័យក្មេងនៅសាលាមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នូវចំណេះដឹងប្រសើរជាងមុនអំពីសុខភាពបន្តពូជនិងផ្លូវភេទរបស់ពួកគេ ដែលជាផ្នែកមួយនៃការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបំពេញសិទ្ធិបន្តពូជរបស់ពលរដ្ឋកម្ពុជា។

វិសាលភាពនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅតែមានកម្រិតទាបនៅឡើយ ដែលថយចុះពី 53,6% (2012/2013) មក 53,5% (2013/2014) (54,5%ជាកុមារី)។ អត្រានេះកាន់តែខ្ពស់ដោយសារជម្រើសសេដ្ឋកិច្ច និងប្រាក់បៀវត្សរ៍កើនឡើង។ ឧស្សាហកម្មវាយនភណ្ឌនៅតែជាការគំរាមកំហែងចំពោះកុមារក្នុងបញ្ចប់ការសិក្សាជាមូល

[4] ស្រង់ចេញពី UNICEF 2014 annual report- results assessment matrix
[5] Ibid.

ដ្ឋាននៅកម្ពុជា។ គម្រោងការសិក្សាអំពីសិស្សបោះបង់សាលារៀន នឹងបង្ហាញកាន់តែច្បាស់អំពីមូលហេតុនៃការបោះបង់ចោលសាលារៀនរបស់កុមារ។

ទិន្នន័យពីការវាយតម្លៃជាលក្ខណៈស្តង់ដារនៃលទ្ធផលរៀនសូត្ររបស់កុមារ (ដែលបានធ្វើឡើងក្នុងចំណោមសំណាកពីសាលារៀនខុសៗគ្នា) បានបង្ហាញពីការថយចុះនៅថ្នាក់ទី 6 ពី 68,1 មក 52,2% សម្រាប់មុខវិជ្ជាភាសាខ្មែរ និង 58,9 មក 42,8 សម្រាប់មុខវិជ្ជាគណិតវិទ្យា រវាងឆ្នាំ 2006/2007 និង 2012/2013។ នៅឆ្នាំ 2015, MoEYS នឹងបានទទួលការគាំទ្រ ដើម្បីចូលរួមនៅក្នុងកិច្ចផ្តួចផ្តើមថ្នាក់តំបន់ ដើម្បីវាស់លទ្ធផលរៀនសូត្ររបស់កុមារ ខាងមុខវិជ្ជាគណិតវិទ្យា ភាសាខ្មែរ និងពលរដ្ឋវិជ្ជា សម្រាប់សិស្សថ្នាក់ទី ៥។ កិច្ចផ្តួចផ្តើមនេះនឹងផ្តល់ទិន្នន័យបន្ថែមអំពីថាតើកុមាររៀនសូត្រអ្វីខ្លះ និងដោយរបៀបណា និងសិស្សណាខ្លះដែលបានរៀន។

អាទិភាពមួយក្នុងចំណោមអាទិភាពនានានៃកំណែទម្រង់របស់រដ្ឋមន្ត្រីក្រសួងអប់រំក្នុងឆ្នាំ 2014 គឺគ្រប់គ្រងការប្រឡងនៅថ្នាក់ទី 12 ក្រោមភាពជាដៃគូជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដោយមានការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការ UNICEF។ ជាសរុប សិស្សចំនួន 41% បានប្រឡងជាប់តាមអត្រា 9% សម្រាប់មុខវិជ្ជាគណិតវិទ្យា និង 14% សម្រាប់គីមីវិទ្យា ដែលនាំឲ្យមានការកែប្រែគោលនយោបាយដែលផ្តោតកម្មវិធីសិក្សានិងចំណេះដឹងរបស់គ្រូលើមុខវិជ្ជាវិទ្យាសាស្ត្រ។

នៅក្នុងការលើកកំពស់ការសិក្សាជាមូលដ្ឋាននៅឆ្នាំសិក្សា 2013-2014 កម្មវិធីផ្តល់អាហារបន្ថែមរបស់អ.ស.ប បានផ្តល់ដល់សិស្សសាលាបឋមសិក្សាចំនួន 450.000 នាក់ ដែលរួមទាំង 397.000 នាក់នៅថ្នាក់មត្តេយ្យសិក្សា និងអាហារូបករណ៍ចំនួន 53,000នាក់ (អាហារ និងសាច់ប្រាក់) ដល់កុមារក្រីក្រនៅថ្នាក់ទី 4 ដល់ទី 6, នៅតាម 4.190 សាលារៀនក្នុងខេត្តចំនួន16។ ការផ្តល់អាហារតាមសាលារៀន ផ្តល់ឲ្យឪពុកម្តាយនូវជម្រើសក្នុងការបញ្ជូនកូនទៅរៀនជាងបញ្ជូនពួកគេទៅធ្វើការ និងរួមចំណែកក្នុងការបង្កើនចំនួនសិស្សចុះឈ្មោះចូលរៀន ការមករៀន និងការបន្តសិក្សា។ ក្នុងអន្តរកាលឈានទៅរកកម្មវិធីរបស់ជាតិសម្រាប់ផ្តល់អាហារតាមសាលារៀន អ.ស.បបានផ្ទេរការទទួលខុសត្រូវយ៉ាងច្រើនដល់រដ្ឋាភិបាលសម្រាប់អនុវត្តកម្មវិធីអាហារូបករណ៍ជាអាហារបន្ថែមនៅក្នុងខេត្តចំនួនពីរ និងបានគាំទ្រដល់ការបង្កើតកម្មវិធីជាតិផ្តល់អាហារូបករណ៍ថ្មីសម្រាប់ថ្នាក់បឋមសិក្សាដើម្បីអនុវត្តទូទាំងប្រទេសនៅឆ្នាំ 2015។ ក្នុងមួយឆ្នាំៗ រដ្ឋាភិបាលរួមចំណែកជាអង្ករ 2.000 តោន ដល់កម្មវិធីផ្តល់អាហារតាមសាលារៀន។

នៅឆ្នាំ 2014 អ.ស.ប និង USAID បានផ្តល់ការគាំទ្ររួមគ្នាដល់កិច្ចផ្តួចផ្តើមព័ត៌មានចម្រុះស្តីពីការសិក្សារបស់យុវវ័យ អំពីសុខភាពនិងសិទ្ធិបន្តពូជនិងផ្លូវភេទ (ឡូយ9) ដែលបានផ្តល់លទ្ធផលវិជ្ជមាន។ មកទល់ខែវិច្ឆិកា ឆ្នាំ 2014 មនុស្សជិត1លាននាក់បានចូលអានក្នុងបណ្តាញព័ត៌មានសង្គមឡូយ9។ យោបល់តបរបស់អ្នកអានមានលក្ខណៈវិជ្ជមានជាខ្លាំង។

ថវិកាចរន្តសរុបរបស់ក្រសួង បានកើនឡើងពី 15,5 % នៅឆ្នាំ 2013 ដល់ 16,2% នៅឆ្នាំ 2014 និងបានព្យាករណ៍ថាកើនដល់ 17,1% នៅឆ្នាំ 2015។ អត្រាប្រតិបត្តិក៏មានការរីកចម្រើនផងដែរ ហើយមានការថយចុះនៃការចំណាយទាបជាងការគ្រោងទុក ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ដោយសារតែដំណើរការត្រៀមរៀបចំថវិកាបានច្បាស់លាស់ជាងមុន ជាពិសេស ខាងបុគ្គលិក។ នៅឆ្នាំ 2014 គ្រូបង្រៀនបានទទួលប្រាក់បៀវត្សរ៍របស់ខ្លួនតាមរយៈការផ្ទេរចូលគណនីក្នុងធនាគារ ដែលទំនងជាបង្កើនអត្រានៃប្រតិបត្តិការ។ បន្ទាប់ពីបន្តកិច្ចប្រឹងប្រែងតស៊ូមតិ ប្រាក់បៀវត្សរ៍សម្រាប់គ្រូបានកើនឡើង ហើយប្រាក់ឧបត្ថម្ភត្រូវបានបន្សុីគ្នា និងធ្វើឲ្យមានលក្ខណៈងាយស្រួល ដែលបង្កើនតម្លាភាព និងការកែលម្អលក្ខខណ្ឌរបស់គ្រូ។

នៅក្នុងការអភិវឌ្ឍវិស័យអប់រំជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ2014-2018 បានទទួលការអនុម័ត នៅក្នុងខែមីនា ឆ្នាំ2014។ មូលនិធិថ្មីអំពីភាពជាដៃគូសាកលសម្រាប់វិស័យអប់រំ (GPE) ដែលមានទឹកប្រាក់38,5 លានដុល្លាអាមេរិក ត្រូវបានប្រកាស ហើយមូលនិធិនេះនឹងផ្តល់ជាការគាំទ្របន្ថែម ជាពិសេស ដែលទាក់ទងនឹងការអប់រំកុមារតូច ECEនិងការអប់រំប្រកបដោយបរិយាប័ន្ន។

នៅក្នុងការត្រៀមសម្រាប់យុទ្ធនាការជាតិសម្រាប់ការចេះអក្សរក្នុងឆ្នាំ 2015 គ្រូអក្ខរកម្មស្នូលចំនួន 666 នាក់ (ដែលរួមទាំង បុគ្គលិកស្ត្រីចំនួន 77 នាក់ មកពីការិយាល័យអប់រំថ្នាក់ខេត្ត និងស្រុក) បានទទួលការបណ្តុះបណ្តាល។ យុទ្ធនាការនេះត្រូវបានរំពឹងថា នឹងធ្វើឲ្យជនកម្ពុជាចំនួន 92.000 នាក់ នឹងអាចចេះអក្សរនៅក្នុងឆ្នាំ 2015។ លើសពីនេះ កម្មវិធីជាតិសម្រាប់ការសិក្សាអក្ខរកម្ម ត្រូវបានពិនិត្យ និងកែសម្រួល ហើយប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ (NF-EMIS) ត្រូវបានបង្កើតឡើងផងដែរ និងបានតម្លើងនៅតាមការិយាល័យអប់រំថ្នាក់ខេត្តចំនួន 25ផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា បានទទួលការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីរៀបចំសេចក្តីព្រាង និងរៀបចំបង្ហើយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (TPAP) ដែលនឹងមានឥទ្ធិពលរយៈពេលវែងមកលើការសិក្សារបស់គ្រូ ការជ្រើសរើស ការអភិវឌ្ឍ ការគ្រប់គ្រង និងលំនាំនៃអាជីព ក៏ដូចជា ការគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូផងដែរ។ វិទ្យាស្ថានជាតិអប់រំ បានទទួលការគាំទ្របចច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីរួមបញ្ចូលសញ្ញាណនៃយុវជនសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) ទៅក្នុងកម្មវិធីសិក្សាដែលមានស្រាប់ ហើយគ្រូបង្គោលគរុកោសល្យចំនួន 150នាក់ បានធ្វើបច្ចុប្បន្នភាពអំពីការប្រើប្រាស់កម្មវិធីសិក្សាកែប្រែផងដែរ។

ការទទួលស្គាល់ពីសារៈសំខាន់នៃភាពជាសហគ្រិននៅកម្ពុជា អ.ស.ប បានគាំទ្រក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ដើម្បីដាក់បញ្ចូលការអប់រំអំពីភាពជាសហគ្រិននៅកម្រិតមធ្យមសិក្សា។ សាលារៀនចំនួនប្រាំ បានចាប់ផ្តើមសាកល្បងឧបករណ៍ភាពជាសហគ្រិន ដែលហៅថា "ការយល់ដឹងអំពីអាជីវកម្ម" (KAB) មុននឹងពង្រីកការអនុវត្តឲ្យបានទូលំទូលាយ - ពេលគឺជាជំហានវិវត្តថ្មីមួយសម្រាប់ការបង្កើតជំនាញសហគ្រិនសម្រាប់សិស្សថ្នាក់មធ្យមសិក្សានៅក្នុងប្រទេសនេះ។ ជាមួយការគាំទ្រពី អ.ស.ប វគ្គបណ្តុះបណ្តាលនវានុវត្តមួយដែលចំណាយទាបសម្រាប់ភាពជាសហគ្រិន និងការបង្កើនអាជីវកម្មខ្នាតតូច ដែលហៅថា"ការអភិវឌ្ឍសហគ្រាសសហគមន៍" (CBED) ត្រូវបានធ្វើឡើងសម្រាប់យុវជនក្រៅសាលារៀនចំនួន 2.700 នាក់ តាមរយៈសេវាកម្មបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MoLVT) MoEYS និង NGOs អន្តរជាតិ។

ផែនការយុទ្ធសាស្ត្រ TVET សម្រាប់ឆ្នាំ 2014-2018 ដែលផ្តោតលើការកែលម្អលទ្ធភាពចូលរៀន គុណភាពនិងភាពពាក់ព័ន្ធនៃប្រព័ន្ធ TVET ត្រូវបានអនុម័តដោយក្រសួង MoLVT។ ការគាំទ្ររបស់អ.ស.ប បានផ្តល់សម្រាប់ការអនុវត្តផែនការ TVET និងការទទួលស្គាល់ជំនាញរបស់គ្នាទៅវិញទៅមក សម្រាប់ការធ្វើសមាហរណកម្មពេញលេញទៅក្នុងសមាគមសេដ្ឋកិច្ចអាស៊ាន (AEC) នៅឆ្នាំ 2015។ ស្តង់ដារជំនាញដែលផ្អែកលើសមត្ថភាពសម្រាប់ការងារចំនួន 23 នៃអាជីពក្នុងវិស័យទេសចរណ៍ ត្រូវបានបង្កើតឡើង សម្រាប់ការទទួលស្គាល់នៅទូទាំងឧស្សាហកម្មនេះ និងមានការគាំទ្រនៅទូទាំងបណ្តាប្រទេសក្នុងសមាគមសេដ្ឋកិច្ចអាស៊ាន។ ជាមួយការគាំទ្ររបស់អ.ស.ប ការងារចំនួនពីរ (ជាងកំបោរ និងការរាយខ្សែភ្លើង) សម្រាប់ឧស្សាហកម្មសាងសង់ ត្រូវបានកំណត់សម្រាប់ការទទួលស្គាល់ទៅវិញទៅមករវាងកម្ពុជា និងប្រទេសថៃ ដែលជាផ្នែកមួយនៃការចាត់ចែង AEC។

លើសពីនេះ អ.ស.ប បានជំរុញអង្គការយុវជន និងបណ្តាញយុវជន ចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងការសន្ទនាអំពីការពិគ្រោះយោបល់នៅក្រោយឆ្នាំ2015 ការពិគ្រោះយោបល់អំពី UNDAF ការរៀបចំបង្ហើយផែនការសកម្មភាពជាតិយុវជន ជាមួយសង្គមស៊ីវិល។

# ការប្រឈមនានា

## សុខភាព ៖

- ប្រជាជនដែលរស់នៅក្នុងទំបន់ដាច់ស្រយាល ពិបាកចូលដល់ និងមានការអភិវឌ្ឍតិចតួច (ទីតាំងលំនៅស្ថានថ្មីៗ ជនចំណាកស្រុកប្រចាំរដូវ) ដោយសារភាពក្រីក្រចម្រុះ ចម្ងាយឆ្ងាយដើម្បីទទួលបានសេវាថៃទាំសុខភាព កង្វះការដឹកជញ្ជូន និងខ្វះធ្មប ព្រមទាំងលទ្ធភាពទទួលបានសេវាសំខាន់ៗពីសុខភាពបន្តពូជ ការកសាងផែនការគ្រួសារ សុខភាពមាតា ទារក និងកុមារមានកម្រិត។
- ទោះបីការយល់ដឹងខ្លះៗ កំពុងចាប់ផ្តើមកត់សំគាល់ក្នុងចំណោមអ្នកគ្រប់គ្រងសុខភាព គុណភាពទាបនៃសេវា រួមផ្សំជាមួយការចាត់ចែងមិនទាន់បានល្អក្នុងការបញ្ជូនសម្រាប់ករណីបន្ទាន់ នៅតែជាការប្រឈមមួយ ដែលទាមទារឲ្យមានកិច្ចប្រឹងប្រែងសហការគ្នាពីភ្នាក់ងារសុខភាព។
- ការប្រឈមផ្សេងទៀតដែលបានកត់សំគាល់ក្នុងផ្នែកសុខភាពបន្តពូជរបស់មាតា សុខភាពទារក និងកុមារ នៅក្នុងការពិនិត្យអំពីគុណភាពការងារប្រចាំឆ្នាំ 2014 រួមបញ្ចូល អនុលោមភាពជាមួយគោលនយោបាយ និងគោលការណ៍ណែនាំនានាដែលមានស្រាប់ ការដឹកនាំមានកម្រិត និងកង្វះការតាមដានបន្តនៅក្រោយបណ្តុះបណ្តាល កង្វះធនធានមនុស្ស បរិក្ខារ និងសម្ភារៈនានាក្នុងសម្បទាសុខភាព ការយល់ខុសអំពីការប្រើប្រាស់វិធីបង្ការការមានផ្ទៃពោះតាមវិធីទំនើប និងភាពម្ចាស់ការ និងការគាំទ្រមានកម្រិត ដើម្បីបង្កើតប្រព័ន្ធបញ្ជូនក្នុងសហគមន៍សម្រាប់ករណីបន្ទាន់ ក្នុងចំណោមកិច្ចការនានាដទៃទៀត។

## មេរោគអេដស៍/ជម្ងឺអេដស៍ ៖

- នៅក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក ការឆ្លើយតបនឹងបញ្ហាមេរោគអេដស៍ ច្រើនតែបានពឹងផ្អែកលើប្រភពពីខាងក្រៅ។ ការកាត់បន្ថយភ្លាមៗ (ប្រមាណ 40-50%) នៃមូលនិធិសកល នៅឆ្នាំ 2014 បាននាំឲ្យមានបញ្ហាធំៗអំពីការទទួលខុសត្រូវ ដែលទាក់ទងនឹងវិសាលភាពនៃសេវាសំខាន់ៗដើម្បីទប់ស្កាត់ និងការបន្តទទួលបានសេវាព្យាបាលសម្រាប់អ្នកផ្ទុកមេរោគអេដស៍។
- ទោះបីកម្ពុជាសម្រេចបានកំណើនយ៉ាងច្រើនក្នុងទសវត្សរ៍កន្លងមកក៏ដោយ នៅក្នុងការកាត់បន្ថយករណីឆ្លងមេរោគអេដស៍ថ្មីៗ និងការបាត់បង់ជីវិតដោយសារជម្ងឺអេដស៍ក៏ដោយ សមត្ថភាព ជាពិសេស នៅថ្នាក់ខេត្ត និងកម្រិតស្រុកប្រតិបត្តិ នៅតែជាការប្រឈមចំបងៗនៅឡើយ សម្រាប់ការពង្រីកនិងតាមដានការឆ្លើយតប។
- សមាមាត្រយ៉ាងច្រើននៃកុមារប្រឈមនឹងមេរោគអេដស៍ បានបាត់មុខនៅក្នុងពេលបន្តព្យាបាល ដែលរារាំងការធ្វើរោគវិនិច្ឆ័យតាំងពីនៅកុមារភាព។
- ការប្រើប្រាស់ជាប្រចាំនូវវិធីបង្ការការមានផ្ទៃពោះនិងការប្រើស្រោមអនាម័យ ជាមួយដៃគូទៀងទាត់របស់ខ្លួន ក្នុងចំណោមបុគ្គលិកតាមកន្លែងបម្រើការកំសាន្ត នៅតែមានកម្រិតទាប (36%) ដែលរួមចំណែកដល់អត្រាខ្ពស់នៃការរំលូតកូន (77%)។
- ករណីឆ្លងមេរោគអេដស៍ថ្មីៗ ត្រូវបានរាយការណ៍នៅក្នុងឃុំរការ ក្នុងខេត្តបាត់ដំបង កាលពីខែធ្នូ ឆ្នាំ 2014 ដែលបង្ហាញអំពីតម្រូវការក្របខ័ណ្ឌនិយ័តកម្មកាន់តែតឹងរ៉ឹង ដើម្បីពិនិត្យទម្លាប់អនុវត្តមិនត្រឹមត្រូវក្នុងការផ្តល់សេវាសុខភាពក្រៅប្រព័ន្ធ ការធានាឲ្យមានវិធានការប្រុងប្រយ័ត្នជាសាកល និងប្រព័ន្ធឃ្លាំមើលដែលកាន់តែប្រយ័ត្នប្រយែង និងឆ្លើយតបដាងមុន សម្រាប់ការធ្វើតេស្តនៅក្នុងដំណាក់កាលដំបូងៗនៃឧប្បទ្វវហេតុបែបនេះ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍នេះបានតម្រូវឲ្យមានការបង្កើនការយល់ដឹងអំពីមេរោគអេដស៍ និងទម្លាប់នៃការចាក់ថ្នាំដោយសុវត្ថិភាពក្នុងចំណោមសាធារណជនទូទៅ និងដោះស្រាយបញ្ហាមាក់ងាយ និងការរើសអើង។

**អាហារូបត្ថម្ភ ៖**

- អត្រាកុមារខ្វះអាហារូបត្ថម្ភស្រួចស្រាល (SAM) ដែលត្រូវការយ៉ាងហោចណាស់ការពិនិត្យឡើងវិញមួយលើកថែមទៀត ក្រោយពេលបញ្ចប់ការព្យាបាល នៅមានត្រឹមតែប្រមាណ 60% ប៉ុណ្ណោះ។
- ទោះបីមានវឌ្ឍនភាពគួរឲ្យកត់សំគាល់អំពីការរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រអាហារូបត្ថម្ភក៏ដោយ គម្លាតខាងហិរញ្ញវត្ថុត្រូវបានជួបប្រទះ ដោយសារតែកម្មវិធី HSSP2 ឈានដល់ទីបញ្ចប់។

**ទឹកស្អាត និងអនាម័យ ៖**

- តួនាទី និងការទទួលខុសត្រូវក្នុងការផ្គត់ផ្គង់ទឹកស្អាត សេវាអនាម័យ និងការរស់នៅស្អាត នៅតែគ្មានភាពប្រាកដប្រជា នៅក្រោមដំណើរការវិមជ្ឈការ និងសហវិមជ្ឈការដែលកំពុងវិវត្តន៍ ហើយការតាមដានវឌ្ឍនភាពនៅក្នុងវិស័យនេះ បន្តជួបការលំបាក ដោយសារគ្មានប្រព័ន្ធព័ត៌មានគ្រប់គ្រងរួមគ្នាមួយដែលមានលក្ខណៈស្តង់ដារ។
- ភាពទន់ខ្សោយនៃនិយ័តកម្ម និងការពង្រឹងការអនុវត្តស្តង់ដារគុណភាពទឹកផឹកដែលមានសុវត្ថិភាពនៅតែជាការប្រឈម។
- ការធានាអនុវត្ត WASH នៅតាមសាលារៀន និងមណ្ឌលសុខភាព កំពុងជួបការប្រឈម ដោយសារតែភាពទន់ខ្សោយខាងប្រតិបត្តិការ និងការថែទាំ ការទទួលខុសត្រូវ និងគណនេយ្យភាពពីសំណាក់អ្នកជាប់កាតព្វកិច្ច។
- ស្ថានភាពនៃដំណើរការសេវា WASH និងការអនុវត្តនៅក្នុងការថែទាំសុខភាពនៅតាមមន្ទីរពេទ្យបង្អែក និងសាលារៀននៅពុំទាន់បានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិស័យនេះនៅឡើយទេ។

**ការអប់រំ ៖**

- តម្រូវការខ្ពស់នៃកម្មវិធីផ្តល់អាហារតាមសាលារៀន ប៉ុន្តែដោយថវិកាមានកម្រិតនិងគ្មានភាពប្រាកដប្រជា ពី អ.ស.ប និងរដ្ឋាភិបាល នាំអោយលទ្ធភាពពង្រីកកម្មវិធីនេះជាបញ្ហាប្រឈម។
- កំណែទម្រង់ជាច្រើនកំពុងតែអនុវត្តក្នុងវិស័យអប់រំ ហើយជាការចាំបាច់ជាបន្ទាន់ និងត្រូវការជាទីបំផុត ប៉ុន្តែសមត្ថភាពដើម្បីអនុវត្តកំណែទម្រង់ទាំងនេះឲ្យបានពេញលេញ នៅតែជួបឧបសគ្គនៅឡើយ។
- កង្វះគោលការណ៍ណែនាំផ្លូវការអំពីការកំណត់ម៉ោងសម្រាប់គ្រូបង្រៀន សម្រាប់ការអប់រំពេញលេញអំពីសុខភាពផ្លូវភេទ /អប់រំអំពីសុខភាពទាំងនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ដែលនាំឲ្យគ្មានសង្គតិភាពរវាងសាលានានា នៅពេលរៀបចំកាលវិភាគបង្រៀន។ ប្រការនេះក៏ប៉ះពាល់ផងដែរចំពោះសកម្មភាពត្រួតពិនិត្យ និងតាមដាន ក៏ដូចជាគុណភាពនៃការអនុវត្តកម្មវិធីសិក្សាផងដែរ។
- ការអនុវត្ត TPAP ទាមទារឲ្យមានការវិនិយោគយ៉ាងច្រើនពីខាងរដ្ឋាភិបាល និងពីដៃគូអភិវឌ្ឍន៍។
- ទោះបីមានការរៀបចំសេចក្តីព្រាងផែនការសកម្មភាពយុវជនហើយក៏ដោយ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិយុវជន នៅពុំទាន់បានបង្កើតនៅឡើយទេ ដូច្នេះធ្វើឲ្យផែនទីបង្ហាញផ្លូវគ្មានភាពច្បាស់លាស់សម្រាប់ការអនុវត្ត និងការតាមដាន។
- ការបណ្តុះបណ្តាល TVET ផ្អែកជាចម្បងលើធនធាន ហើយគ្រូបង្ហាត់ប្រើប្រាស់កម្មវិធីជាទ្រឹស្តី តាមចំនួនម៉ោង និងគ្មានភាពបត់បែនតាមតម្រូវការទីផ្សារ និងការប្រែប្រួលបច្ចេកវិទ្យាឡើយ។ ឧស្សាហកម្ម និងអ្នកពាក់ព័ន្ធដទៃទៀតមានការចូលរួមក្នុងកម្រិតកំណត់ ក្នុងការធានាថាប្រព័ន្ធ TVET ផ្តល់អត្ថប្រយោជន៍ ចំណែកគ្រឹះស្ថាននានាប្រឈមនឹងតម្រូវការប្រកបដោយភាពប្រកួតប្រជែងដើម្បីទទួលបានធនធាននិងសមត្ថភាព សម្រាប់កែលម្អទាំងលទ្ធភាពទទួលបាន និងគុណភាពនៃសេវាផងដែរ។

## *អាទិភាពសម្រាប់ឆ្នាំ 2015*

## សុខភាព៖

- ពង្រីកកម្មវិធីអប់រំអំពីការប្រាស្រ័យទាក់ទងដែលនាំឲ្យមានការកែប្រែឥរិយាបថនៅតាមសហគមន៍ អំពីការទប់ស្កាត់ករណីតេតាណូសលើទារក នៅក្នុងតំបន់នានាដែលមានប្រេវ៉ាឡង់ខ្ពស់នៃទម្លាប់អនុវត្តកាត់ទងផ្ចិតដែលគ្មានអនាម័យ ដើម្បីបង្កើនការយល់ដឹងដល់គ្រួសារ និងសហគមន៍អំពីទម្លាប់នៃការកាត់ទងផ្ចិតប្រកបដោយគ្រោះថ្នាក់។
- បន្តគាំទ្រដល់សកម្មភាពចម្រុះក្នុងការផ្សព្វផ្សាយដល់មូលដ្ឋានសម្រាប់សហគមន៍ដែលពិបាកចូលដល់ និងដែលក្រីក្របំផុត ដើម្បីបំពេញគម្លាតនៃសេវាគ្របដណ្តប់សម្រាប់ក្រុមពលរដ្ឋដែលងាយរងគ្រោះ រួមផ្សំជាមួយការតស៊ូមតិដើម្បីបង្កើនការផ្តល់ថវិកាប្រចាំឆ្នាំ។
- ពង្រឹងសមត្ថភាពនិងជំនាញឆ្មបដែលបម្រើការនៅតាមតំបន់ដាច់ស្រយាល់ ដោយផ្តល់ឲ្យពួកគេនូវឱកាសដើម្បីអនុវត្តនៅក្រោមការត្រួតពិនិត្យយ៉ាងម៉ត់ចត់ និងការណែនាំពីគ្រូបង្វឹកដែលមានបទពិសោធន៍ខាងសេវាសម្ភពសង្គ្រោះបន្ទាន់ និងថែទាំទារក។
- កម្មវិធីផ្តល់ថ្នាំបង្ការកម្រិតជាតិបានកំណត់អាទិភាពដូចតទៅសម្រាប់ឆ្នាំ 2015៖ ការបញ្ចូលនូវការផ្តល់ថ្នាំបង្ការរោគហើមស្ងួត (PCV) និងថ្នាំបង្ការរោគខ្វះឆ្អឹងខ្នង (IPV) ទៅក្នុងកម្មវិធីផ្តល់ថ្នាំបង្ការជាប្រចាំ និងការបណ្តុះបណ្តាលការអង្កេតផ្ទៀងផ្ទាត់អំពីការលុបបំបាត់រោគតេតាណូសក្នុងចំណោមមាតានិងទារក ការពិនិត្យកម្មវិធីពង្រីកការផ្តល់ថ្នាំបង្ការ និងយុទ្ធនាការបង្កើនការផ្តល់ថ្នាំបង្ការជាប្រចាំនៅទូទាំងប្រទេសនៅក្នុងសហគមន៍ដែលត្រូវបានកំណត់ថាមានហានិភ័យខ្ពស់។
- អាទិភាពនានាផ្តល់ដោយការពិនិត្យគុណភាពការងារដែលបានអនុវត្តរួមគ្នាប្រចាំឆ្នាំ រួមមានការពង្រីកទីតាំងគ្រប់គ្រងកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរនៅតាមសម្បទាសុខភាព ការកែលម្អគុណភាពនៃការប្រឹក្សា និងសេវាកសាងផែនការគ្រួសារ ដែលរួមទាំង ការកសាងផែនការគ្រួសារដែលត្រូវការឲ្យមានការព្យាករណ៍ ការកែលម្អសម្បទាសុខភាពដើម្បីផ្តល់សេវាពេញលេញសម្រាប់ការរំលូតកូន ស្របតាមច្បាប់ស្តីពីការពន្លូតកូន (សម្បទាសុខភាពចំនួន 580 រហូតដល់ឆ្នាំ 2016) ការត្រួតពិនិត្យដើម្បីគាំទ្រ និងអនុវត្តបន្តនៅក្រោយបានទទួលការបណ្តុះបណ្តាល ការរក្សាវិសាលភាពគ្របដណ្តប់ឲ្យនៅកម្រិតខ្ពស់សម្រាប់ការទប់ស្កាត់ករណីចម្លងមេរោគអេដស៍ពីម្តាយទៅកូន (PMTCT) ។
- ការបង្កើនវត្តមានមណ្ឌលស្តុកទុករក្សាទុកឈាមសម្រាប់សេវា/សម្ភពសង្គ្រោះបន្ទាន់ និងថែទាំទារក (EmONC) ការពង្រឹងការអនុវត្តគោលការណ៍ណែនាំ សម្រាប់ការផ្សព្វផ្សាយដល់មូលដ្ឋាន និងយុទ្ធសាស្ត្រសម្រាប់ករណីមានហានិភ័យខ្ពស់ ការពង្រឹងសមត្ថភាព និងជំនាញឆ្មប ដើម្បីកែលម្អគុណភាពនៃការផ្តល់ប្រឹក្សា និងសេវាកម្ម RMNH ការអភិវឌ្ឍសមត្ថភាពសម្រាប់ការឆ្លើយតបនឹងអំពើហឹង្សាមកលើស្ត្រី នៅក្នុងវិស័យសុខាភិបាល។
- ធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ សម្រាប់កិច្ចផ្តួចផ្តើមដែលផ្តល់ផលរហ័សដើម្បីកាត់បន្ថយមរណភាពមាតា និងទារក និងឯកសារណែនាំ និងគោលការណ៍ណែនាំសម្រាប់ការពន្យាកំណើត ផែនការកែលម្អសេវាសម្ភពសង្គ្រោះបន្ទាន់ និងថែទាំទារកសម្រាប់ឆ្នាំ 2016 – 2020 បន្តដោយការបណ្តុះបណ្តាល ការណែនាំ និងការតាមដាន។

## មេរោគអេស៍/ជម្ងឺអេដស៍ ៖

- បន្តការតស៊ូមតិដើម្បីស្វែងរកមូលនិធិទាំងពីប្រភពជាតិ និងពីខាងក្រៅសម្រាប់ការឆ្លើយតបនឹងបញ្ហាមេរោគអេដស៍។
- បន្តគាំទ្រដល់រដ្ឋាភិបាលដើម្បីអនុម័តច្បាប់ស្តីពីការចេញអាជ្ញាប័ណ្ណជាចាំបាច់ ដើម្បីធានាថា កម្ពុជានៅតែបាន

ទទួលថ្នាំដែលមានថ្លៃទាបសម្រាប់ព្យាបានអ្នកជម្ងឺអេដស៍ និងជម្ងឺឆ្លង និងជម្ងឺមិនឆ្លងដទៃទៀត។

- ផ្ដោតលើគំរូនៃការផ្ដល់សេវាចម្រុះ និងបែបថ្មីដើម្បីឲ្យមានឥទ្ធិពល ដែលរួមទាំងជាមួយការបន្តភាពជាដៃគូរវាង រដ្ឋាភិបាល សង្គមស៊ីវិល និងការចូលរួមរបស់សហគមន៍។
- ការអនុវត្ត និងការតាមដានវិធានការក្នុងវិស័យសុខាភិបាលដែលបានចាត់ជាអាទិភាព និងដែលបន្សុីគ្នាសម្រាប់ ឆ្លើយតបនឹងបញ្ហាមេរោគអេដស៍ គឺជាវិស័យអាទិភាពចំបងមួយនៃការគាំទ្រដើម្បីឈានទៅលុបបំបាត់ករណីឆ្លង មេរោគអេដស៍ថ្មីៗ រហូតដល់ឆ្នាំ ២០២០ ប្រកបដោយនិរន្តរភាព។
- ការដាក់ឲ្យប្រតិបត្តិការផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយគ្រោះថ្នាក់ ជាពិសេស យុទ្ធសាស្ត្រដើម្បីបង្កើនវិសាល ភាពគ្របដណ្ដប់នៃកម្មវិធីម្ទុល និងសឺរ៉ាំងតាមវិធីដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល។
- ធ្វើការស្រាវជ្រាវអំពីការឆ្លងមេរោគអេដស៍ ដែលទាក់ទងនឹងប្រតិបត្តិករក្រៅប្រព័ន្ធដែលគ្មានអាជ្ញាប័ណ្ណ ដោយ រៀនសូត្រពីករណីនៃការឆ្លងមេរោគអេដស៍ក្នុងខេត្តបាត់ដំបង។
- បន្តផ្ដល់ការគាំទ្រពេញលេញដល់អាទិភាពចំនួនបួននៃផែនការសកម្មភាពជាតិយុវជន ពោលគឺ ការអប់រំ ការងារ ភាពជាអ្នកស្ម័គ្រចិត្ត និង សុខភាព ដែលរួមទាំង សុខភាពខាងផ្លូវភេទ និងសុខភាពបន្តពូជផងដែរ។
- គាំទ្រដល់ការរួមបញ្ចូលការកសាងផែនការគ្រួសារនៅក្នុងអន្តរាគមន៍ប្រឆាំងមេរោគអេដស៍ / ជំងឺអេដស៍ក្នុងក្រុម ពលរដ្ឋដែលមានការប្រឈមបំផុត ដូចជា បុគ្គលិកក្នុងវិស័យបម្រើការកំសាន្ត។

**អាហារូបត្ថម្ភ ៖**

- បន្តការតស៊ូមតិ និងការគាំទ្រដើម្បីជានានិរន្តរភាពនៃការផ្គត់ផ្គង់សម្រាប់អន្តរាគមន៍អាហារូបត្ថម្ភ ដោយការលើក ទឹកចិត្តដល់រដ្ឋាភិបាល ដើម្បីរួមបញ្ចូលសមាសជាតុផ្សំសំខាន់ៗសម្រាប់អាហារូបត្ថម្ភ ទៅក្នុងបញ្ជីថ្នាំសំខាន់ៗ។
- យោងតាមផែនទីបង្ហាញផ្លូវដើម្បីលទ្ធផលរហ័សសម្រាប់កែលម្អអាហារូបត្ថម្ភឆ្នាំ 2014-2020 សមាសភាគចំនួន ប្រាំ ត្រូវបានជ្រើសរើសជាអន្តរាគមន៍អាទិភាព៖ ការប្រឹក្សាអំពីអាហារូបត្ថម្ភ និងការបំពេញបន្ថែមមីក្រូសារជាតុ ការព្យាបាលកុមារដែលស្គាំងស្គមធ្ងន់ធ្ងរ ការផ្ដល់មីក្រូសារជាតុសម្រាប់ទប់ស្កាត់ និងយុទ្ធសាស្ត្រព្យាបាល និងការ ប្រាស្រ័យទាក់ទងដើម្បីកែប្រែឥរិយាបថ ដែលផ្ដោតលើឱកាសសម្រាប់រយៈពេល 1.000 ថ្ងៃ។

**ទឹកស្អាត និងអនាម័យ ៖**

- គាំទ្រការរៀបចំផែនការសកម្មភាពជាតិពេញលេញមួយសម្រាប់ WASH នៅជនបទ ដែលបង្កើតឡើងជាផែនការ ប្រតិបត្តិសម្រាប់ផែនការយុទ្ធសាស្ត្រជាតិ RWSSH ដែលបានប្រកាសនៅពេលថ្មីៗនេះសម្រាប់ឆ្នាំ 2014-2025 ។
- គាំទ្រដល់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីរៀបចំប្រព័ន្ធតាមដាន និងគ្រប់គ្រងព័ត៌មានវិស័យទឹកស្អាត និង អនាម័យ។
- គាំទ្រដល់ការវិភាគតាមជំពូកសេវាកម្មនិងការអនុវត្តខាងផ្នែក WASH នៅក្នុងមណ្ឌលសុខភាពសម្រាប់ការរៀបចំ គោលនយោបាយ និងការធ្វើសេចក្ដីសម្រេចដែលផ្អែកលើគោលនយោបាយ។
- គាំទ្រក្របខ័ណ្ឌ ECCD ដែលបានប្រកាសជាផ្លូវការនៅឆ្នាំ 2014 ក្រោមក្រសួងអប់រំ យុវជន និងកីឡា និងផែនការ យុទ្ធសាស្ត្រជាតិសម្រាប់សន្តិសុខស្បៀង និងកិច្ចផ្ដួចផ្ដើមអាហារូបត្ថម្ភនៅក្រោម CARD។
- បន្តគាំទ្រដល់សម្បទាអនាម័យ និងការរស់នៅស្អាត តាមរយៈការផ្ដល់កញ្ចប់សេវាអនាម័យ និងការរស់នៅស្អាត និងពង្រឹងទម្លាប់អនាម័យ និងការរស់នៅស្អាតប្រចាំថ្ងៃ នៅតាមសាលារៀន និងក្នុងសហគមន៍។

**ការអប់រំ ៖**

- ការគាំទ្របន្ថែមដើម្បីផ្ទេរកម្មវិធីអាហារូបករណ៍ទៅក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាល។

- បង្កើយផែនទីបង្ហាញផ្លូវសម្រាប់ការផ្តល់អាហារបន្ថែមនៅតាមសាលារៀន និងការអនុវត្តផែនទីនេះក្នុងឆ្នាំ 2015។
- ការស្វែងយល់បន្ថែមទៀតអំពីជម្រើសអនុវត្តសម្រាប់កម្មវិធីផ្តល់អាហារនៅតាមសាលារៀន រួមផ្សំជាមួយការតស៊ូមតិដើម្បីបង្កើនការផ្តល់មូលនិធិពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
- ពង្រឹងការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពផ្តល់អាហារតាមសាលារៀន ដែលរួមទាំង យន្តការសម្រាប់ធ្វើឲ្យក្រុមប្រឹក្សាឃុំចូលរួមបដិភាគពីសហគមន៍។/
- បន្តការគាំទ្រដល់ការអនុវត្ត CSE និងការគាំទ្រដល់ដំណើរការរបស់ MoEYS នៃការរួមបញ្ចូលខ្លឹមសារនៃ CSE ទៅក្នុងកម្មវិធីសិក្សានៅថ្នាក់ជាតិ។
- បន្តគាំទ្រដល់ការប្រឹក្សាតាមប្រព័ន្ធទូរស័ព្ទ (Inthanou) អន្តរាគមន៍តាមប្រព័ន្ធផ្សព្វផ្សាយ (ឡូយ ៩) ទាក់ទងនឹងសុខភាពខាងផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិរបស់ពលរដ្ឋវ័យក្មេង។
- គាំទ្រក្រសួង MoEYS និងសមាគមអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា ដើម្បីចាត់ចែងរៀបចំវេទិកាស្រាវជ្រាវការអប់រំដំបូងបង្អស់នៅកម្ពុជា (CERF)។
- គាំទ្រដល់ការអនុវត្តTPAP រួមផ្សំជាមួយការពង្រឹងការតស៊ូមតិដើម្បីបង្កើនការវិនិយោគពីរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍន៍នានា។
- អ.ស.ប និងបន្តគាំទ្រក្នុងការកសាងសមត្ថភាពថ្នាក់ជាតិ ដើម្បីសំរបសំរួលនិងអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្រ្តអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)។
- គាំទ្រដល់ការពង្រីក MSMEs តាមរយៈកម្មវិធីកសាងសមត្ថភាពដែលចំណាយទាប (CBED) និងការរួមបញ្ចូល ការអប់រំអំពីភាពជាសហគ្រិន (KAB) នៅក្នុងកម្មវិធីសិក្សានៅថ្នាក់ជាតិសម្រាប់កម្រិតមធ្យមសិក្សា។
- គាំទ្រដល់ការអនុវត្តរចនាសម្ព័ន្ធទទួលស្គាល់ជំនាញក្នុងវិស័យទេសចរណ៍ និងការសាងសង់នៅក្នុងបរិបទនៃសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

## *ការចំណាយសម្រាប់លទ្ធផល 2សម្រាប់ឆ្នាំ 2014 – 2015:*

**ចំណាយប៉ាន់ស្មានសម្រាប់ឆ្នាំ 2014: 25.808.409 ដុល្លាអាមេរិក**

**ចំណាយគ្រោងសម្រាប់ឆ្នាំ 2015: 28.295.540 ដុល្លាអាមេរិក**

**ការវិភាគបរិមាណ - សូចនាករដែលត្រូវតាមដានក្នុងឆ្នាំ 2014**

| ល.រ | សូចនាករ | ស្ថានភាព | ទិន្នន័យ | ឆ្នាំ 2014 | យោបល់ | គ្រោងសម្រាប់ឆ្នាំ 2015 |
|---|---|---|---|---|---|---|
| 2.5 | ភាគរយកុមារអាយុ 12-23 ខែដែលបានទទួលថ្នាំបង្ការគ្រប់មុខនៅអាយុ 1 ឆ្នាំ (កញ្ជ្រិល) (ភាគរយ, កញ្ជ្រិល) | គ្រោង | | | | 95 |
| | | ជាក់ស្តែង | 91 | 98 | | |
| 2.5 | ភាគរយកុមារអាយុ 12-23 ខែដែលបានទទួលថ្នាំបង្ការគ្រប់មុខនៅអាយុ 1 ឆ្នាំ (DPT) (ភាគរយ, DPT) | គ្រោង | | | | 95 |
| | | ជាក់ស្តែង | 92 | 94 | | |

| ល.រ | សូចនាករ | ស្ថានភាព | ទិន្នន័យ | ឆ្នាំ 2014 | យោបល់ | គ្រោងសម្រាប់ឆ្នាំ 2015 |
|---|---|---|---|---|---|---|
| 2.7 | សមាមាត្រនៃការសម្រាលកូនដោយមានជំនួយពីបុគ្គលិកជំនាញសុខាភិបាល ( ភាគរយ, វេជ្ជបណ្ឌិត ) | គ្រោង | | | | 87 |
| | | ជាក់ស្តែង | 58 | 86 | តួលេខនេះគឺជាចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ 2014។ លទ្ធផលផ្លូវការនៃសមិទ្ធផលនេះនឹងត្រូវបញ្ចេញនៅក្នុងសន្និបាតជាតិវិស័យសុខាភិបាល | |
| 2.9 | ចំនួន EmONC ជាមូលដ្ឋាន/ពេញលេញ (ក្នុងប្រជាជន500.000នាក់ ជាមូលដ្ឋាន ) | គ្រោង | | 3,5 | | 4 |
| | | ជាក់ស្តែង | 1,6 | 3,5 | | |
| 2.9 | ចំនួន EmONC ជាមូលដ្ឋាន/ពេញលេញ (ក្នុងប្រជាជន500.000នាក់ ពេញលេញ ) | គ្រោង | | 0,97 | | 1 |
| | | ជាក់ស្តែង | 0,9 | 0,97 | | |
| 2.12 | ភាគរយស្ត្រីមានផ្ទៃពោះ ដែលបានមកពិគ្រោះយោបល់ (ANC) បាន 2 ឬច្រើនដង (ភាគរយ) | គ្រោង | | 98 | | 100 |
| | | ជាក់ស្តែង | 80 | 98 | | |
| 2.19 | ភាគរយយុវវ័យនិងកុមារដែលមានផ្ទុកមេរោគអេដស៍នៅដំណាក់កាលខ្ពស់ ដែលបានទទួលការព្យាបាលប្រឆាំងវីរុស (ART) (ភាគរយ) | គ្រោង | | | | 95 |
| | | ជាក់ស្តែង | 92 | 85,4 | | |

# លទ្ធផលទី ៣ - សមភាពយេនឌ័រ

ត្រឹមឆ្នាំ ២០១៥ គម្លាតយេនឌ័រ ក្នុងចំណោមស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសទាំងអស់ មានការថយចុះ ហើយពួកគេនឹងកាន់តែទទួលបាន និងអាចប្រើប្រាស់សិទ្ធិរបស់ពួកគេប្រកបដោយសមភាព។

## *សេចក្តីផ្តើម*

សហប្រជាជាតិ គាំទ្រដល់ការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រ ហើយ និងកំពុងធ្វើការងារដើម្បីគាំទ្រឱ្យមានបរិយាកាសជំនួយសហប្រតិបត្តិការ ដែលមានលក្ខណៈសុខុដុមរមនីយកម្មរួមមួយ ដែលលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី, យន្តការបញ្ជ្រាបយេនឌ័រ, ការបន្តផ្តល់ភាពអង់អាចឱ្យស្ត្រីអាចប្រើប្រាស់សិទ្ធិរបស់ពួកគេ ដើម្បីទទួលបានការងារពេញលេញ និងប្រកបដោយផលិតភាព, ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងកិច្ចការសាធារណៈ និងការឆ្លើយតបគ្រប់ជ្រុងជ្រោយលើការទប់ស្កាត់ជាមុនចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។សហប្រជាជាតិជាសហអ្នកសម្របសម្រួលក្រុមការងារ បច្ចេកទេស យេនឌ័រ (TWGG) និងអនុក្រុមឆ្លើយតប ចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងផ្តល់ភាពអង់អាចផ្នែក សេដ្ឋកិច្ចរបស់ស្ត្រី របស់ក្រុមការងារនេះ។ សហប្រជាជាតិក៏កំពុងគាំទ្រដល់ការបង្កើតអភិក្រមកម្មវិធី (PBA) ដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រផងដែរ។

## *លទ្ធផលឆ្នាំ ២០១៤*

នៅក្នុងឆ្នាំ ២០១៤ សហប្រជាជាតិបានបន្តការគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ក្រសួងកិច្ចការនារី ក្នុងការគាំទ្រ និងសម្របសម្រួលកិច្ចពិគ្រោះយោបល់គោលនយោបាយស្តីពីអាទិភាពជាតិខាងសមភាពយេនឌ័រ។ កន្លងមក មានការសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងការឆ្លើយតបចំពោះវិសមភាពយេនឌ័រ និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ តាមរយៈការរៀបចំបញ្ចប់ និងការអនុម័តលើផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី ២។ ការគាំទ្ររបស់សហប្រជាជាតិ បានរួមចំណែកអភិវឌ្ឍសមត្ថភាពរបស់យន្តការស្ត្រីនៅថ្នាក់ជាតិបន្ថែមទៀត នៅក្នុងការប្រើប្រាស់អភិក្រមកម្មវិធី ដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រ។ លទ្ធផលសំខាន់ៗ រួមមាន ការរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រនារីរតនៈ ៤ និងសង្ខេបគោលនយោបាយចំនួន ១០ សម្រាប់អមជាមួយនឹងផែនការយុទ្ធសាស្ត្រនេះ ដែលជាមូលដ្ឋានសម្រាប់ធ្វើការបញ្ជ្រាបយេនឌ័រ នៅតាមក្រសួងស្ថាប័នពាក់ព័ន្ធនានា។ ជាមួយនឹងការគាំទ្ររបស់សហប្រជាជាតិ មានការសម្រេចបាននូវវឌ្ឍនភាពជាច្រើន ដូចជា ការរៀបចំរបាយការណ៍វាយតម្លៃយេនឌ័រនៅកម្ពុជាទី ៣ (ដែលនឹងចេញផ្សាយនៅក្នុងឆ្នាំ ២០១៥) និងការអភិវឌ្ឍសមត្ថភាពផ្នែកអភិក្រមកម្មវិធី ដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រ ដែលអភិក្រមនេះត្រូវអនុវត្តចំពោះការងារចំនួនពីរ ៖ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ លើសពីនេះ សហប្រជាជាតិបានជួយគាំទ្រដល់ការរៀបចំរបាយ

ការណ៍មួយរបស់ក្រសួងកិច្ចការនារីអំពីវឌ្ឍនភាព ដែលសម្រេចបាន នៅក្នុងការអនុវត្តផែនការសកម្មភាពទីក្រុងប៉េកាំង ដែលជាផ្នែកមួយនៃដំណើរការពិនិត្យឡើងវិញនៅថ្នាក់តំបន់ និងថ្នាក់សកល។

សហប្រជាជាតិបន្តគាំទ្រដល់កិច្ចពិគ្រោះយោបល់គោលនយោបាយស្តីពីបញ្ហាយេនឌ័រសំខាន់ៗ នៅក្នុងគ្រប់វិស័យទាំងអស់ តាមរយៈក្រុមការងារបច្ចេកទេសយេនឌ័រ អនុក្រុមការងារឆ្លើយតបចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងអនុក្រុមការងារមួយទៀតខាងផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី របស់ក្រុមការងារបច្ចេកទេសយេនឌ័រ ក៏ដូចជាយន្តការក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAG)។ លទ្ធផលសំខាន់ៗ រួមមាន ការរៀបចំនូវផ្នែកមួយអំពីសមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងការបង្កើតសូចនាករពិនិត្យតាមដានរួមគ្នា នៅកម្រិតលទ្ធផលរយៈពេលមធ្យម សម្រាប់ឆ្នាំ ២០១៤-២០១៨ និងកម្រិតជាតុចេញ សម្រាប់ឆ្នាំ ២០១៤-២០១៥។ លើសពីនេះ ការគាំទ្ររបស់សហប្រជាជាតិបានរួមចំណែកដល់ការរៀបចំផ្នែកមួយអំពីសមភាពយេនឌ័រ សម្រាប់*ចក្ខុវិស័យ ២០៣០* របស់ប្រទេសកម្ពុជា ឯកសារជាតុចូលទី ៣ ស្តីពី*ការគ្រប់គ្រងការអភិវឌ្ឍ ក្នុងដំណើរឈានឆ្ពោះទៅកាន់ឆ្នាំ ២០៣០* ដែលត្រូវបានរៀបចំឡើង ក្រោមការងារណែនាំរបស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។

ដោយឡែកនៅថ្នាក់ក្រសួងវិញ ជាមួយនឹងការគាំទ្រពីសហប្រជាជាតិ ក្រសួងចំនួន ២៣ បានបញ្ចូលផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ទៅក្នុងផែនការប្រតិបត្តិឆ្នាំ ២០១៥ របស់ខ្លួន ហើយសមត្ថភាពរបស់ក្រសួងនានាត្រូវបានពង្រឹងបន្ថែមទៀត ពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងយេនឌ័រ គោលនយោបាយដែលអនុលោមទៅតាមអនុសញ្ញា CEDAW ការអនុវត្តកម្មវិធី ការរៀបចំថវិកា ការពិនិត្យតាមដាន និងការវាយតម្លៃ តាមរយៈការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេស។ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សមត្ថភាព ដែលគាំទ្រដោយសហប្រជាជាតិ រួមមាន ការគាំទ្រដល់ការពង្រឹងការពិនិត្យតាមដានថ្នាក់ជាតិ និងការរាយការណ៍របស់ប្រទេសអំពីការអនុវត្ត អនុសញ្ញា CEDAW និងសិទ្ធិមនុស្សរបស់ស្ត្រី, ការពិនិត្យឡើងវិញលើច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងច្បាប់ពាក់ព័ន្ធនឹងពលករ ទេសន្តរប្រវេសន៍ យោងទៅតាមក្របខ័ណ្ឌច្បាប់ និងស្តង់ដាអន្តរជាតិ, ការបញ្ជ្រាបអំពើហិង្សា លើស្ត្រីទៅក្នុងដំណើរការនៃការរៀបចំផែនការនៅមូលដ្ឋាន, ការពង្រឹងការយល់ដឹងរបស់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានផ្សេងទៀតអំពីច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ, ការពង្រឹងការយល់ដឹងអំពីស្តង់ដាអន្តរជាតិ និងការឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាលចំពោះអំពើហិង្សាលើស្ត្រី និងកុមារ, ការប៉ាន់ប្រមាណចំណាយរបស់អន្តរាគមន៍ឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងការពិនិត្យតាមដានលើការឆ្លើយតប ចំពោះមេរោគអេដស៍ តាមបែបឆ្លើយតបចំពោះយេនឌ័រ។ ជាមួយនឹងការគាំទ្រពីសហប្រជាជាតិ អន្តរាគមន៍ពាក់ព័ន្ធ ជាមួយនឹងយេនឌ័រជាច្រើនត្រូវបានអនុវត្ត ដោយក្រសួងពាក់ព័ន្ធ ដូចជា អន្តរាគមន៍ ដែលអនុវត្តដោយ គ.ជ.អ.ប ក្នុងគោលបំណងពង្រឹងសកម្មភាពរបស់អ្នកដឹកនាំឃុំ ដើម្បីទប់ស្កាត់រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី និងកុមារ ជាការឆ្លើយតបចំពោះសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ CEDAW និងដោយផ្អែកទៅតាមប្បញ្ញត្តិរដ្ឋបាលទូទៅ របស់ក្រសួងមហាផ្ទៃ ក៏ដូចជាអន្តរាគមន៍របស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងការផ្តល់ការអប់រំអំពីផ្លូវភេទគ្រប់ជ្រុងជ្រោយ ហើយដែលបានសម្រេចនូវលទ្ធផលជាច្រើន ដូចជា ការប្រកាសផ្សព្វផ្សាយពីកូនសៀវភៅស្តីពីភាពពេញវ័យរបស់ក្មេងស្រី ជាដើម។

ដោយឡែក ចំពោះការចូលរួម និងការដឹកនាំរបស់ស្ត្រីវិញ ការគាំទ្ររបស់សហប្រជាជាតិបានរួមចំណែកពង្រឹងសមត្ថភាពរបស់ស្ត្រី ដែលជាអ្នកដឹកនាំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលើកកម្ពស់កិច្ចពិគ្រោះយោបល់អំពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ។ លទ្ធផល ដែលសម្រេចបាន រួមមាន អនុសាសន៍ ដែលផ្តល់ដោយអ្នកតស៊ូមតិ ដើម្បីសមភាពយេនឌ័រ អំពីស្ត្រី និងសុខភាព ការអប់រំ នយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត និងសេដ្ឋកិច្ច ដែលត្រូវបានចែករំលែកជាមួយនឹងក្រសួងកិច្ចការនារី និងទទួលបានការអនុម័តយល់ព្រមពីក្រសួងកិច្ចការនារី ដើម្បីចាត់វិធានការបន្ថែមទៀត។ លើសពីនេះ អ្នកតស៊ូមតិ ដើម្បីសមភាពយេនឌ័រ ក៏បានរៀបចំញត្តិមួយស្តីពីការបង្កើនការចូល រួមក្នុងវិស័យនយោបាយ ភាពជាតំណាង និងតួនាទីរបស់ស្ត្រីកម្ពុជាជាអ្នកដឹកនាំផងដែរ ហើយញត្តិនេះត្រូវបានផ្ញើទៅកាន់ក្រសួងចំនួន ៤ និងទៅកាន់គណបក្សនយោបាយធំៗទាំងពីរ ដែលមានអសនៈនៅក្នុងរដ្ឋសភា។ សកម្មភាពជាក់លាក់រួមមាន ការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ និងការតស៊ូមតិ ដល់ស្ត្រីជាសមាជិកក្រុមប្រឹក្សាខេត្ត ស្តីពីការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការបណ្តុះបណ្តាលដល់សមាជិកគណៈកម្មាធិការឃុំទទួលបន្ទុកស្ត្រី និងកុមារ និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ស្តីពីការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រី កុមារ យុវជន និង ក្រុមងាយរងគ្រោះ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន, ការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីវ័យក្មេង ខាងជំនាញដឹកនាំ និងការបណ្តុះបណ្តាល និងការរៀបចំសម្ភារអប់រំផ្សព្វផ្សាយ ដែលផ្តោតគោលដៅលើស្ត្រីរស់នៅជាមួយមេរោគអេដស៍ និងក្រុមប្រឈមនឹងការឆ្លងមេរោគអេដស៍ ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិ និងផ្តល់លទ្ធភាពឱ្យពួកគេចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីបញ្ហា ដែលជាក្តីបារម្ភរបស់ពួកគេ។

ដោយឡែក ខាងការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការគាំទ្ររបស់សហប្រជាជាតិបានរួមចំណែកធ្វើឱ្យមានការតាក់តែងគោលនយោបាយផ្អែកតាមភ័ស្តុតាង និងការលើកកម្ពស់សិទ្ធិរបស់ស្ត្រីក្នុងការងារ តាមរយៈការផ្តល់ជំនួយបច្ចេកទេសដល់ការរៀបចំយុទ្ធសាស្ត្រប្រតិបត្តិស្តីពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (ដែលនឹងដាក់ឱ្យអនុវត្ត នាពេលខាងមុខនេះ) គាំទ្រដល់ការបោះពុម្ពផ្សាយរួមគ្នាជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីសមភាពយេនឌ័រ នៅក្នុងទីផ្សារការងារ នៅក្នុងប្រទេសកម្ពុជា និងមគ្គុទេសក៍វ៉ែយឆ្លាតចំនួន ៣ សម្រាប់សហជីពនៅកម្ពុជាអំពីការមិនរើសអើង និងសមភាព ការការពារមាតុភាព និងសកម្មភាពប្រឆាំងនឹងការបៀតបៀនផ្លូវភេទនៅកន្លែងការងារ។ ជាលទ្ធផលនៃការគាំទ្ររបស់សហប្រជាជាតិ បណ្តាញពលករកម្ពុជានៅក្នុងប្រទេសឥណ្ឌូនេស៊ីត្រូវបានបង្កើតឡើង ដែលផ្តល់លទ្ធភាពឱ្យសមាជិករបស់បណ្តាញនេះលើកឡើងពីសេចក្តីត្រូវការរបស់ពួកគេ និងធ្វើការចរចាប្រកបដោយប្រសិទ្ធភាពជាមួយនឹងនិយោជក ដើម្បីទទួលបានលក្ខខណ្ឌការងារសមរម្យ។ នៅកម្រិតមូលដ្ឋានវិញ ការគាំទ្ររបស់សហប្រជាជាតិក៏បានរួមចំណែកនាំឱ្យមានការបង្កើតគំរូអាជីវកម្មទៅតាមតម្រូវការជាក់ស្តែង សម្រាប់ក្រុមផលិតករជាស្ត្រី។

ជាមួយនឹងការគាំទ្ររបស់សហប្រជាជាតិ ក្រសួងកិច្ចការនារីបានផ្តួចផ្តើមរៀបចំផែនការអនុវត្ត សម្រាប់ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធមកពីគ្រប់វិស័យទាំងអស់នៅក្នុងការពិគ្រោះយោបល់កន្លងមក។ សមិទ្ធផលសំខាន់ៗ ដែលអាចផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធីផ្អែកតាមភ័ស្តុ

តាងជាក់ស្តែង សំដៅឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងកុមារ រួមមាន ការប្រកាសចាប់ផ្តើមធ្វើការសិក្សាប្រេវ៉ាឡង់ថ្នាក់ជាតិលើអំពើហិង្សាលើកុមារ ការផ្តួចផ្តើមរៀបចំការសិក្សាប្រេវ៉ាឡង់ថ្នាក់ជាតិលើអំពើហិង្សាលើស្ត្រី (ដែលនឹងធ្វើឡើង នាពេលខាងមុខនេះ) និងការដាក់បញ្ចូលម៉ូឌុលអំពើហិង្សាក្នុងគ្រួសារ ក្នុងការអង្កេតសុខភាព និងប្រជាសាស្ត្រ ឆ្នាំ ២០១៤។ សកម្មភាពសំខាន់ៗ ដែលគាំទ្រដោយសហប្រជាជាតិ រួមមាន យុទ្ធនាការ ១៦ ថ្ងៃ បញ្ចប់អំពើហិង្សាលើស្ត្រី ដែលត្រូវបានអនុវត្តដោយដៃគូចំនួន ៣៣ មកពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហប្រជាជាតិ និងការរៀបចំឯកសារបោះពុម្ពផ្សាយ ក្រោមចំណងជើង *Being LGBT in Asia: Cambodia Country Report* ដោយការចូលរួមពិគ្រោះយោបល់។ ជាមួយនឹងការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុរបស់សហប្រជាជាតិ គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រី និងកុមារ នៅក្នុងប្រព័ន្ធសុខាភិបាលដំបូង ត្រូវបានរៀបចំឡើង ហើយ សៀវភៅណែនាំស្តីពីការបញ្ចប់អំពើហិង្សាលើស្ត្រី - មគ្គុទេសក៍ស្តីពីការធ្វើការងារជាមួយនឹងអ្នកស្ម័គ្រចិត្ត ត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តល្អៗដែលមាន។

## បញ្ហាប្រឈម

ដូចលើកឡើងនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានឆ្នាំ ២០១៣ របស់គណៈកម្មាធិការលុបបំបាត់ ទម្រង់ការរើសអើងប្រឆាំងស្ត្រីភេទ បញ្ហាប្រឈមជាអាទិភាព ដែលពាក់ព័ន្ធជាមួយនឹងសមភាពយេនឌ័រ រួមមាន ៖

- រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មានប្រព័ន្ធជំនួយផ្លូវច្បាប់ ដែលធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានលើលទ្ធភាពទទួលបានយុត្តិធម៌របស់ស្ត្រី។
- នៅមិនទាន់មានការសហការគ្នាឱ្យបានគ្រប់គ្រាន់ រវាងយន្តការជាតិសម្រាប់លើកកម្ពស់ស្ត្រី និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ។
- ស្ត្រីនៅតែពុំមានតំណាងគ្រប់គ្រាន់ នៅគ្រប់កម្រិតទាំងអស់នៃវិស័យនយោបាយ និងវិស័យសាធារណៈ (កថាខណ្ឌ ២៨) ហើយចាំបាច់ត្រូវតែមានយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនភាពជាតំណាងរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។
- ស្ត្រីបន្តប្រមូលផ្តុំ នៅក្នុងវិស័យការងារពុំមានជំនាញ ហើយលក្ខខណ្ឌការងាររបស់ស្ត្រី ដែលធ្វើការងារនៅក្នុងឧស្សាហកម្មកាត់ដេរ និងស្ត្រីដែលធ្វើការងារជាអ្នកបម្រើតាមផ្ទះ នៅមានកម្រិតខ្សោយនៅឡើយ។
- ស្ត្រីនៅមានលទ្ធភាពតិចតួច ក្នុងការទទួលបានដីធ្លី និងកម្មសិទ្ធិក្នុងការកាន់កាប់ដីធ្លី ត្រូវទទួលរងការបាត់បង់ទីលំនៅ និងការបណ្តេញចេញ និងខ្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសេវាសំខាន់ៗ នៅទីតាំងថ្មី ដែលពួកគេផ្លាស់ទៅនោះ។

លើសពីនេះ បញ្ហាប្រឈម ដែលជួបប្រទះ នៅក្នុងឆ្នាំ ២០១៤ រួមមាន ៖

- ភាពចាំបាច់ ដើម្បីបញ្ចប់ផែនការយុទ្ធសាស្ត្រនារីរតនៈ ៤ ឱ្យបានទាន់ពេលវេលា និងភាពចាំបាច់ ដើម្បីធានាឱ្យមានភាពជាម្ចាស់ និងសមត្ថភាពក្នុងប្រទេស លើការរៀបចំឯកសារគោលនយោបាយនេះ។
- ការផ្តោតការយកចិត្តទុកដាក់តិចតួចលើអន្តរាគមន៍បញ្ជ្រាបយេនឌ័រ ធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ក្រសួង

ពាក់ព័ន្ធ ក្នុងការអនុវត្តអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ជាការឆ្លើយតបចំពោះបញ្ហាសមភាពយេនឌ័រសំខាន់ៗ ដែលទាមទារឱ្យមានការបណ្តុះបណ្តាល និងអន្តរាគមន៍ ដែលមានលក្ខណៈឯកទេសជាក់លាក់ ទៅតាមគម្រោង និងវិស័យ។

- គុណភាព និងភាពអាចជឿទុកចិត្តបាននៃទិន្នន័យអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅមានកម្រិត។ ទិន្នន័យទាំងនេះគឺជាទិន្នន័យពីប្រភពចម្រុះ ហើយត្រូវបានកត់ត្រាដោយអ្នកពាក់ព័ន្ធជាច្រើន។ លើសពីនេះ នៅមិនទាន់មានការប្រមូលទិន្នន័យជាប្រចាំនៅថ្នាក់ជាតិ ដើម្បីចុះ និងតាមដានករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅឡើយ។
- ការធានាយ៉ាងណាឱ្យភាពងាយរងគ្រោះពាក់ព័ន្ធនឹងយេនឌ័រ ក្នុងទម្រង់ចម្រុះ ត្រួតគ្នា ទទួលបានការយកចិត្តទុកដាក់ នៅក្នុងការអនុវត្តកម្មវិធីសមភាពយេនឌ័រ ដូចជា ទម្រង់អំពើហិង្សា ផ្អែកទៅតាមអាយុ ជាតិពន្ធុ ពិការភាព ចំណង់ចំណូលចិត្តក្នុងការរួមភេទ និងអត្តសញ្ញាណយេនឌ័រ។ ចំណុចនេះក៏ត្រូវបានទទួលស្គាល់ នៅក្នុងសង្ខេបគោលនយោបាយរបស់ក្រសួងកិច្ចការនារីស្តីពីក្រុមស្ត្រី និងក្មេងស្រីងាយគ្រោះផងដែរ។

## *អាទិភាព សម្រាប់ឆ្នាំ ២០១៥*

- ពង្រឹងកិច្ចពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធចម្រុះ ស្តីពីបញ្ហាសមភាពយេនឌ័រ និងសិទ្ធិស្ត្រីសំខាន់ៗ ដូចជា នៅក្នុងបរិបទអនុសញ្ញា CEDAW ផែនការសកម្មភាពទីក្រុងប៉េកាំង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលនឹងត្រូវដាក់ចេញនាពេលខាងមុខ។ គាំទ្រជាក់លាក់ដល់ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរួមចំណែកដល់ការរៀបចំរបៀបវារៈសកល និងថ្នាក់តំបន់ សំដៅសម្រេចឱ្យបាននូវ សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី តាមរយៈដំណើរការនៃសម័យប្រជុំលើកទី ៥៩ នៃគណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី និងដើម្បីជម្រុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ នៅក្នុងកិច្ចពិគ្រោះយោបល់បន្ត នៅថ្នាក់ជាតិ។
- ធ្វើការងារជាមួយនឹងរដ្ឋាភិបាល ដើម្បីកែលំអការវាយតម្លៃជាលក្ខណៈប្រព័ន្ធលើវឌ្ឍនភាព ដែលសម្រេចបានពាក់ព័ន្ធនឹងអាទិភាពរបស់ជាតិខាងសមភាពយេនឌ័រ ដូចជា តាមរយៈការផ្តល់ការគាំទ្រដល់ការរៀបចំក្របខ័ណ្ឌ និងវិធីសាស្ត្រពិនិត្យតាមដាន និងវាយតម្លៃរួមមួយ សម្រាប់ផែនការយុទ្ធសាស្ត្រនារីរតនៈ ៤ និងការដាក់បញ្ចូលសមាសភាគយេនឌ័រនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ទៅក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ជាតិ។
- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈ ៤, ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងយុទ្ធសាស្ត្រប្រតិបត្តិស្តីពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងគាំទ្រដល់ការបញ្ចប់ការប៉ាន់ប្រមាណចំណាយនៃការអនុវត្តផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងការរៀបចំ បញ្ចប់ និងការចាប់ផ្តើមអនុវត្តផែនការអនុវត្តនេះ និងគាំទ្រដល់ការរៀបចំបញ្ចប់ និងការចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រប្រតិបត្តិស្តីពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។

- បន្តធ្វើការងារជាមួយនឹងក្រសួងពាក់ព័ន្ធ ដើម្បីធ្វើការបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលនយោបាយ ផែនការ និងថវិការបស់ពួកគេ ដូចជា ផ្តល់ការគាំទ្រដល់ក្រុមសកម្មភាពបញ្ជ្រាបយេនឌ័រ (GMAGs) ដើម្បីដាក់បញ្ចូលសកម្មភាពជាក់លាក់ ដែលត្រូវបានប៉ាន់ប្រមាណចំណាយត្រឹមត្រូវ យកចេញពីផែនការយុទ្ធសាស្ត្រនារីរតនៈ ៤ ផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីទី ២ និងយុទ្ធសាស្ត្រប្រតិបត្តិស្តីពីការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ទៅក្នុងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ និងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រទូទៅរបស់ក្រសួងពាក់ព័ន្ធទាំងនោះ។
- បង្កើនការយល់ដឹងអំពីការរៀបចំថវិកាឆ្លើយតបយេនឌ័រ ការគាំទ្រដល់ការធ្វើការសិក្សាស្រាវជ្រាវអំពីការប្រើប្រាស់ធនធានរបស់ឃុំ ដោយក្រុមប្រឹក្សាឃុំ ដោយផ្តោតការយកចិត្តទុកដាក់លើការវិនិយោគលើស្ត្រី កុមារ និងយុវជន។
- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ក្នុងការផ្សព្វផ្សាយលទ្ធផលរកឃើញនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា និងលទ្ធផលរកឃើញនៃការសិក្សាអំពីប្រេវ៉ាឡង់អំពើហិង្សាលើស្ត្រី (ដែលនឹងមាននាពេលខាងមុខ) និងលទ្ធផលរកឃើញពាក់ព័ន្ធនឹងយេនឌ័រនៃជំរឿនកសិកម្មទូទាំងប្រទេស ដែលធ្វើឡើងជាលើកដំបូង។
- គាំទ្រដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីរៀបចំនូវផែនទីបង្ហាញផ្លូវមួយ ក្នុងការឈានទៅផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការងារបម្រើតាមផ្ទះ (C189)។
- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីបង្កើនការយល់ដឹងរបស់ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តជា សាធារណៈ តាមរយៈអន្តរាគមន៍កសាងសមត្ថភាព ដោយផ្តោតគោលដៅលើអ្នកដឹកនាំជាស្ត្រី និងគាំទ្រក្នុងការ រៀបចំឱ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនចំនួនស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងនៅក្នុងបរិបទនៃសន្និសីទជាតិលើកទី ៣ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងការចូលរួមក្នុងវិស័យនយោបាយ ដែលគ្រោងនឹងធ្វើឡើង នៅក្នុងឆ្នាំ ២០១៥។
- លើកកម្ពស់កិច្ចខិតខំប្រឹងប្រែង ដើម្បីកៀងគរបុរសឱ្យធ្វើជាអ្នកតស៊ូមតិ ដើម្បីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។
- គាំទ្រដល់ក្រសួងសុខាភិបាល ដើម្បីប្រកាសផ្សព្វផ្សាយ និងអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រី និងកុមារ នៅក្នុងប្រព័ន្ធសុខាភិបាល និងរៀបចំសៀវភៅណែនាំគ្លីនិកថ្នាក់ជាតិ ក៏ដូចជា កម្មវិធីសិក្សា និងឧបករណ៍លើកកម្ពស់សុខភាព សម្រាប់ប្រើប្រាស់អមជាមួយនឹងសៀវភៅណែនាំគ្លីនិកនេះ។
- គាំទ្រដល់រដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងលទ្ធផលរកឃើញនៃការអង្កេតលើអំពើហិង្សាលើកុមារ តាមរយៈ អន្តរាគមន៍បណ្តុះបណ្តាលគ្រូ បំណិនជីវិត និងអភិវឌ្ឍន៍កុមារតូច។

### *ចំណាយសម្រាប់លទ្ធផលទី ៣ សម្រាប់ឆ្នាំ ២០១៤-២០១៥ ៖*

- ចំណាយប៉ាន់ស្មាន សម្រាប់ឆ្នាំ ២០១៤ ៖ ៤ ៧៥៨ ១០៧ ដុល្លារ
- ចំណាយ ដែលត្រូវបានព្យាករ សម្រាប់ឆ្នាំ ២០១៥ ៖ ៧ ១២៨ ៩៩៥ ដុល្លារ

### *ការវិភាគបែបបរិមាណ - សូចនាករ ដែលត្រូវពិនិត្យតាមដាន នៅក្នុងឆ្នាំ ២០១៤*

| ល.រ. | សូចនាករ | ស្ថានភាព | ទិន្នន័យគោល | ២០១៤ | យោបល់ | ចំណុចដៅក្នុងផែនការ ២០១៥ |
|---|---|---|---|---|---|---|
| ៣.១ | សន្ទស្សន៍អភិវឌ្ឍន៍ពាក់ព័ន្ធនឹង យេនឌ័រ (GDI) របស់ សហប្រជាជាតិ (សន្ទស្សន៍) | ក្នុង ផែនការ | | | | |
| | | ជាក់ស្តែង | ០,៥៩៤ | ០,៥០៥ | នេះគឺជា តួលេខ សម្រាប់ GII ។ ចាំបាច់ត្រូវ ធ្វើការកែ សម្រួល ចំណុចដៅ នៅពេលដែល សូចនាករនេះ ត្រូវបានកែ សម្រួល។ | |
| ៣.៦ | ភាគរយនៃផែនការប្រចាំឆ្នាំកម្រិតវិស័យនៅថ្នាក់ជាតិ ដែលត្រូវបានប៉ាន់ប្រមាណចំណាយរួច ដែលឆ្លើយតបចំពោះយេនឌ័រ ទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ត្រូវបានរៀបចំឡើងរួមគ្នាជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភាគរយ) | ក្នុង ផែនការ | | | | |
| | | ជាក់ស្តែង | ១០ | ក្រសួងពាក់ព័ន្ធចំនួន ៨ បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំថវិកាឆ្លើយតបនឹង យេនឌ័រ | | |
| ៣.៧ | ភាគរយនៃក្រុមការងារបច្ចេកទេស (TWGs) ដែលមាន ក) ផែនការការងារ និង ខ) សូចនាករពិនិត្យតាមដានរួមគ្នា ដែលឆ្លើយតប ចំពោះយេនឌ័រ ធៀបជាមួយនឹង លក្ខណៈវិនិច្ឆ័យ ដែលកំណត់ដោយ ក្រុមការងារបច្ចេកទេសយេនឌ័រ (សូចនាករពិនិត្យតាមដានរួមគ្នា) | ក្នុង ផែនការ | | | | |
| | | ជាក់ស្តែង | ២៥ | សូចនាករពិនិត្យតាម ដានរួមគ្នា កំពុងត្រូវបានអនុវត្ត និងរាយការណ៍ដោយក្រុមការងារបច្ចេកទេស យេនឌ័រ | | |
| ៣.៧ | ភាគរយនៃក្រុមការងារបច្ចេកទេស (TWGs) ដែលមាន ក) ផែនការការងារ និង ខ) សូចនាករពិនិត្យតាមដានរួមគ្នា ដែលឆ្លើយតប ចំពោះ | ក្នុង ផែនការ | | | | |
| | | ជាក់ស្តែង | ២៥ | សូចនាករពិនិត្យតាម ដានរួមគ្នា កំពុងត្រូវ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | យេនឌ័រ ធៀបជាមួយនឹង លក្ខណៈវិនិច្ឆ័យ ដែលកំណត់ដោយក្រុមការងារបច្ចេកទេសយេនឌ័រ (គោលនយោបាយ) | | | បានអនុវត្ត និងរាយការណ៍ ដោយក្រុមការងារបច្ចេកទេស យេនឌ័រ | | |
| ៣.៨ | ភាគរយនៃក្រសួងពាក់ព័ន្ធ (រាប់បញ្ចូលទាំងទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ) ដែលរៀបចំការបណ្តុះបណ្តាលឆ្លើយតបចំពោះយេនឌ័រ ដល់មន្ត្រី នៅតាមក្រសួង/ស្ថាប័ន របស់ខ្លួន (ភាគរយ ថ្នាក់ជាតិ) | ក្នុង ផែនការ | | | | ៥០ |
| | | ជាក់ស្តែង | ៣០ | បុគ្គលិកចំនួន ១២០ នាក់ របស់ក្រសួងមុខងារសាធារណៈ និង សិក្ខាកាមជាមន្ត្រី រដ្ឋាភិបាលចំនួន ១៧៧ នាក់នៃ សាលាភូមិន្ទ រដ្ឋបាល បាន ទទួលការបណ្តុះបណ្តាល អំពីការ ឆ្លើយតបចំពោះយេនឌ័រ | | |
| ៣.៨ | ភាគរយនៃក្រសួងពាក់ព័ន្ធ (រាប់បញ្ចូលទាំងទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ) ដែលរៀបចំការបណ្តុះបណ្តាលឆ្លើយតបចំពោះយេនឌ័រ ដល់មន្ត្រី នៅតាមក្រសួង/ស្ថាប័ន របស់ខ្លួន (ភាគរយ ថ្នាក់ក្រោមជាតិ) | ក្នុង ផែនការ | | | | ៥០ |
| | | ជាក់ស្តែង | ៣០ | បុគ្គលិកចំនួន ១២០ នាក់ របស់ក្រសួងមុខងារសាធារណៈ និង សិក្ខាកាមជាមន្ត្រី រដ្ឋាភិបាលចំនួន ១៧៧ នាក់នៃ សាលាភូមិន្ទ រដ្ឋបាល បាន ទទួលការ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | បណ្ដុះបណ្ដាល អំពីការ ឆ្លើយ តបចំពោះយេន ឌ័រ | | |
| ៣.៩ | ភាគរយរបស់ក្រុមការងារបញ្ជ្រាប យេនឌ័រ ដែលប្រើប្រាស់ថវិកាជាតិ របស់រដ្ឋាភិបាល ដើម្បីអនុវត្ត សកម្មភាពនានា (ភាគរយ) | ក្នុង ផែនការ | | | | ៦០ |
| | | ជាក់ស្ដែង | ២០ | ៨៩ | ក្រសួង ២៤ លើ ២៧ | |
| ៣.១៣ | ក្រសួងពាក់ព័ន្ធមួយចំនួន ដែល JAPR របស់ខ្លួនប្រើប្រាស់ទិន្នន័យ ឆ្លើយតបចំពោះយេនឌ័រ ដើម្បី កំណត់ពីអាទិភាព និងធ្វើសេចក្ដី សម្រេចចិត្តអំពីកម្មវិធី។ | ក្នុង ផែនការ | | ១ | គ្រប់ក្រសួង ពាក់ព័ន្ធ ទាំង អស់ដែល ត្រូវបាន ជ្រើសរើស | ១ |
| | | ជាក់ស្ដែង | 0 | N/A | | |
| ៣.១៥ | ចំនួនគោលនយោបាយ ពាក់ព័ន្ធនឹង ការងារ និងគំនិតផ្តួចផ្តើមច្បាប់ ដែល ផ្តោតលើការរើសអើង និងលើក កម្ពស់សមភាព នៅក្នុងពិភពការងារ (ចំនួន) | ក្នុង ផែនការ | | | | |
| | | ជាក់ស្ដែង | ចំនួន គំនិត ផ្តួច ផ្តើម ដែលត្រូវ បានរាយ-ការណ៍ នៅក្នុង ផែនការ បញ្ជ្រាប យេនឌ័រ របស់ ក្រសួង ការងារ | ៧៧ | សហគ្រាស ចំនួន ៧៧ បាន រៀបចំ គោលនយោ-បាយនៅ កន្លែងធ្វើការ ដែលផ្តោត លើ ការរើស អើង ស្រប ទៅតាម គោលនយោ-បាយជាតិ | |
| ៣.២១ | ភាគរយនៃសមាជិករបស់ ក្រុមប្រឹក្សា ថ្នាក់ក្រោមជាតិ ដែល ជាស្ត្រី (ភាគ រយ ឃុំ) | ក្នុង ផែនការ | | ២៥ | គោលដៅ អភិវឌ្ឍន៍ សហស្ស វត្សរ៍ កម្ពុជា | |
| | | ជាក់ស្ដែង | ១៤,១ | ១៧,៧៨ | | |
| ៣.២១ | ភាគរយនៃសមាជិករបស់ ក្រុមប្រឹក្សា ថ្នាក់ក្រោមជាតិ ដែល ជាស្ត្រី (ភាគ រយ ខេត្ត) | ក្នុង ផែនការ | | | | |
| | | ជាក់ស្ដែង | ១០,១ | ១៣,២៣ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣.២១ | ភាគរយនៃសមាជិករបស់ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែល ជាស្ត្រី (ភាគរយ ស្រុក) | ក្នុង ផែនការ | | | | |
| | | ជាក់ស្តែង | ១២,៦៥ | ១៣,៨៥ | | |
| ៣.២២ | ភាគរយនៃនិយោជិតក្នុងវិស័យ សាធារណៈ ដែលកាន់មុខតំណែងកម្រិតខ្ពស់ (ចាប់ពីប្រធានឡើងទៅ) (ភាគរយ ប្រុស) | ក្នុង ផែនការ | | | | |
| | | ជាក់ស្តែង | | ៦ | | |
| ៣.២៦ | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានដាក់ឱ្យអនុវត្ត | ក្នុង ផែនការ | | ១ | ច្បាប់ត្រូវបាន ដាក់ឱ្យអនុវត្ត | ១ |
| | | ជាក់ស្តែង | ០ | | | |
| ៣.២៩ | ផែនការការងារប្រចាំឆ្នាំ ដែលត្រូវបានប៉ាន់ប្រមាណចំណាយ សម្រាប់ផែនការសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើស្ត្រី ត្រូវបានរៀបចំឡើង។ | ក្នុង ផែនការ | | ៣ | ផែនការ ការងារត្រូវ បានប៉ាន់ប្រមាណ ចំណាយរួច | ៤ |
| | | ជាក់ស្តែង | ០ | | | |

នៅក្នុងករណីមួយចំនួន ទិន្នន័យគោល និងចំណុចដៅ មិនទាន់ត្រូវបានកំណត់នៅឡើយ

## លទ្ធផលទី ៤ – អភិបាលកិច្ច

**ហេតុដល់ឆ្នាំ ២០១៥ ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានគណនេយ្យភាព និងវិធានការបានប្រសើរជាងមុន តបនឹងតម្រូវការនិងសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា និងបង្កើនការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចតាមបែបប្រជាធិបតេយ្យ**

### *សេចក្តីផ្តើម*

*អ.ស.ប គាំទ្រការប្តេជ្ញារបស់កម្ពុជា ចំពោះអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំពុងធ្វើការ៖ ពង្រឹងយន្តការនានាសម្រាប់ការសន្ទនា ការធ្វើជាតំណាង និងការចូលរួម, បង្កើនការចូលរួមក្នុងជីវភាពនយោបាយ, ពង្រឹងសមត្ថភាពរបស់ក្រុមងាយរងគ្រោះ និងទន់ខ្សោយ ដើម្បីទាមទារសិទ្ធិរបស់ពួកគេ, និងពង្រឹងសមត្ថភាពរបស់ស្ថាប័នរដ្ឋដើម្បីការពារសិទ្ធិរបស់ពលរដ្ឋ។*

កិច្ចប្រឹងប្រែងក៏បានធ្វើផងដែរ ដើម្បីកសាងសមត្ថភាពសម្រាប់ប្រមូល ទទួលបាន និងប្រើប្រាស់ ព័ត៌មានតាមផ្នែក ដើម្បីកសាងគោលនយោបាយ និងផែនការ ដើម្បីកែលម្អសេវាសាធារណៈ និងដើម្បីពង្រឹងវិធានការតាមវិស័យដើម្បីឆ្លើយតបនឹងមេរោគអេដស៍/ ជម្ងឺអេដស៍។

ការគាំទ្ររបស់អ.ស.ប នៅក្នុងវិស័យវិមជ្ឈការ និងសហវិមជ្ឈការ (D&D) និងកំណែទម្រង់រដ្ឋបាលដែលពាក់ព័ន្ធ ត្រូវបានសម្របសម្រួល តាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) និងក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការនិងសហវិមជ្ឈការ រួមទាំង កិច្ចផ្តួចផ្តើមដើម្បីគាំទ្រដំណើរការកសាងផែនការនៅថ្នាក់ក្រោមជាតិផងដែរ។ ការគាំទ្ររបស់អ.ស.ប នៅក្នុងវិស័យកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ត្រូវបានសម្របសម្រួលតាមរយៈក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ដែលមានអ.ស.ប ជាសហប្រធាន។

### *លទ្ធផលឆ្នាំ 2014*

នៅឆ្នាំ2014 អ.ស.ប បានគាំទ្រដល់កិច្ចផ្តួចផ្តើមអប់រំយុវជន "ឡូយ 9" ដែលបានផលិតកម្មវិធីទូរទស្សន៍ វិទ្យុ និងការផ្សាយតាមបណ្តាញអនឡាញ ដែលបានរួមចំណែកបង្កើនការទទួលព័ត៌មានក្នុងចំណោមយុវជន អំពីជីវភាពរបស់ពលរដ្ឋ និងការចូលរួមនៅក្នុងសកម្មភាពជាពលរដ្ឋ ដែលបានគ្របដណ្តប់យុវជនកម្ពុជាប្រមាណ 3លាននាក់។ លទ្ធផលនានារាប់បញ្ចូល ការផលិតកម្មវិធីឡូយ9 ភាគ 3 រួមជាមួយទស្សនាវដ្តីទូរទស្សន៍សរុបចំនួន 37ច្បាប់ និង 114 ភាគនៃកម្មវិធីតាមវិទ្យុ។ ការសិក្សាមួយអំពីការចូលរួមរបស់យុវជនស៊ីវិលនៅកម្ពុជា ដែលបានប្រកាសជាផ្លូវការនៅខែមីនា ឆ្នាំ 2014 បានគូសបញ្ជាក់អំពីឥទ្ធិពលជាសំខាន់នៃកម្មវិធីឡូយ9 មកលើ ចំណេះដឹងពលរដ្ឋ ឥរិយាបថ និងការអនុវត្តក្នុងចំណោមពលរដ្ឋវ័យក្មេង។ ទស្សនិកជនឡូយ9 បានបង្ហាញអំពីចំណេះដឹងយ៉ាងច្រើនអំពីលក្ខខណ្ឌជាពលរដ្ឋ បានសំដែងឥរិយាបថវិជ្ជមាន ចំពោះការចូលរួមនៃពលរដ្ឋនិងបានដឹងអំពីឱកាសសម្រាប់ការចូលរួមរបស់សហគមន៍ និងការពាក់ព័ន្ធនៅក្នុងសកម្មភាពនោះផងដែរ។

ផ្អែកលើជោគជ័យនៃកម្មវិធីឡូយ9 អ.ស.បបានបង្កើត និងប្រកាសកិច្ចផ្តួចផ្តើមថ្មីមួយកាលពីខែវិច្ឆិកាឆ្នាំ 2014 ក្នុងគោលដៅរួមចំណែកកសាងចំណេះដឹង និងសមត្ថភាពក្នុងចំណោមពលរដ្ឋវ័យក្មេង ជាពិសេស ស្ត្រីវ័យក្មេង នៅក្នុងការចរចាជាមួយអ្នកធ្វើសេចក្តីសម្រេចដើម្បីមានឱកាសការងារកាន់តែប្រសើរ និងពង្រឹងរបរចិញ្ចឹមជីវិត។

នៅក្នុងកិច្ចប្រឹងប្រែងនានាដើម្បីផ្ទេរមុខងារពីស្ថាប័នថ្នាក់កណ្តាល ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្រោមដំណើរការកែទម្រង់វិមជ្ឈការនិងសហវិមជ្ឈការ (D&D) ជាមួយការគាំទ្រពីអ.ស.ប ក្រសួងចំនួនប្រាំមួយបានបញ្ចប់ការវិភាគមុខងារ និងក្រសួងចំនួនបួនបានបញ្ចប់ការពិនិត្យកែសម្រួលមុខងារ។ ក្រសួងសុខាភិបាល (MoH) និងក្រសួងអភិវឌ្ឍន៍ជនបទ (MRD) បានបង្កើតគំរូសាកល្បងដើម្បីកំណត់មុខងារមួយចំនួនសម្រាប់ផ្ទេរទៅថ្នាក់ក្រោមជាតិ។ អ.ស.បនិងដៃគូអភិវឌ្ឍន៍ដទៃទៀត បានផ្តល់ការគាំ

ទ្រទ្រង់បច្ចេកទេសដល់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្តសកម្មភាពកំណត់មុខងារបែបនេះ។

ចំពោះការរៀបចំផែនការ គោលនយោបាយ និងគោលការណ៍ណែនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) គោលនយោបាយស្តីពីការរៀបចំផែនការត្រូវបានរៀបចំជាសេចក្តីព្រាង និងត្រូវបានរំពឹងថានឹងបានអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។

ជាមួយការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ វឌ្ឍនភាពត្រូវបានកត់សំគាល់នៅក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តគណនេយ្យភាពសង្គម។ សម្ភារៈព័ត៌មានសម្រាប់ពលរដ្ឋ (I4C) ផ្សំដោយព័ត៌មានអំពីសេវាដែលមានស្តង់ដារសេវាកម្ម ថវិកា និងសិទ្ធិ របស់ពលរដ្ឋ ក៏ត្រូវបានរៀបចំផងដែរ។ NGOs និងទីកន្លែងជាគោលដៅត្រូវបានជ្រើសរើស ហើយនីតិវិធី និងឧបករណ៍នានាសម្រាប់ការតាមដានដែលនាំមុខដោយពលរដ្ឋ ត្រូវបានរៀបចំបង្កើត និងសាកល្បងផងដែរ។ មានការរំពឹងថា ស្រុកចំនួន 20នឹងអនុវត្តសកម្មភាពនានាដែលទាក់ទងនឹងការផ្សព្វផ្សាយសម្ភារៈ I4C ការកសាងសមត្ថភាពសហគមន៍ និងពលរដ្ឋ ដើម្បីពួកគេអាចតាមដាន និងផ្តល់យោបល់តប ទៅអ្នកផ្តល់សេវា និងចូលរួមក្នុងការរៀបចំផែនការសម្រាប់សកម្មភាពរួមគ្នា ដើម្បីដោះស្រាយភាពខ្វះចន្លោះនៃការផ្តល់សេវាសង្គម។

ជាមួយការគាំទ្រពីអ.ស.ប សម្ព័ន្ធភាពជាតិនៃក្រុមប្រឹក្សាមូលដ្ឋាន(NLC) បានអនុវត្តការពង្រីកសមាគមន៍ថ្នាក់ខេត្ត(PAs) ចំនួន14 ដែលនៅសល់ និងបានរួមបញ្ចូលក្រុមប្រឹក្សានៅថ្នាក់ស្រុក ក្រុង និងខណ្ឌផងដែរ។ លើសពីនេះ សមាគមជាតិនៃក្រុមប្រឹក្សារាជធានី-ខេត្ត(NACPC) ត្រូវបានបង្កើតឡើងនៅថ្នាក់រាជធានីនិងខេត្តផងដែរ។ អ.ស.ប បានផ្តល់ការគាំទ្រសម្រាប់ការរៀបចំនិងបណ្តុះបណ្តាលអំពីក្រមអនុវត្តសម្រាប់សមាជិកក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។ លើសពីនេះ ការគាំទ្រត្រូវបានផ្តល់សម្រាប់ការបង្កើតលេខាធិការដ្ឋានរួមគ្នាមួយនៃសមាគមទាំងពីរនេះ (NLC និង NACP)។ តួនាទីចំបងនៃសមាគមទាំងពីរនេះ និងលេខាធិការដ្ឋានគឺ តស៊ូមតិការពារប្រយោជន៍នៃរដ្ឋាភិបាលមូលដ្ឋានខ្លួនឯង នៅថ្នាក់ជាតិ និងផ្តល់សេវាកម្មនានាដល់សមាជិកខ្លួន។

អ.ស.ប បានគាំទ្រដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) នៅក្នុងរៀបចំ និងបង្កើយយុទ្ធសាស្រ្តសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូសម្រាប់ឆ្នាំ 2014-2018 និងសូចនាករតាមដានរួមគ្នា។ កិច្ចការនេះបង្កើតជាវិធីសាស្រ្តដែលផ្អែកលើលទ្ធផលនៅក្នុងការគ្រប់គ្រងលទ្ធផលនៃការអភិវឌ្ឍ និងភាពជាដៃគូ (ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងដៃគូត្បូង-ត្បូង) ដែលផ្អែកលើការកៀងគរធនធាន និងការធានាឲ្យមានការបន្សុីគ្នាជាមួយអាទិភាពអភិវឌ្ឍន៍ជាតិ។ កិច្ចការនេះក៏ជម្រុញផងដែរឲ្យមានតម្លាភាព និងគណនេយ្យភាពនៃជំនួយអភិវឌ្ឍន៍។

កិច្ចប្រឹងប្រែងខ្លាំងក្លាមួយក៏បានធ្វើផងដែរ ដើម្បីដោះស្រាយបញ្ហានៃការមិនរួមបញ្ចូលជនពិការ។ ជាមួយការគាំទ្រពី អ.ស.ប ផែនការយុទ្ធសាស្រ្តជាតិសម្រាប់ពិការភាពឆ្នាំ 2014-2018 ត្រូវបានរដ្ឋាភិបាលអនុម័ត។ របាយការណ៍ដំបូងមួយរបស់អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ត្រូវបានរៀបចំជាសេចក្តីព្រាង បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។ អង្គការជនពិការកម្ពុជា (CDPO) បានបង្កើតស្ថានីយ៍វិទ្យុជនពិការ សម្រាប់ចាក់ផ្សាយក្នុងខេត្តចំនួនពីរ - កំពង់សោម និងសៀមរាប ដែលនឹងកែលម្អលទ្ធភាពទទួលបានព័ត៌មាន និងអាចឲ្យសម្លេងរបស់ជនពិការលេចឮនៅក្នុងសង្គមទាំងមូល។ លើសពីនេះ ក្រសួងព័ត៌មានបានឯកភាពបញ្ជ្រាបពិការភាពនៅក្នុងគោលនយោបាយព័ត៌មាន។ តំណាងនានានៃCDPO ត្រូវបានរួមបញ្ចូលនៅក្នុងក្រុមការងាររបស់រដ្ឋាភិបាលកម្ពុជា សម្រាប់ការរៀបចំច្បាប់ស្តីពីការទទួលបានព័ត៌មាន។

សមត្ថភាពរបស់អគ្គនាយកដ្ឋានពន្ធនាគារ (GDP) នៃក្រសួងមហាផ្ទៃ ដើម្បីការពារសិទ្ធិមនុស្សដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ត្រូវបានកែលម្អ ដោយសារតែការផលិតផ្ទាំងព័ត៌មានចំនួនពីរ (ក្នុងចំណោមសកម្មភាពដទៃទៀត)ស្តីពីសិទ្ធិទណ្ឌិត និងគ្រួសារដែលមកសុំជួប ដែលនឹងត្រូវដាក់តាំងបង្ហាញនៅក្នុងគ្រប់ពន្ធនាគារ ក៏ដូចជា ក្នុងអគារសាធារណៈផ្សេងទៀតផងដែរ ការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្មីមួយស្តីពីការកាត់បន្ថយការដាក់ទោសនិងការលើកលែងទោស, ការពង្រឹងការបណ្តុះបណ្តាលបុគ្គលិកពន្ធនាគារ និងការកែលម្អលក្ខខណ្ឌដាក់ស្តែងក្នុងពន្ធនាគារ និងការប្រព្រឹត្តចំពោះអ្នកទោស ដែលទាំងអស់នេះធ្វើឡើងតាមរយៈការគាំទ្រពីអ.ស.ប។

អ.ស.ប បានផ្តល់ការគាំទ្រដល់រដ្ឋាភិបាល និងសង្គមស៊ីវិល សម្រាប់ការចូលរួមនៅក្នុងដំណើរការពិនិត្យជាសកលនិងទៀងទាត់ (UPR) ដែលធ្វើឡើងនៅខែមករា ឆ្នាំ 2014 ក៏ដូចជា នៅក្នុងដំណើរការនៃការផ្សព្វផ្សាយ និងការអនុវត្តអនុសាសន៍នានាពី UPR ផងដែរ។ ការគាំទ្ររបស់អ.ស.ប ក៏បានផ្តល់ផងដែរ ដល់សង្គមស៊ីវិល ក្នុងការបញ្ជូនព័ត៌មានទៅគណៈកម្មាធិការសិទ្ធិមនុស្សនៃអ.ស.ប នៅមុនការពិនិត្យនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ 2015។ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានទទួលការគាំទ្រជាច្រើនពីអ.ស.ប ដើម្បីរៀបចំរបាយការណ៍ដំបូងរបស់ខ្លួននៅក្រោមអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

សមត្ថភាពរបស់អាជ្ញាធរថ្នាក់ក្រោមជាតិនិងសង្គមស៊ីវិលក្នុងការអនុវត្តច្បាប់ឆ្នាំ 2009 ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី បានបង្កើនតាមរយៈការបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់ NGO-, CBO- និងតំណាងសហជីពកម្មករស្តីពីច្បាប់ និងមគ្គុទេសក៍អនុវត្តច្បាប់ នៅក្នុងខេត្តចំនួនប្រាំ នៅក្នុងឆ្នាំ 2014។ អ.ស.ប និងក្រសួងមហាផ្ទៃបានឯកភាពរៀបចំរួមគ្នាឲ្យមានការសន្ទនាជាបន្តបន្ទាប់នៅថ្នាក់ខេត្ត រវាងអាជ្ញាធរថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ជាពិសេស ស្តីពីសេរីភាពនៃការជួបប្រជុំ និងការសំដែងមតិ។ ការសន្ទនាថ្នាក់ខេត្តលើកដំបូងបានធ្វើឡើងកាលពីខែធ្នូ ឆ្នាំ 2014 នៅខេត្តរតនៈគិរី។

សមត្ថភាពរបស់តុលាការត្រូវបានពង្រឹង ដើម្បីទប់ស្កាត់ការឃុំខ្លួនដោយបំពាន តាមរយៈលក្ខខណ្ឌថ្មីៗដែលចៅក្រម ត្រូវផ្តល់ហេតុផល នៅពេលធ្វើការសម្រេចដាក់ចុងចោទឃុំឃាំងនៅមុនការជម្រះក្តី។ ការប្រែប្រួលនេះត្រូវបានអ.ស.ប តស៊ូមតិតាំងពីឆ្នាំ 2012មក។ អ.ស.ប បានធ្វើការជិតស្និទ្ធជាមួយក្រសួងយុត្តិធម៌ លើបញ្ហានេះ ហើយបទបញ្ជាថ្មីត្រូវក្រសួងយុត្តិធម៌ ផ្ញើទៅតុលាការទាំងអស់កាលពីខែមករា ឆ្នាំ 2014។ កំណែទម្រង់នេះនឹងជួយបង្កើនតម្លាភាព និងគណនេយ្យភាព នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់តុលាការ។ អ.ស.ប បាន និងកំពុងផ្តល់ការគាំទ្រដល់សមាគមមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី ដើម្បីរួមបញ្ចូលការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សនៅក្នុងកម្មវិធីសិក្សាដល់សិក្ខាកាមជាមេធាវីទាំងអស់។

សមត្ថភាពរបស់កងកម្លាំងនគរបាលដើម្បីស្វែងយល់អំពីនិយាមសិទ្ធិមនុស្ស ត្រូវបានបង្កើន តាមរយៈវគ្គបណ្តុះបណ្តាលនានាដែលផ្តោតលើសិទ្ធិមនុស្ស នៅពេលចាប់ខ្លួន និងការប្រើប្រាស់កម្លាំង។ អ.ស.ប ក៏បានបង្កើតជាមួយគ្នានឹងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ នូវផ្ទាំងព័ត៌មានមួយស្តីពីសិទ្ធិនៅពេលចាប់ខ្លួន សម្រាប់ដាក់តាំងបង្ហាញនៅតាមស្ថានីយ៍នគរបាលផងដែរ។

សមត្ថភាពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ត្រូវបានពង្រឹង ដើម្បីសម្រុះសម្រួលទំនាស់ក្នុងការងារ។ ករណីចំនួន 264 នៃទំនាស់ដែលពាក់ព័ន្ធជាមួយភាគីច្រើន ត្រូវបានផ្សះផ្សារនៅឆ្នាំ 2014 ក្នុងនោះ 74 ករណី ត្រូវបានដោះស្រាយដោយជោគជ័យ និង 190 ករណី បានដោះស្រាយខ្លះៗ និងបានបង្វែរទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

អ.ស.បបានផ្តល់ការកសាងសមត្ថភាពស្តីពីទំនាក់ទំនងឧស្សាហកម្ម ការសន្ទនាកិច្ចការសង្គមនិងការចរចារួមគ្នាដែលបានធ្វើឡើងសម្រាប់និយោជក និងអង្គការកម្មករ។ ជាលទ្ធផល យ៉ាងហោចណាស់សហជីពដែលមានតំណាងភាគច្រើនបំផុត (MRS) ថ្មីចំនួន 37 ត្រូវបានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ទទួលស្គាល់ជាផ្លូវការ ហើយកិច្ចព្រមព្រៀងចរចារួមគ្នា(CBAs)ថ្មីៗចំនួន37 ដែលរួមទាំង កិច្ចព្រមព្រៀងចរចាគុណភាពខ្ពស់ចំនួន12 ត្រូវបានចុះបញ្ជី។ សេចក្តីព្រាងច្បាប់ស្តីពីសហជីពកម្មករ ត្រូវបានរៀបចំរួចរាល់ ដែលមានអនុលោមភាពជាងមុន ជាមួយអនុសញ្ញា ILO ដែលបានផ្តល់សច្ចាប័ន។

ក្រុមខ័ណ្ឌស្ថាប័នមួយសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ត្រូវបានបង្កើតឡើងដោយមានការជួយពីអ.ស.ប។ គណៈកម្មាធិការប្រឹក្សាយោបល់ត្រីភាគី បានអនុម័តគោលការណ៍សម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមា ដូចជា ភាពញឹកញាប់នៃការកែសម្រួលប្រចាំឆ្នាំ ដំណើរការចរចាឈ្នះ-ឈ្នះ និងការប្រើប្រាស់ដោយតុល្យភាពនូវលក្ខណៈវិនិច្ឆ័យសង្គម និងសេដ្ឋកិច្ច ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យនេះ គណៈកម្មាធិការនេះបានវិភាគទិន្នន័យ ដើម្បីផ្តល់ជាមូលដ្ឋាននៃភស្តុតាងសម្រាប់កែតម្រូវប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ 2015 ។ ជាលទ្ធផល ដំណើរការចរចាត្រីភាគី បាននាំឲ្យមានការឯកភាពប្រាក់ឈ្នួលអប្បបរមា 128 ដុល្លា សម្រាប់កម្មករ សន្តិភាព និងស្ថិរភាព នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។

អ.ស.ប បានសហការជាមួយរដ្ឋាភិបាល (ក្រសួងអភិវឌ្ឍន៍ជនបទ (MoRD) និងក្រសួងមហាផ្ទៃ (MoI)) ដើម្បីលើកកំពស់ និងការពារសិទ្ធិដីធ្លី និងសិទ្ធិសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិច (IP)។ សហគមន៍ជនជាតិដើម(ICs) ចំនួន8 បានទទួលលិខិតទទួលស្គាល់ពី MoRD ក្នុងនោះសហគមន៍ចំនួន 7 បានទទួលលិខិតចុះបញ្ជីពី MoI។ អ.ស.ប បានជួយសហគមន៍ក្នុងការផលិតផែនទីដីសមូហភាព ដោយបានដាក់ជូនពាក្យសុំប័ណ្ណកម្មសិទ្ធិដី និងការទទួលវិធានការការពារបណ្តោះអាសន្ន ទន្ទឹមនឹងបន្តធ្វើការតស៊ូមតិដើម្បីបង្កើនធនធានដើម្បីបង្កើនល្បឿននៃដំណើរការចុះបញ្ជីដីធ្លីសមូហភាព។

ការគាំទ្ររបស់អ.ស.ប បានផ្តល់ប្រភពទិន្នន័យបើកចំហរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើឲ្យមានព័ត៌មានអនឡាញ អំពីពីសម្បទានដីធ្លី និងរួមបញ្ចូលសេចក្តីសង្ខេបអំពីបញ្ហានានាតាមប្រធានបទខុសៗគ្នា ដើម្បីធ្វើឲ្យមានព័ត៌មានដែលសាធារណជនអាចទទួលបានដោយឥតគិតថ្លៃ និងសម្រួលដល់ការស្រាវជ្រាវ និងការប្រាស្រ័យទាក់ទងរវាងក្រុមហ៊ុនសាធារណៈ និងឯកជន សង្គមស៊ីវិល និងរដ្ឋាភិបាល។ សម្បទានដីសរុបចំនួន 598 ត្រូវបានចុះបញ្ជី ដែលរួមទាំង ដីសម្បទានសេដ្ឋកិច្ចចំនួន 301 អាជីវកម្មរ៉ែចំនួន 267 និង តំបន់សេដ្ឋកិច្ចពិសេសចំនួន 30កន្លែង ក៏ដូចជា ផែនទីចល័តផងដែរ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មីរួមមួយសម្រាប់រយៈពេលប្រាំឆ្នាំ (NSDP) 2014-2018 ត្រូវបានរៀបចំឡើង និងគាំទ្រដោយភ្នាក់ងាររដ្ឋដែលពាក់ព័ន្ធ។ បន្ទាប់ពីមានការតស៊ូមតិ និងការសន្ទនាទូលំទូលាយដែលផ្អែកលើភស្តុតាង បញ្ហាគន្លឹះនៃកង្វល់ដែលទាក់ទងនឹងភាគលាភប្រជាសាស្ត្រ ចំណាកស្រុក នគរូបនីយកម្ម និទស្សន៍ចំនួនប្រជាជន យុវជន មនុស្សចាស់ សុខភាពផ្លូវភេទនិងបន្តពូជ សុខភាពមាតា និងទារក ការកសាងផែនការគ្រួសារ និងបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានដាក់បញ្ចូលដោយជោគជ័យនៅក្នុងផែនការដែលមានការអនុម័តឯកភាព និងការគាំទ្រពីអ.ស.ប។

អ.ស.ប បានផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ដល់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីធ្វើការវិភាគស៊ីជម្រៅអំពីយេនឌ័រ និងមនុស្សចាស់នៅកម្ពុជាដោយប្រើប្រាស់ និងវិភាគទិន្នន័យអង្កេតប្រជាជនកម្ពុជាចន្លោះជម្រឿនឆ្នាំ2013 កាលពីពេលថ្មីៗនេះ។ របាយការណ៍តាមប្រធានបទទាំងនេះនឹងត្រូវប្រើប្រាស់ជាភស្តុតាងសម្រាប់ការរៀបចំគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីមនុស្សចាស់ និងការធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិប្រជាជន នៅក្នុងបណ្តាឆ្នាំខាងមុខនេះ។

ដោយទទួលស្គាល់ពីផលប៉ះពាល់សង្គម-សេដ្ឋកិច្ច និងបរិស្ថាននៃនគរូបនីយកម្ម ជាពិសេស ដែលទាក់ទងនឹងសុខភាពខាងផ្លូវភេទ និងបន្តពូជ និងស្ថានភាពនៃសិទ្ធិបន្តពូជ របស់ប្រជាជនក្រីក្រ ដែលរស់នៅតាមជនបទ អ.ស.ប បានបង្កើតឡើងនៅឆ្នាំ 2014 នូវការសិក្សាដំបូងបង្អស់អំពីនគរូបនីយកម្ម។ របាយការណ៍នេះត្រូវបានរៀបចំរួចរាល់ និងត្រូវប្រើប្រាស់បន្ថែមទៀតសម្រាប់ការចែករម្លែកចំណេះដឹង ការសន្ទនាអំពីការតស៊ូមតិគាំទ្រគោលនយោបាយជាមួយរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធដទៃទៀត។

បណ្តាញ PLHIV និងក្រុមប្រជាពលរដ្ឋដែលប្រឈមបំផុត (FONPAMs) ដែលរួមទាំង បុរសស្រលាញ់បុរស បុគ្គលិកក្នុងវិស័យបម្រើការកំសាន្ត អ្នកចាក់គ្រឿងញៀន ស្រីស្រស់ និង PLHIV ត្រូវបានបំពាក់ដោយសេវាកម្មច្បាប់ដែលទាក់ទងនឹងករណីចម្លងថ្មីៗនៃមេរោគអេដស៍ និងឧបករណ៍ ព្រមទាំងជំនាញខាងសិទ្ធិមនុស្ស ដែលបានបង្កើតឡើងជាមួយការគាំទ្រពីអ.ស.ប។

អ.ស.ប ក៏បានសម្រួលដល់ការធ្វើបច្ចុប្បន្នភាពការបង្កើតកម្មវិធី និងការផ្តល់មូលនិធិថ្មីៗដែលទាក់ទងនឹងការអភិវឌ្ឍផងដែរ។ PLHIV និងក្រុមប្រជាពលរដ្ឋចំបងៗដែលរងគ្រោះដោយសារ HIV ឥឡូវនេះក្លាយជាអ្នកដើរតួសំខាន់នៅក្នុងវិធានការជាតិឆ្លើយតបនឹងមេរោគអេដស៍ ដែលរួមទាំង ការចូលរួមប្រកបដោយអត្ថន័យ និងយ៉ាងសកម្ម នៅក្នុងការពិភាក្សាគោលនយោបាយ ការធ្វើសេចក្តីសម្រេចផ្តល់មូលនិធិ និងការអនុវត្ត ដោយសារការតស៊ូមតិ និងការគាំទ្ររបស់អ.ស.ប ដល់ការកសាងសមត្ថភាព។ PLHIV មានទំនុកចិត្តកាន់តែខ្លាំងឡើង និងអាចនិយាយអំពីការមាក់ងាយ ការរើសអើង និងការបំពានលើសិទ្ធិមនុស្ស។ មេដឹកនាំនិងសមាជិកនានាបានចូលរួមយ៉ាងសកម្ម និងបានរួមចំណែកក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិវិស័យសុខភាព (2015-2020)។ ក្រៅពី NGOs ក្រុមសហគមន៍ក៏រួមចំណែកផងដែរ ក្នុងការលើកកំពស់ការយល់ដឹងអំពីសិទ្ធិ និងតម្រូវការឲ្យមានអន្តរាគមន៍សំខាន់ៗប្រកបដោយគុណភាព ការព្យាបាល ការថែទាំនិងសេវាគាំទ្រ និងការពង្រឹងសិទ្ធិអំណាច ដើម្បីកាត់បន្ថយបញ្ហាសិទ្ធិមនុស្ស។ នៅឆ្នាំ 2014 វិធីសាស្ត្រថ្មីសម្រាប់ការសាកល្បងដោយសហគមន៍ បានអនុញ្ញាតឲ្យមនុស្សចំនួនច្រើនជាង 25.000នាក់ មកពីក្រុមពលរដ្ឋរងគ្រោះចំបងៗ ដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ។

## ការប្រឈម

- អវត្តមានប្រព័ណីអំពីឯករាជ្យភាពនៃស្ថាប័នរដ្ឋ និង ការត្រួតពិនិត្យនិងការថ្លឹងអំណាច នៅតែជាការប្រឈមជារួម ក្នុងការកែលម្អអភិបាលកិច្ច និងគណនេយ្យភាពសាធារណៈ។
- វឌ្ឍនភាពក្នុងកម្រិតកំណត់អំពីកំណែទម្រង់រដ្ឋបាល (PAR) និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PMF)។
- កម្រិតទាបនៃការត្រៀមលក្ខណៈ និងការយល់ដឹងក្នុងចំណោមក្រសួងពាក់ព័ន្ធ អំពីមុខងារវិមជ្ឈការ ទៅអាជ្ញាធរនៅថ្នាក់ក្រោមជាតិ។
- វឌ្ឍនភាពយឺតយ៉ាវនៃការវិភាគនិងការពិនិត្យមុខងារ ដែលនាំឲ្យមានការពន្យាពេលអនុវត្តការកំណត់មុខងារ។
- ភាពយឺតយ៉ាវនៃការអនុវត្តនៅក្នុងការពិនិត្យមុខងារ និងការកំណត់កិច្ចការសម្រាប់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។
- ការយល់ដឹងក្នុងកម្រិតកំណត់អំពីសារៈសំខាន់នៃការកំណត់មុខងារនៅក្នុងការកែលម្អការផ្តល់សេវា។
- កង្វល់អំពីសមត្ថភាពដែលមានកម្រិតកំណត់នៃរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។
- គោលការណ៍ណែនាំក្នុងការរៀបចំផែនការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មានមាត្រាតិចតួចដែលជានាំឲ្យមានការចូលរួមពេញលេញនៃពលរដ្ឋ និងក្រុមជនងាយរងគ្រោះ ព្រមទាំងក្រុមអ្នកទន់ខ្សោយ ដូចជា ជនពិការ ពលរដ្ឋវ័យក្មេង កុមារ ស្ត្រីមានផ្ទៃពោះ។ល។
- ចំណេះដឹងអំពីច្បាប់នៅមានកម្រិតកំណត់ ហើយក្រុមពលរដ្ឋទន់ខ្សោយអាចទទួលបានសេវាច្បាប់ក្នុងកម្រិតកំណត់ ក្នុងពេលដែលឧបសគ្គខាងផ្នែកច្បាប់ នៅតែមាននៅឡើយសម្រាប់ពួកគាត់ក្នុងការទទួលបានសេវាទប់ស្កាត់និងព្យាបាលបញ្ហាមេរោគអេដស៍។
- មានការធ្វើវិភាជន៍ថវិកាក្នុងកម្រិតកំណត់ សម្រាប់កិច្ចគាំពារសង្គម និងការជួយជនពិការនៅក្នុងថវិកាក្រសួង MOSVY សម្រាប់ឆ្នាំ 2014។
- ការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិ ទាមទារពេលវែង ហើយដំណើរការមានភាពយឺតយ៉ាវ។
- ភាពមិនចុះសម្រុងគ្នាខាងនយោបាយរវាងក្រុមអ្នកពាក់ព័ន្ធខុសៗគ្នានៅកម្រិតជាតិ និងក្រោមជាតិ អំពីការបង្កើតលេខាធិការរួម សម្រាប់សមាគមរដ្ឋាភិបាលមូលដ្ឋានចំនួនពីរ។
- ការវិភាជន៍ថវិកាក្នុងកម្រិតកំណត់សម្រាប់ក្រសួងយុត្តិធម៌ និងតុលាការ ក៏ដូចជា បញ្ហាខាងមុខងារ និងទម្លាប់អនុវត្តជាទូទៅនៃប្រព័ន្ធយុត្តិធម៌ ដែលបន្តកំហិតលើលទ្ធភាពរបស់ពលរដ្ឋកម្ពុជាទូទៅក្នុងការទទួលបានសំណង នៅពេលដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។

## អាទិភាពសម្រាប់ឆ្នាំ 2015

- បន្តគាំទ្រដល់ការសន្ទនា និងការបង្កើតគោលនយោបាយបរិយាបន្ន ដែលផ្តែកលើភស្តុតាង ដែលរួមទាំងនៅក្នុងបរិបទនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រជាតិ និងរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ 2015ផងដែរ។
- បន្តគាំទ្រដល់យន្តការនានាសម្រាប់បង្កើនគណនេយ្យភាព ប្រសិទ្ធភាពជំនួយ និងការសម្របសម្រួលនៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាល។
- ផ្តល់ការគាំទ្រដល់ក្រសួងចំនួនបី នៅក្នុងការអនុវត្តកម្មវិធីសាកល្បងកំណត់មុខងារសម្រាប់ផ្ទេរទៅថ្នាក់ក្រោមជាតិ។
- គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម តាមរយៈការធ្វើការជាមួយ NGOs និងអ្នកពាក់ព័ន្ធនានានៅក្នុងតំបន់គោលដៅ។

- បន្តគាំទ្រដល់ក្រសួងផែនការ ក្នុងការពិនិត្យខ្សែបន្ទាត់នៃភាពក្រីក្រសម្រាប់កម្ពុជា ដោយផ្អែកលើវិធីសាស្ត្រថ្មីសម្រាប់កំណត់ភាពក្រីក្រ។
- ការគាំទ្រដល់ក្រសួងផែនការ ដើម្បីរៀបចំរបាយការណ៍ MDG កម្ពុជានៅឆ្នាំ 2015 ដើម្បីពិនិត្យមើលសមិទ្ធផល និងមេរៀនដែលកម្ពុជាទទួលបាន ក្នុងការឈានទៅសម្រេចគោលដៅនានាដែលបានប្តេជ្ញានៅក្រោម MDG។
- ការគាំទ្រដល់ក្រសួងផែនការ នៅក្នុងការអនុវត្តការងារត្រៀមរៀបចំសម្រាប់ការពិនិត្យពាក់កណ្តាលអាណត្តិក្នុងពេលខាងមុខនេះនៃ NSDP 2014-2018 ដែលត្រូវអនុវត្តនៅឆ្នាំ 2016 សម្រាប់ប៉ាន់ប្រមាណវឌ្ឍនភាពនៃការអនុវត្ត និងដើម្បីកែសម្រួលអាទិភាពដែលពាក់ព័ន្ធនៅក្នុងករណីចាំបាច់។
- គាំទ្រដល់ក្រសួងផែនការ ដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិប្រជាជន ដើម្បីឆ្លុះបញ្ចាំងពីបញ្ហាដែលប្រជាជនកម្ពុជាកំពុងប្រឈម ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយនេះ។
- ការកសាងសមត្ថភាពបន្ថែមទៀតរបស់ក្រុមសហគមន៍សម្រាប់ការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេនៅក្នុងការរៀបចំផែនការ ការអនុវត្ត និងការតាមដានករណីមេរោគអេដស៍ និងសេវាកម្ម SRH ក៏ដូចជា តម្រូវការខាងសិទ្ធិមនុស្សដែលពាក់ព័ន្ធ និងការតាមដានផងដែរ។
- ពង្រឹងលទ្ធភាពរបស់ PLHIV និងក្រុមប្រជាជនដែលងាយរងការប៉ះពាល់សំខាន់ៗ ជាពិសេស ក្រុមអ្នកទន់ខ្សោយ ក្នុងការទទួលបានសេវាខាងផ្នែកច្បាប់ និងសង្គម ក្រៅពីសេវាសំខាន់ៗក្នុងការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងសេវាព្យាបាល។
- គាំទ្រដល់ CDC/CRDB ដើម្បីចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រសហប្រតិបត្តិការ និងភាពជាដៃគូអភិវឌ្ឍន៍ឆ្នាំ 2014-2018 ដែលជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូសកល ស្តីពីការគ្រប់គ្រងជំនួយ។
- បន្តលើកកំពស់ការចូលរួមរបស់យុវជន ស្ត្រី និងជនជាតិដើមភាគតិច តាមរយៈការអនុវត្តកម្មវិធីអប់រំដល់សាធារណជនតាមប្រព័ន្ធព័ត៌មានពហុសណ្ឋាន និងការបង្កើននូវការយល់ដឹងតាមបែបផ្សេងទៀតអំពីសិទ្ធិ។
- ការពង្រីកសមាជិកភាពនៃសមាគមឃុំ/សង្កាត់នៅថ្នាក់ខេត្ត ដោយរួមបញ្ចូលក្រុមប្រឹក្សា DMK ទៅក្នុងខេត្តដែលនៅសល់ចំនួន13 និងការបង្កើតសម្ព័ន្ធភាពជាតិនៃសមាគមថ្មីៗ។
- គាំទ្ររដ្ឋាភិបាលក្នុងការធ្វើរបាយការណ៍អំពីស្ថានភាពនៃការប្តេជ្ញានៅលំដាប់ថ្នាក់ខ្ពស់/អន្តរជាតិចំពោះអ.ស.ប និងESCAP។
- បន្តគាំទ្រសម្រាប់កែលម្អការរស់នៅរបស់ជនពិការ (PwD) - តាមរយៈការអនុវត្តកម្មវិធីរួមគ្នារបស់អ.ស.ប ស្តីពីកិច្ចផ្តួចផ្តើមសិទ្ធិជនពិការកម្ពុជា (DRIC) ។
- បន្តគាំទ្ររដ្ឋបាលយុត្តិធម៌ប្រកបដោយប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាព និងការគាំទ្រដល់ការគ្រប់គ្រងករណីនៅក្នុងតុលាការឲ្យបានប្រសើរជាងមុន។
- បន្តការតស៊ូមតិ និងផ្តល់ការគាំទ្រដល់កំណែទម្រង់របស់រដ្ឋាភិបាល និងការកសាងសមត្ថភាពនៅក្នុងរដ្ឋបាលយុត្តិធម៌ ស្របជាមួយនិយាមអន្តរជាតិ (ដែលរួមទាំង កំណែទម្រង់ផ្នែកយុត្តិធម៌ កំណែទម្រង់ពន្ធនាគារ និងជំនួយខាងផ្នែកច្បាប់)។
- គាំទ្ររដ្ឋាភិបាលដើម្បីរៀបចំច្បាប់តុលាការការងារ អនុលោមតាមអនុសញ្ញា ILO ដែលបានផ្តល់សច្ចាប័ន និងទម្លាប់ល្អជាអន្តរជាតិ រួមជាមួយការគាំទ្រពីត្រីភាគី។
- បន្តគាំទ្រដល់សមាហរណកម្មសិទ្ធិមនុស្សនៅក្នុងការបណ្តុះបណ្តាលមេធាវី ចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងកម្លាំងនគរបាល។
- គាំទ្ររដ្ឋាភិបាល និយោជក និងសហជីព ដើម្បីកែលម្អទំនាក់ទំនងឧស្សាហកម្ម និងបង្កើតប្រព័ន្ធរឹងមាំមួយនៃការកំណត់ថ្លៃឈ្នួលអប្បបរមា។
- ពង្រីកការគាំទ្រដល់សហគមន៍ជនជាតិដើមចំនួន 10 ស្តីពីសិទ្ធិដីធ្លី និងប័ណ្ណកម្មសិទ្ធិ។

## *ការចំណាយក្នុងវិស័យនៃលទ្ធផល 4 សម្រាប់ឆ្នាំ 2014 – 2015:*

**តួលេខចំណាយប៉ាន់ស្មានសម្រាប់ឆ្នាំ ២០១៤៖ 7.914.542 ដុល្លាអាមេរិក**

**តួលេខគ្រោងចំណាយសម្រាប់ឆ្នាំ ២០១៥៖ 9.058.720 ដុល្លាអាមេរិក**

**ការវិភាគបរិមាណ - សូចនាករដែលត្រូវតាមដានក្នុងឆ្នាំ 2014**

| ល.រ | សូចនាករ | ស្ថានភាព | តួលេខគោល | ឆ្នាំ 2014 | យោបល់ | គ្រោងសម្រាប់ឆ្នាំ 2015 |
|---|---|---|---|---|---|---|
| 4.50 | ចំនួនក្រសួងពាក់ព័ន្ធដែលទទួលការគាំទ្រដោយផ្ទាល់ពី NCDD ក្នុងការ ពិនិត្យមុខងារដែលត្រូវផ្ទេរទៅថ្នាក់ក្រោមជាតិ (ចំនួន) | គ្រោង | | 3 | យ៉ាងហោចណាស់ក្រសួងពាក់ព័ន្ធចំនួនបី | 3 |
| | | ជាក់ស្តែង | 0 | | | |

ក្នុងករណីខ្លះ លក្ខខណ្ឌគោល និងចំណុចដៅ ពុំទាន់បានកំណត់នៅឡើយទេ។